ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី២៥**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាត្ធូ គ្រីស្ពារ *(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក វីល្លៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វែនណឺ

*(Mr. Alain Werner)*

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច

សួរដោយ លោក គឹម ម៉េងឃី ផ្ដើមពី......ទំព័រ ២
សួរដោយ លោកស្រី អេលីហ្សាប៊ែត វ៉ាបេសាន់ដ្រាតាណា ផ្ដើមពី......ទំព័រ ១៦
សួរដោយ លោក ហុង គឹមសួន ផ្ដើមពី......ទំព័រ ១៨
សួរដោយ លោក គង់ ពិសី ផ្ដើមពី......ទំព័រ ៣០
សួរដោយ លោក លោក ការ សាវុត្ថ ផ្ដើមពី......ទំព័រ ៣៤
សួរដោយ លោកស្រី ម៉ារីប៉ូល កានីហ្សារ ផ្ដើមពី......ទំព័រ ៤២
សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី......ទំព័រ ៥០
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី......ទំព័រ ៥៣

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| លោក វីលៀម ស្មីត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី វ៉ាបេសាន់ដ្រាតាណា | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើអង្គហេតុ នៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ តទៅទៀត ។

ក្រឡាបញ្ជី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគីដែលត្រូវចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់ទីឈើរាងវង់ក្រចកសេះនៅទីនេះ ។

មុននឹងដំណើរការពិភាក្សាដេញដោល អង្គជំនុំជម្រះសូមរំឭកដល់ភាគីដែលចូលរួមនៅក្នុងកិច្ចពិភាក្សាដេញដោលទាំងអស់ឲ្យបានជ្រាបថា ការកត់សម្គាល់របស់អង្គជំនុំជម្រះ ក្នុងការដេញដោលកន្លងមកនេះ និងទទួលសំណូមពរពីអ្នកបកប្រែភាសាផង គឺឃើញថាមានការនិយាយញាប់ ។ អ៊ីចឹងសូមអស់លោក លោកស្រី ដែលអញ្ជើញឡើងមានមតិយោបល់នោះ សូមនិយាយឲ្យបានយឺតៗ សមល្មមដែលខាងអ្នកបកប្រែភាសាមានលទ្ធភាពអាចបកប្រែភាសាបានល្អ បានច្បាស់លាស់ឲ្យចំន័យនៃការប្រើពាក្យតាមផ្លូវបច្ចេកទេសនៃការងារច្បាប់នេះ ។ ទីពីរ កត់សម្គាល់បទពិសោធន៍ពីម្សិលមិញដែរឃើញថាភាគីដែលមានបំណងលើកឯកសារនៅក្នុងសំណុំរឿងមកបង្ហាញនោះ គឺសូមឲ្យមានការត្រៀមលក្ខណៈសម្បត្តិជាមុនបានល្អ ហើយនិងបង្ហាញនូវលេខយោងនូវឯកសារហ្នឹង ទាំងបីភាសា ឬក៏ពីរភាសា ដែលតាមលក្ខណៈសម្បត្តិនៃឯកសារនីមួយៗ ដែលមានការបកប្រែជាពីរភាសា ឬបីភាសាឲ្យបានច្បាស់លាស់ ដើម្បីយើងយកមកពិនិត្យពិភាក្សា មុននឹងអនុញ្ញាតឲ្យពិភាក្សាដេញដោល ចៀសវាងការអូសបន្លាយពេលវេលា ។ ចំណុចមួយទៀត សូមរំឭកថាការតាំងសំណួរ ក៏ដូចជាមានបញ្ហាវែងហើយពេលខ្លះរំឭកម្តងហើយម្តងទៀត រហូតដល់ជនជាប់ចោទនឹងមិនបានយល់នូវសំណួរ ។ អ៊ីចឹង

សូមប្រឹងប្រែងដើម្បីរៀបចំសំណួរហ្នឹងឲ្យបានខ្លី ឲ្យបានចំបញ្ហា ដែលងាយយល់ ហើយដើម្បីងាយស្តាប់បាន ហើយនិងជនជាប់ចោទអាចឆ្លើយតបនឹងសំណួរបានផង ។ ហើយមួយទៀត គឺសូមមានការប្រុងប្រយ័ត្ន និងចៀសវាងសំណួរច្រំដែល សំណួរក្រៅអង្គហេតុនៃលើកយកមកពិភាក្សា និងសំណួរនាំមុខ ។

[០៩:១១:០៥]

អង្គជំនុំជម្រះសង្ឃឹមថាភាគីដែលចូលរួមក្នុងកិច្ចពិភាក្សាដេញដោល គឺនឹងប្រឹងប្រែងឲ្យអស់ពីលទ្ធភាព ដើម្បីពន្លឿននៃនីតិវិធីសវនាការរបស់យើងនៅក្នុងរឿងនេះឲ្យបានឆាប់រហ័ស ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅឲ្យមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។ ប្រសិនបើមានសំណួរត្រូវសួរដល់ជនជាប់ចោទ ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលបានកំណត់ធ្វើការពិភាក្សាដេញដោលនេះ ។ សូមអញ្ជើញ ។

**សួរដោយ លោក គីម ម៉េងឃី៖**

សូមអរគុណ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម នៃអង្គជំនុំជម្រះសាលាដំបូង សូមគោរពអង្គសវនាការ ។

**ស៖** ក្រោយពីបានសាកសួរ និងបានស្តាប់កន្លងមក ខ្ញុំមានសំណួរខ្លះសួរទៅកាន់លោក កាំង ហ្គេកអ៊ាវ ពាក់ព័ន្ធទៅនឹងអាជីពរបស់គាត់ដែលជាអ្នកបង្រៀននយោបាយនៅមន្ទីរស-២១ផង ហើយជាអ្នកនយោបាយនៅក្នុងសម័យនោះផង ។ សួរថា តើគោលការណ៍ជាទូទៅនៃបក្សកុម្មុយនីស្តកម្ពុជាដែលជាលក្ខណៈទូទាំងប្រទេស តាមទស្សនៈរបស់លោកយល់ តើយកទៅតាមគំរូនៃបណ្តាប្រទេសសង្គមនិយមមួយណា ឬក៏ជាគោលការណ៍នយោបាយបដិវត្តន៍របស់ខ្មែរសុទ្ធសាធ? ហើយសំណួរដាច់ដោយឡែកមួយទៀត ថាតើការអនុវត្តនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ជាគំរូដែលច្នៃប្រឌិតដោយថ្នាក់ដឹកនាំខ្មែរសុទ្ធសាធ ឬក៏មានឥទ្ធិពល ឬក៏គំរូតាមភ្នាក់ងារ ឬក៏មន្ទីរសន្តិសុខផ្សេងទៀតនៅបណ្តាលប្រទេសសង្គមនិយមនៅក្នុងសាកលលោក?

**ឆ៖** លោកប្រធានជាទីគោរព! សំណួរលោក ម៉េងឃី វែងណាស់ ខ្ញុំសូមលោកមេត្តាកាត់ម្តងបន្តិចៗឲ្យខ្ញុំឆ្លើយ ។

**ស៖** អ៊ីចឹងខ្ញុំសួរបែងចែកជាពីរសំណួរ ។ ទីមួយ ខ្ញុំសួរថាតើតាមទស្សនៈរបស់លោក គោលនយោបាយជាទូទៅនៃបក្សកុម្មុយនីស្តកម្ពុជា ដែលអនុវត្តនៅលើផ្ទៃប្រទេសហ្នឹងយកគំរូតាមប្រទេស

ណា? នេះសំណួរទីមួយ ។ ហើយសំណួរទីពីរ--

[០៩:១៤:០៥]

**ឆ៖** អរគុណលោក ម៉េងឃី សូមគោរពលោកប្រធាន ។ ខ្ញុំបានជម្រាបអង្គសវនាការយើងទាំងមូលពីមុនហើយថា ឡឺ ប៉ុល ពត ទីស មិនមែនជា ឡឺ ម៉ៅ អីស ទេ បានន័យ ប៉ុល ពត គាត់អត់មកទ្រឹស្តី ម៉ៅ សេទុង មកអនុវត្តទាំងស្រុងទេ ។ តាមការវិភាគរបស់ខ្ញុំ ប៉ុល ពត គាត់យកទ្រឹស្តីពួកអាក្រុមបួននាក់នៃមហាបក្សបដិវត្តន៍វប្បធម៌របស់ប្រទេសចិន ហើយយកមកច្នៃបន្ថែមទៅតាមគំនិតគាត់ ឲ្យវាស្របនឹងសភាពការណ៍នៅស្រុកខ្មែរ ។ លោកឃើញហើយក្នុងលក្ខន្តិកៈបក្ស ខ្ញុំអត់បានបើកមើលលក្ខន្តិកៈទេ មានជំពូកមួយ មានគោលជំហរមួយនិយាយថា យើងអនុវត្តលទ្ធិម៉ាក្ស-លេនីន ជាត្រីវិស័យ យើងមិនគម្ពីរនិយម ។ នេះខ្ញុំសូមឆ្លើយចប់សំណួរលោកប៉ុណ្ណេះ ។

**ស៖** អ៊ីចឹងតាមខ្ញុំយល់នូវការពន្យល់របស់លោកមានន័យថា ការអនុវត្តមាគ៌ានយោបាយនៃបក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺមិនមែនយកទៅតាមទ្រឹស្តីទាំងស្រុងដែលដកស្រង់អំពីបណ្តាប្រទេសទូទាំងពិភពលោកទេ គឺចេញមកពីគំនិតរបស់បដិវត្តន៍ ប៉ុល ពត សុទ្ធសាធ ឬក៏យ៉ាងម៉េច?

**ឆ៖** គ្រប់បញ្ហាទាំងអស់ វាតែងមានមុនមានក្រោយ អ្នកក្រោយឈរលើទស្សនៈគោលជំហររបស់អ្នកមុខ ហើយឈានដំណើរទៅទៀត ។ ប៉ុល ពត ឈរលើទស្សនៈរបស់ពួកអាក្រុមបួននាក់ ហើយក៏ឈានដំណើរទៅមុខមួយកម្រិតទៀត ។ ខ្ញុំជឿថា ប្រហែលលោកមិនទាន់ស្គាល់អាក្រុមបួននាក់ហ្នឹងទេក៏មិនដឹង ។ អាក្រុមបួននាក់នេះ វាធ្វើមហាបដិវត្តន៍វប្បធម៌នៅប្រទេសចិន ធ្វើឲ្យសង្គមចិនៗជួបការកាប់សម្លាប់ក្រៅប្រព័ន្ធច្បាប់ ។ អាក្រុមបួននាក់នេះទីមួយឈ្មោះ វ៉ាំង ហុងវិន អនុប្រធានបក្សកុម្មុយនីស្តចិន ទីពីរឈ្មោះ ឆាង ឈុនឈីវ--

**អ្នកបកប្រែ៖**

លោកប្រធានសូមអនុញ្ញាតឲ្យលោកជាប់ចោទ លោកអានឈ្មោះឲ្យយឺតបន្តិចទាន។

**ប្រធានអង្គជំនុំ៖**

សូមជនជាប់ចោទ មានបញ្ហាបកប្រែភាសា សូមអានឈ្មោះៗជនបរទេសជនជាតិចិនហ្នឹងឲ្យយឺតបន្តិច ដើម្បីឲ្យគាត់ស្តាប់យល់ ហើយអាចបកប្រែបាន ។

**ជនជាប់ចោទ៖**

**ឆ៖** ពួកអាក្រុមបួននេះសាកលលោកស្គាល់ ហៅថា អាក្រុមបួនហ្នឹងនៅក្នុងវចនានុក្រមឡារូស

ក៏មានដែរ គេហៅថា ឡាប៉ង់ដេកាត្រ ។ ទីមួយឈ្មោះ វ៉ាំង ហុងវិន សរសេរយ៉ាងម៉េចនៅក្នុង*ឡារូស អ៊ីរីស្ត្រេ*មាន ខ្ញុំមិនប៊ានប្រកបនៅពេលនេះទេវង្វេង ។ ទីមួយឈ្មោះ វ៉ាំង ហុងវិន អនុប្រធានបក្សកុម្មុយនីស្តចិន ទីពីរឈ្មោះ ឆាង ឈុនឈីវ, ទីបីឈ្មោះ យ៉ាវ វ៉ាន់យិន, ទីបួន ឈាង ឈីង ស្រីមេម៉ាយប្រពន្ធចុង ប្រពន្ធទីបីរបស់ប្រធានម៉ៅ ។

[០៩:១៧:៥១]

ដូច្នេះ អាក្រុមបួននាក់នេះនៅពេលដែលប្រធានម៉ៅស្លាប់ទៅ តេង ស៊ាវភីង គាត់ចាប់ដាក់គុកអស់ទៅហើយ ។ ខ្ញុំត្រឡប់ទៅក្រោយវិញ ទ្រឹស្តីរបស់ ប៉ុល ពត ឈរនៅលើទ្រឹស្តីរបស់ពួកអាក្រុមបួននេះផង ហើយគាត់ឈានដំណើរទៅមុខមួយកម្រិតទៀតរបស់គាត់ទៀតផង ។

ដូច្នេះ អានេះជាសេចក្តីសរុបរបស់ខ្ញុំទេណ៎ា មិនតំណាងឲ្យសច្ចធម៌ទាំងស្រុងរបស់កិច្ចដំណើរការរបស់លទ្ធិម៉ាក្ស-លេនីន នៅពេលនុ៎ងទេ ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ បន្តសំណួរមួយទៀត គឺទាក់ទងទៅនឹងគំរូនៃមន្ទីរស-២១ ក៏ដូចជាមន្ទីរសន្តិសុខផ្សេងទៀតនៅបណ្តាប្រទេសដែលធ្វើបដិវត្តន៍ គឺក្នុងគោលបំណងនូវការកម្ទេចខ្មាំង ។ តើការបង្កើតមន្ទីរស-២១ ទៅតាមគោលនយោបាយរបស់បក្សហ្នឹង គឺយកគំរូទៅតាមបណ្តាប្រទេសផ្សេងទៀត ឬក៏ទ្រឹស្តីមនោគមវិជ្ជាផ្សេងទៀត ឬក៏ជាគំនិតរបស់ ប៉ុល ពត តែម្នាក់? ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ហានេះខ្ញុំពិបាកឆ្លើយណាស់ ។ ដូច្នេះ សូមរំឭកការដែលថ្នាក់ដឹកនាំនិយាយជាមួយខ្ញុំជាហូរហែ កាលយើងខ្ញុំធ្វើប្រធានមន្ទីរ១៣ បង វន គឺ វ៉ន វេត លេខាភូមិភាគពិសេស ណែនាំខ្ញុំថាមិត្តខំទៅ គ្មានប្រទេសណាគេបង្រៀនយើងទេ តែគេបង្រៀនយើង វាប៉ះពាល់ដល់ការងារសម្ងាត់របស់ប្រទេសគេ ។ ម្លោះហើយគាត់ចេះតែខំណែនាំខ្ញុំរហូតមក ហើយដល់មកជួបលោកគ្រូ សុន សេន ទៀត គាត់ក៏អត់មាននិយាយពាក្យហ្នឹងទេ ក៏គាត់ខំណែនាំកិច្ចការដាក់ស្តែងឲ្យខ្ញុំជាប់លាប់ដែរ ។ កន្លះខែ មួយខែអី ខ្ញុំជិះកង់មកពីអមលាំងមកជួបគាត់នៅអាដំណាក់ស្នាច់ ស្រុកខ្មែរទេ លោកស្គាល់ប្រវែងចម្ងាយខ្លះហើយ ។

ដល់មកភ្នំពេញ នេះខ្ញុំនិយាយកាត់ៗចុះ ខ្ញុំបានជម្រាបមេខ្ញុំ លោកគ្រូ សុន សេន ខ្ញុំថានៅបារាំងគេមានអង្គការចារកម្មរបស់គេមួយឈ្មោះ *ហ្សេ៊ីកវីស ដឺ ដុកគុយម៉ង់ ប៉ាស់ហ្សុងអ៊ិចស្ត្រេរីយ៉ែរ អេដឺកុងត្រេសស្យុណាស* ។ ខ្ញុំរាយការណ៍ទៅមួយសន្ទុះសុទ្ធតែឮលោកគ្រូ សុន សេន មេខ្ញុំហ្នឹងគាត់ណែនាំមកវិញថា មិត្តឯងរៀបចំ ស-២១ តាមលំនាំ *ហ្សេ៊ីកវីសដឺកុងត្រេស្យុណាស* ។ មានន័យថាក្រសួងការងារ

ប្រឆាំងចារកម្ម ។ គាត់ណែនាំអ៊ីចឹង ។

[០៩:២០:៤៨]

ដូច្នេះ នេះជាការណែនាំទ្រឹស្តីដុល ក៏ប៉ុន្តែ ជាក់ស្តែងដូចខ្ញុំបានជម្រាបលោក មេធាវី អាឡាំង វែនណឺ ម្សិលមិញ ។ មេខ្ញុំគេជាមនុស្សហ្មត់ចត់នឹងការងារ គេតាមដានការងារខ្ញុំរាល់ល្ងាច ។ ខ្ញុំនិយាយរាល់ល្ងាចហ្នឹងដូចជាជ្រុលបន្តិច ស្ទើរតែរាល់ល្ងាចតាមទូរស័ព្ទ ។ គេឲ្យខ្ញុំរាយការណ៍ការងារប្រចាំថ្ងៃ គេណែនាំខ្ញុំរៀនវិភាគ គេតម្រង់ទិសការងារខ្ញុំ ។ ដូច្នេះ នេះជាកិច្ចការដែលខ្ញុំបានធ្វើ ។ តើយកទៅតាមលំនាំប្រទេសណា ខ្ញុំមិនហ៊ានឆ្លើយទេ វាអត់មានឯកសារ អត់មានអ្នកណានិយាយ ក៏ប៉ុន្តែ បើនិយាយអំពីផ្តាច់ការវណ្ណៈអធនខ្លាំងត្រូវតែកម្ទេច និងវារៀងច្បាស់លាស់ ។ ផ្តាច់ការវណ្ណៈអធនគ្រប់ប្រទេសបក្សម៉ាក្សលេនីន ទាំងអស់គ្រប់ប្រទេសអនុវត្តផ្តាច់ការវណ្ណៈអធន ។ ប៉ុល ពត គាត់ហៅថា ផ្តាច់ការសង្គមនិយម ។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ បន្តទៅទៀតគឺសំណួរទីបី ពាក់ព័ន្ធទៅនឹងសំណួរដែលខ្ញុំបានធ្លាប់សួរលោកម្តងហើយ ហើយលោកសន្យាថានឹងឆ្លើយនៅពេលដែលពាក់ព័ន្ធនឹងប្រធានបទគឺ ស្តីពីគោលនយោបាយ ។ អ៊ីចឹង សួរលោកថា តើគោលការណ៍នៃបក្សកុម្មុយនីស្តកម្ពុជា គេបានកំណត់នូវសញ្ញាណ ឬក៏អត្ថន័យថាពាក្យថាខ្លាំងហ្នឹង វាមានន័យថាយ៉ាងដូចម្តេច ដែលហៅថាខ្លាំង?

**ឆ៖** ពាក្យថា “ខ្មាំង” បើនិយាយពីក្នុងឋានៈ ដំបូងគេវិភាគសង្គមកម្ពុជាមុនថ្ងៃ១៧ មេសា គេវិភាគសង្គមកម្ពុជាវាឃើញមានវណ្ណៈកសិករ វណ្ណៈកម្មករ វណ្ណៈអនុធន ដែលរួមមានបញ្ញាជននៅក្នុងនុំង វណ្ណៈនាយទុនជាតិស្នេហាជាតិ ហើយមានវណ្ណៈប្រតិកិរិយាពីរ គឺសក្តិភូមិ និងនាយទុនប្រតិកិរិយា ។ នៅឆ្នាំ១៩៧៤ ទស្សនាវដ្តីទង់បដិវត្តន៍មានកំណត់វណ្ណៈពិសេសពីរ គឺទាហាន និងប៉ូលិសហ្នឹងវណ្ណៈពិសេសមួយ ។ វណ្ណៈពិសេសមួយទៀត ប៉ុល ពត គាត់កំណត់ព្រះសង្ឃក្នុងពុទ្ធសាសនា ។

ខ្ញុំសូមបញ្ជាក់អំពីវណ្ណៈពិសេសពីរចុងក្រោយនេះ គ្មានឯកសារដែលមានលក្ខណៈដូចគ្នាទៅនឹងឯកសារបក្សកុម្មុយនីស្តចិនមិនមានលក្ខណៈដូចគ្នាជាមួយនឹងឯកសាររបស់ ប៉ុល ពត ទេ ចំពោះបញ្ហានេះ ។

ហើយនិយាយពីព្រះរាជវង្សានុវង្សក៏ឯកសារបក្សកុម្មុយនីស្តចិន គ្មានដូចឯកសារបក្សកុម្មុយនីស្តកម្ពុជាដែរ ។ ក៏ប៉ុន្តែ វណ្ណៈពិសេសពីរ លោកសង្ឃ និងទាហាន ប៉ូលិល, ប៉ុល ពត គាត់កំណត់ថាចំពោះបញ្ហាពុទ្ធសាសនានៅកម្ពុជាមិនអីទេ ដែលអាក្រក់គឺលទ្ធិកម្មផល ។ ចំណែក លោកសង្ឃជាកូន

កសិករ ក្រពះលោកសង្ឃពឹងលើឆ្នាំងបាយកសិករ ។ ដូច្នេះ បើកសិករមិនឲ្យឆាន់ លោកសង្ឃក៏មិនមានដែរ ។ នេះគាត់និយាយអ៊ីចឹងអំពីបញ្ហាពុទ្ធសាសនា ព្រះភិក្ខុសង្ឃ ។

[០៩:២៥:៤៤]

ដល់និយាយអំពីទាហាននិងប៉ូលិស គាត់ថា ពួកអស់នេះកាន់កាំភ្លើងខ្លាំងមកសម្លាប់ប្រជាជនកម្ពុជា ពិសេសនៅត្រង់ហ្នឹង ។ នេះឆ្នាំ១៩៧៤ យើងខ្ញុំឃើញឯកសារអ៊ីចឹង ។ ដល់១៧ មេសា ឯកសារដែលនៅសល់បានបង្ហាញឲ្យឃើញថា គេបានកម្ចាត់វណ្ណៈផ្សេងៗទាំងអស់ ហើយរៀបចំតែវណ្ណៈពីរទេ ។ ដូច្នេះ ជម្លៀសក៏ដោយសារបញ្ហាវណ្ណៈ ទុកឲ្យនៅសល់វណ្ណៈពីរគឺកម្មករនិងកសិករ ។ កម្ចាត់នាយទុក រដ្ឋកាន់កាប់រោងចក្រក៏បញ្ហាវណ្ណៈ ។ ជម្លៀសបញ្ញាជនទៅជនបទឲ្យធ្វើស្រែចម្ការ ជ្រើសរើសបញ្ញាជនមួយចំនួនមកកម្ទេច។ បញ្ញាជនខ្លះហៀរមកដល់ស-២១ផង។ ក៏ដោយសារបញ្ហាវណ្ណៈ ។ នេះរយៈកាលទីមួយ គឺមុនឯកសារ៣០ មីនា ១៩៧៦ ។

ដោយសារបដិវត្តន៍កម្ពុជានៅសល់តែវណ្ណៈពីរនេះហើយ ដែលនាំឲ្យខ្ញុំកំណត់ថា លទ្ធិ ប៉ុល ពត មិនមែនលទ្ធិម៉ៅ ទេ ។ ម៉ៅ សេទុង ក្រោយគាត់រំដោះនៅសល់វណ្ណៈបួន នៅប្រទេសគាត់ គឺកម្មករ កសិករ អនុធន រួមទាំងបញ្ញាជននៅក្នុងនុ៎ង ហើយនិងវណ្ណៈនាយទុនជាតិស្នេហាជាតិ ។ ម៉ៅ សេទុង គាត់ធ្វើផ្កាយនៅក្នុងទង់ជាតិគាត់ គាត់ធ្វើផ្កាយ ។ ផ្កាយតូចៗបួន តំណាងឲ្យវណ្ណៈបួនហ្នឹង ។ អាផ្កាយធំមួយហ្នឹងតំណាងឲ្យបក្សកុម្មុយនីស្តចិន នេះភស្តុតាងមួយ ។ ភស្តុតាងមួយទៀត គឺទង់របស់កម្ពុជាប្រជាធិបតេយ្យ អង្គរវត្តកំពូលបី អាហ្នឹងជាក្រឹត្យក្រមហើយ ។ ព្រះនរោត្តម សីហនុ ក៏ព្រះអង្គធ្វើកំពូលបីដែរ ក៏ប៉ុន្តែកំពូលបីរបស់ ប៉ុល ពត អាកណ្តាល ខ្ញុំជឿថា តំណាងបក្ស ។ ខ្ញុំមិនឃើញឯកសារណាទេ ប៉ុន្តែ អាកណ្តាលតំណាងបក្ស អាពីរនេះតំណាងឲ្យវណ្ណៈកម្មករ កសិករ ។

ហើយលោកអញ្ជើញមើលចំរៀងគោរពទង់ជំនាន់នុ៎ងចុះ មុនដំបូងឈាមក្រហមឆ្អៅ អ៊ីចឹងឈាមកម្មករ កសិករ បញ្ញាជន ឈាមយុវជន ព្រះសង្ឃ ហើយនិងនារីអីហ្នឹង ។ ដល់ក្រោយមកឈាមកម្មករ ឈាមកសិករ ឈាមយុទ្ធជន យុទ្ធនារីបដិវត្តន៍ ។ ទាត់ចោលវណ្ណៈអស់ផ្សេងអស់រលីង ។ ហ្នឹងវាបញ្ជាក់អ៊ីចឹង ។ ដូច្នេះ ម៉ៅ សេទុង ទុកវណ្ណៈបួន, ប៉ុល ពត ទុកវណ្ណៈពីរ ។ ហ្នឹងដែលខ្ញុំបានបញ្ជាក់ជូនទាំងអស់ថា តាមការវិភាគនេះ ខ្ញុំថា ប៉ុល ពត លទ្ធិ ប៉ុល ពត មិនមែនលទ្ធិម៉ៅ ។ ខ្ញុំនិយាយអ៊ីចឹង ។

ដូច្នេះ នេះជាគោលការណ៍មួយ និយាយដល់ទៅឫគល់នៃទ្រឹស្តីនយោបាយហើយ ។ ដូច្នេះ ខ្ញុំសូមបញ្ចប់ប៉ុណ្ណោះ មិនដឹងជាពេញលេញនឹងសំណួរលោកហើយឬនៅទេ បើមិនពេញទេ សូមមេត្តាសួរ

ទៀតចុះ ។

[០៩:២៩:៤០]

**សៈ** អ៊ីចឹង សូមបញ្ជាក់បន្ថែមជាមួយនឹងលោកបន្តិច លោកថា នៅក្នុងពាក្យថាខ្មាំង វាមានគឺនៅក្នុងឆ្នាំ៧៤ និយាយអំពីវណ្ណៈ មានព្រះសង្ឃ ហើយនិងទាហាន ឬក៏ប៉ូលិស ។ ក្រោយការវិវឌ្ឍន៍នៃ ១៧ មេសា មក ខ្មាំងគឺមានក្រុមសក្តិភូមិហើយនិងនាយទុន ។ តែក្រោយពីសេចក្តីសម្រេចនៅ៣០ ខែមីនា ឆ្នាំ១៩៧៩ វណ្ណៈនៅតែ-- *(សូមទោស)* ៧៦ គឺថាវណ្ណៈ គឺសល់តែពីរទេ ។ អ៊ីចឹងក្រៅពីហ្នឹងគឺត្រូវបានចាត់ទុកថាជាខ្មាំងទាំងអស់ តើអ៊ីចឹងមែនទេ?

**ឆៈ** អរគុណនឹងការសួរបញ្ជាក់ខ្ញុំ ។ និយាយទៅវារង្វេងទិស នេះសូមជម្រាបដោយត្រង់ ។ ឆ្នាំ ១៩៧៤ ឯកសារវាចេញមក ពេលដែលវណ្ណៈពិសេស គាត់អត់ប៉ានទាន់ធ្វើអីទេៗ គ្រាន់តែអប់រំជួរបក្សអំពីមាគ៌ា អំពីទ្រឹស្តីនយោបាយ ។ ដល់១៧ មេសា ៧៥ បានគាត់ប៉ានធ្វើ ។ ដូចខ្ញុំបាននិយាយពីលើកមុនអ៊ីចឹង ១៧ មេសា ១៩៧៥ គាត់អាងកម្លាំងបក្សជនរាប់ម៉ឺននាក់នៅក្នុងកណ្តាប់ដៃគាត់, គាត់ចេញមាគ៌ាដែលប៉ះពាល់ដល់អាយុជីវិតប្រជាជន ។ នេះជារឿងពិត ។

ដូច្នេះ រឿងជម្លៀសដូចខ្ញុំនិយាយជូនលោកអំមិញហ្នឹង រឿងជម្លៀស រឿងអី វាស្ថិតនៅក្នុងការសម្រិតសម្រាំងវណ្ណៈនេះឯង ។ ដូច្នេះ វណ្ណៈពីរនេះវានៅសល់ក្រោយ ១៧ មេសា កម្មករ និងកសិករ ។ គេហៅថា កម្មករសមូហភាពទៅទៀត លោក ម៉េងឃី មិនមែនកម្មករធម្មតាទេ កម្មករសមូហភាព កសិករសមូហភាព ។ គឺមានអង្គភាពជាកងចល័ត មានពួក មានក្រុម មានអនុសេនាតូច អនុសេនាធំរបស់គេអ៊ីចឹង ច្បាស់លាស់ ។ ហ្នឹងគេហៅថាកម្មករសមូហភាព កសិករសមូហភាព ។ ទូទាំងប្រទេសវាទៅជាអង្គភាពដែលមានការចាត់តាំង ។ ហ្នឹងហើយដែល ប៉ុល ពត គាត់មានប្រសាសន៍ហៅថា កម្មករសមូហភាព កសិករសមូហភាព ។

ដូច្នេះ ខ្មាំងគេកម្ចាត់រួចអស់ហើយ គេកម្ចាត់រួចអស់ ។ បើតាមខ្ញុំដឹងសម្តេចសង្ឃរាជ ហួត តាត ដោយសារស្នាដៃ៧០៣ ។ បើតាមខ្ញុំដឹងដែរគ្មានឯកសារទេ ប៉ុន្តែ សម្តីដែលខ្ញុំឮ ។ បើតាមខ្ញុំដឹងដែរ ឧត្តមសេនី បេង ឡៃយុង, ឧត្តមសេនី ឈឹម ឈួន, ឧត្តមសេនី ជា គឹមអេង នៅក្នុងកណ្តាប់ដៃ៧០៣ ។ អ្នកដឹកនាំសង្ឃ គេកម្ចាត់ស្ងាត់ៗអ៊ីចឹង ដូចកម្ចាត់ព្រះសង្ឃរាជ ហួត តាត។ ក៏ប៉ុន្តែ ព្រះភិក្ខុសង្ឃទូទាំងប្រទេស គេជម្លៀសទៅជនបទ គេផ្សឹក គេរុញឲ្យទៅជាកសិករឡើងវិញ ។

[០៩:៣៣:០៥]

ដូច្នេះ ទិសរបស់គាត់ មាគ៌ាសកម្មភាព វាច្រើន វាសម្បូរបែប ក៏ប៉ុន្តែ ទិសធ្វើម៉េចឲ្យបានទៅជាកម្មករ និងកសិករ ។ វណ្ណៈតែពីរហ្នឹង ។ អ្នកណាប្រឆាំងចាប់ ។ អ្នកល្អមៗមិនប្រឆាំងទេ គេទុកឲ្យរស់ ក៏ប៉ុន្តែ បញ្ញាជនគេទៅស្រាវជ្រាវយកមកពីជនបទ ។ អាហ្នឹងអ៊ីចឹង ។

ដល់ឯកសារថ្ងៃ៣០ មីនា ១៩៧៦ ប៉ុល ពត គាត់ចាប់គិតអំពីផ្ទៃក្នុងបក្ស ដោយឡែកត្រង់ហ្នឹង។ រឿងហ្នឹងខ្ញុំរាយការណ៍ជូនចៅក្រមស៊ើបអង្កេតច្បាស់ហើយ ពេលហ្នឹងគាត់ចាប់ផ្តើមគិតគូរអំពីខ្មាំងសត្រូវបង្កប់នៅក្នុងផ្ទៃក្នុងបក្ស មិនមែននៅក្នុងផ្ទៃក្នុងប្រជាជនជាធំទេ គឺក្នុងផ្ទៃក្នុងបក្ស ។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

ដូច្នេះ យើងគិតមាគ៌ាជារួមអំពីស្អីដែលហៅថាខ្មាំងអ៊ីចឹង ។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងអ្នកណាកំណត់ថាខ្មាំង ។ ហ្នឹងចូលទៀតហើយ ចូលពួកក្រុមបួននាក់នុ៎ង, អ៊ូ! ពួកៗមនុស្សបួនក្រុមហ្នឹងដែលមានចែងនៅក្នុងសេចក្តីសម្រេចចិត្តថ្ងៃ៣០ មីនា ១៩៧៦ ។ គឺពួកហ្នឹងហើយជាអ្នកសម្រេច ។ មាគ៌ាជារួមវាមាន ក៏ប៉ុន្តែ ដល់អនុវត្តជាក់ស្តែងពួកហ្នឹង អ្នកណាម្នាក់ក្នុងពួកហ្នឹងជាអ្នកសម្រេច ។

ឧទាហរណ៍នៅក្នុងកងទ័ពមជ្ឈិម អ្នកសម្រេចមានតែមួយទេ គឺមេខ្ញុំ លោកគ្រូ សុន សេន បើគ្មានគាត់ទេ គ្មានអ្នកណាហ៊ានសម្រេចទេ ។ អ្នកឯងហ៊ានតែសម្រេច អ្នកឯងហ៊ានដាច់ក ។ នេះអំពីរឿងខ្មាំងអនុវត្តជាក់ស្តែង គឺវាទៅតាមការបែងចែងការចាត់ចែងរបស់ពួកបួនក្រុមហ្នឹង ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ពាក់ព័ន្ធនឹងសំណួរលោកបានលើកឡើង គឺថា វាមានដំណាក់កាលពីរនៅក្នុងការកម្ទេចខ្មាំង គឺដំណាក់កាលទីមួយ គឺវាប់ចាប់គិតថាពី ១៧ មេសា ១៩៧៥ មក ហើយដំណាក់កាលទីពីរ ចាប់ផ្តើមពីមានសេចក្តីសម្រេច ៣០ ខែមីនា ឆ្នាំ១៩៧៦ ។ អ៊ីចឹង ខ្ញុំមានសំណួរមួយសួរទៅលោកថាតើលោកអាចពន្យល់បានទេថា គោលបំណងអ្វីដែលវាមានការប្រែប្រួល និងការវិវឌ្ឍចំពោះអត្ថន័យនៃការកម្ទេចខ្មាំង នៅក្នុងនយោបាយនៃបក្សកុម្មុយនីស្តកម្ពុជាយ៉ាងដូចនេះ?

**ឆ៖** ខ្ញុំសុំរំឭកពាក្យស្លោកមួយ ពាក្យស្លោករបស់បក្សកុម្មុយនីស្តកម្ពុជា គេថា “ជ័យជម្នះយើងជាជ័យជម្នះរបស់មហាជន” ពាក្យស្លោកគេថា “មហាចលនាមហាជន មហាលោតផ្លោះ មហាអស្ចារ្យ” ។ ដូច្នេះ ការដែលចេញពីវណ្ណៈប៉ុន្មានស្មេកស្មុះ មកជាវណ្ណៈពីរហ្នឹង គេទុកជាមហាជ័យជម្នះមួយហើយ ។ យើងមើលទិសដៅធំបំផុតនៃកុម្មុយនីស្តនិយមគឺស្អី? ទិសដៅធំបំផុតនៃកុម្មុយនីស្តនិយមវណ្ណៈតែមួយទេណា គឺកម្មករ សង្គមកុម្មុយនីស្ត គឺសង្គមកម្មករ មានតែកម្មករទេ ។

[០៩:៣៦:៥៥]

ដូច្នេះ នៅកម្ពុជាជំនាន់នោះ វាមានកម្មករ កសិករ តែពីរទេ គេចង់ទៅដល់អាន់ុង ។ យើងមើលមួយទៀត ពាក្យស្លោកនៅក្នុងសង្គម សង្គមនិយម "ពីម្នាក់ៗតាមសមត្ថភាព ហើយប្រគល់ផលទៅឲ្យម្នាក់ៗវិញ តាមសាច់ការ" នេះក្នុងសង្គមៗនិយម ។ ដល់សង្គមកុម្មុយនីស្តនិយម "ពីម្នាក់ៗតាមសមត្ថ-ភាព ហើយប្រគល់ទៅឲ្យម្នាក់ៗវិញ តាមសេចក្តីត្រូវការ" មិនមែនតាមចិត្តចង់ទេ គឺតាមសេចក្តីត្រូវការ ។ សេចក្តីត្រូវការនៃការងារអ្នកឯងបានប៉ុន្មាន គឺឲ្យប៉ុណ្ណឹង ។

ឧទាហរណ៍ យើងខ្ញុំខំធ្វើការឲ្យគេ បាយទឹក ដូចគេ ដូចឯង ក៏ប៉ុន្តែ ដោយឡែក យុទ្ធជនគេមានម្ហូបតែមួយមុខទេ ។ ផ្ទាល់ខ្លួនខ្ញុំ មិត្តហ៊ី គាត់ឧបត្ថម្ភម្ហូបពីរមុខ ព្រោះ ខ្ញុំចូលចិត្តម្ហូបក្រៀម នេះខុសគេប៉ុណ្ណឹង ។ រួចរបបគេឲ្យមានម៉ូតូ សេ អិល មួយ។ បារីគេឲ្យ នេះទៅតាមសេចក្តីត្រូវការ អ្នកឯងត្រូវការស៊ីប៉ុន្មាន ដើម្បីបម្រើបដិវត្តន៍ឲ្យបានស្រួលខ្លួន គេឲ្យ ។ នេះទិសដៅគេទៅដល់ហ្នឹង អានេះសាច់ទ្រឹស្តីណ៎ា ។ ក៏ប៉ុនក្នុងអនុវត្ត តាមខ្ញុំចាំ ដូចជាសំណួររបស់លោក តាន់ សេណារ៉ុង ពីរឿងប្រជាជនអត់បាយ ដកគេ ដាក់អ្នកបដិវត្តន៍ទៅវាមានបាយស៊ី ។ ខ្ញុំបានជម្រាបលោក តាន់ សេណារ៉ុង ថា អាហ្នឹងជាទ្រឹស្តីទេ ។ ការពិត គឺដើម្បីកម្ចាត់បក្ខពួកគេ ដាក់បក្ខពួកឯង កម្ចាត់បក្ខពួក កែ ពក ដាក់បក្ខពួក តាម៉ុក ។

ដូច្នេះ ប៉ុល ពត គាត់ជឿទុកចិត្តតែបក្ខពួក តាម៉ុក បក្ខពួកផ្សេងទៀត គាត់អត់ជឿទុកចិត្ត ។ កសិករនៅឧត្តរ គេខំតស៊ូបដិវត្តន៍ដែរ ។ ចុងបញ្ចប់ថ្ងៃ៣១ ខែមករា ១៩៧៧ ចាប់គ្នាទាំងឈុត យកមកឲ្យស-២១ ។ សូមបញ្ជាក់ថា កម្មាភិបាលឧត្តរនិងខ្ញុំ មានមនោសញ្ចេតនានឹងគ្នាណាស់ ខ្ញុំជាអ្នកឧត្តរដល់អញ្ចើង ខ្ញុំតក់ស្លុតដែរ ។ ខ្ញុំគិតថា អ្ហឺ! អ្នកលះបង់អាយុជីវិតសាច់ឈាម ដើម្បីជាតិប្រជាជន ឥឡូវមកស្លាប់ក្នុងស-២១ ក្នុងឋានៈក្បត់បក្ស ។ វាហួសចិត្ត ។

សរុបមកវិញ ជាអាថ៌កំបាំងគឺ ប៉ុល ពត គាត់ទុកចិត្តតែកសិករ ខាងខ្មែរ តាម៉ុក ទេ ផ្សេងទៀតអត់ទុកចិត្តទេ ។ នេះដែលនាំឲ្យខ្ញុំគូរ *ការីកាត់ទ័រ* មួយជូនអង្គសវនាការ ។ ហ្នឹងខ្ញុំសូមជម្រាបអ៊ីចឹង ។

**ស៖** អ៊ីចឹង ខ្ញុំអាចយល់បានខ្លះ អំពីគោលបំណងនៃការធ្វើបដិវត្តន៍តាមផ្នែកទ្រឹស្តី លោកបានលើកឡើងថា គឺជាការទុកតែវណ្ណៈតែមួយ ឬក៏ពីរនៅក្នុងសង្គមនៃបដិវត្តន៍តែប៉ុណ្ណោះ ហើយវណ្ណៈផ្សេងទៀតត្រូវលុបបំបាត់ ឬក៏កម្ទេចចោល ។ ក៏ប៉ុន្តែ ក្នុងការអនុវត្ត វាគឺជាជម្លោះនៅក្នុងផ្ទៃក្នុងនៃបក្សកុម្មុយនីស្តកម្ពុជា តើការយល់របស់ខ្ញុំហ្នឹងត្រឹមត្រូវដែរទេ?

[០៩:៤០:៤៦]

**ឆ៖** ត្រឹមត្រូវជាមូលដ្ឋានហើយៗ ។

**ស៖** អ៊ីចឹង ខ្ញុំវិលទៅរកសំណួរមួយសួរថា ដោយសារមានបញ្ហាទំនាស់រវាងផ្ទៃក្នុងនៃបក្សកុម្មុយនីស្តកម្ពុជា តើក្នុងគោលបំណងនូវការកម្ទេចខ្មាំង ឬទាំងអស់ហ្នឹង គឺសុទ្ធតែជម្លោះរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ។ តើនៅក្នុងការអនុវត្តនូវការកម្ទេចគ្នាទៅវិញទៅមកហ្នឹង គេប្រើមធ្យោបាយ ឬក៏គោលនយោបាយយ៉ាងដូចម្តេច ឬក៏គេមានស្ថាប័នរបស់គេរៀងៗខ្លួននៅក្នុងការដើរតួនាទីកម្ទេច ឬក៏មានស្ថាប័នណាមួយពិសេសសម្រាប់ក្នុងការស្វែងរក ឬក៏កំណត់អ្នកដែលជាខ្មាំងបដិវត្តន៍ហ្នឹង?

**ឆ៖** ស្ថាប័នដែលកំណត់ខ្មាំងបដិវត្តន៍ហ្នឹង ស្ថាប័នកំពូលជាងគេ គឺអចិន្ត្រៃយ៍មជ្ឈិមបក្សៗនិយាយឲ្យចំគឺ បងប៉ុល ហ្នឹងតែម្តង លេខាបក្ស មាគ៌ាក៏គាត់ចេញ អប់រំក៏គាត់ក្តាប់ ការតែងតាំងក៏គាត់តែងតាំង ។ លោកមើលចុះឯកសារនៅសល់ថ្ងៃ១៩ ថ្ងៃ២០ ថ្ងៃ២១ មេសា គាត់តែងតាំងស្ថាប័ន១១ ឬ១៣ អ៊ីចេះ នៅភ្នំពេញ គាត់តែតាំង ស្អីក៏គាត់តែងតាំងដែរ ។ ឯកសារថ្ងៃ០៩ ខែតុលា ១៩៧៥ គាត់តែងតាំង សុន សេន ឲ្យធ្វើនគរបាល ។ នេះវាមានឯកសារនៅសល់ឲ្យយើងស្រួលនិយាយ ស្រួលបង្ហាញ នេះខ្ញុំសុំចប់ប៉ុណ្ណេះ ។

**ឆ៖** ដូច្នេះ ខ្ញុំនឹងវិលទៅរកសំណួរទាក់ទងទៅនឹងការអនុវត្តគោលនយោបាយដោយមន្ទីរស-២១ នៅក្នុងការកម្ទេចខ្មាំង ។ តើមន្ទីរស-២១ អនុវត្តគោលនយោបាយទៅតាមបក្សកុម្មុយនីស្តកម្ពុជា ដែលដាក់ឲ្យទាំងបួនក្រុម ឬក៏តំណាងឲ្យក្រុមណាមួយនៅក្នុងចំណោមក្រុមទាំងបួនហ្នឹង?

**ឆ៖** សូមជម្រាបលោក ម៉េងឃី ថា មនុស្សទាំងបួនក្រុមនេះ មានដប់បួននាក់ ក៏ប៉ុន្តែផ្ទាល់មកកាន់កាប់ស-២១ គឺមានតែម្នាក់ទេ គឺលោកគ្រូ សុន សេន ។ គេមិនអាចមកទាំងដប់បួននាក់កើតទេ ។

**ស៖** ដូច្នេះ ខ្ញុំបន្តសំណួរទៀត។ អ៊ីចឹងលោកថា ដឹកនាំផ្ទាល់ដោយលោក សុន សេន តើនៅក្នុងក្រោមការដឹកនាំ ការបញ្ជារបស់លោក សុន សេន មន្ទីរស-២១ មានផែនការច្បាស់លាស់ទេនៅក្នុងការកម្ទេចខ្មាំង ឬក៏មានជាយុទ្ធសាស្ត្រអីជាក់លាក់សម្រាប់ដូចជាផែនការបីឆ្នាំ ពីរឆ្នាំ នៅក្នុងការកម្ទេចខ្មាំង ឬក៏បោសសម្អាតខ្មាំងហ្នឹងដែរឬទេ?

[០៩:៤៤:៥៦]

**ឆ៖** ខ្ញុំសូមជម្រាបលោក ម៉េង ឃី ណា ខ្ញុំសូមសារភាពត្រង់ហើយ ថាផែនការពីរឆ្នាំ បីឆ្នាំដែលលោកមានប្រសាសន៍អំមិញ ខ្ញុំមិនដែលបានឃើញទេ នេះតាមពិត ។ ទីពីរ ខ្ញុំសូមបញ្ជាក់ថា ភារកិច្ច

របស់ស-២១ មនុស្សដែលគេចាប់បញ្ជូនមកហើយត្រូវតែពុះពារសួរចម្លើយឲ្យចេញឲ្យគេ ។ សួរចម្លើយបានហើយ ចម្លើយរាយការណ៍ជូនទៅខាងលើ ខាងលើពេញចិត្តនឹងចម្លើយនេះហើយ ស-២១ ត្រូវតែយកចេញទៅកម្ទេច ។ បើគេមិនទាន់ពេញចិត្តទេ គេឲ្យសួរម្តងទៀត ស-២១ ត្រូវតែសួរ ។ ធ្វើម៉េចកុំឲ្យរត់រួច ធ្វើម៉េចស-២១ កុំដោះលែងណា៎ ងាប់ ហើយធ្វើម៉េច ស-២១ កុំចេះតែដើរទៅចាប់ណា៎ ព្រោះអ្នកឯងមិនមានសិទ្ធិសម្រេចកម្ទេចទេ ធម្មតាតែចាប់ហើយ គឺកម្ទេច ។ ដូច្នេះ ខ្ញុំសូមនិយាយប៉ុណ្ណឹងជម្រាបលោក ម៉េងឃី ។

**ស៖** ពាក់ព័ន្ធទៅនឹងលោកនិយាយថា គឺមិនមានផែនការច្បាស់លាស់ទេ ក៏ប៉ុន្តែ មានការបញ្ជូនគឺសម្រាប់ស-២១ ក្នុងការសួរចម្លើយ យកចម្លើយ ។ អ៊ីចឹង ពាក់ព័ន្ធទៅនឹងចម្លើយសារភាព តើវាមានបច្ចេកទេស ឬក៏របៀបវិភាគទៅលើចម្លើយសារភាពជាក់លាក់ នៅក្នុងមន្ទីរស-២១ ហ្នឹងដែរឬទេ ឬក៏ជាគ្រាន់តែជាចម្លើយដែលវាយបង្ខំ ឬក៏ជាចម្លើយដែលមានការវិភាគច្បាស់លាស់សម្រាប់ជូនទៅថ្នាក់លើ?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ជាក់ថា វិធីសួរចម្លើយ ថ្វីត្បិតតែយកទារុណកម្មជាជំនួយក៏ដោយ ក៏ប៉ុន្តែមិនមែនចាប់មកដល់ភិសភូស ទាត់ធាក់ភ្លាមទេ ។ គេមានដំណើរការពីស្លូតទៅកាច ។ អ្នកខ្លះក៏មានសមត្ថភាពវិភាគបានច្បាស់លាស់ទៅ ពឹងផ្អែកលើទារុណកម្មមានកម្រិតរបស់គេពីទាបទៅខ្ពស់ទៅដូចជាមិត្តប៉ុន ។ អ្នកខ្លះគាត់មានសមត្ថភាពវិភាគខ្ពស់ដែរ តែគាត់មិនព្រមធ្វើទារុណធ្វើទារុណកម្ម ដូចបងម៉មណៃ ជម្រាបត្រង់ អត់ធ្វើទេ មិនងាយធ្វើទេ ។ ឯចំណែក អ្នកខ្លះ ល្ងាសណាស់ ស្រួលមិនស្រួលទារុណកម្មឥឡូវហ្នឹង ដូចមិត្តទុយ នេះខ្ញុំសូមលើកឧទាហរណ៍អញ្ចឹង ។

សរុបមក ចម្លើយសារភាពនៅស-២១ សុទ្ធតែពឹងផ្អែកលើទារុណកម្ម លើកលែងតែម្នាក់គត់គឺ កុយ ធួន អត់បានវ៉ៃគាត់ទេ ។ ចម្លើយ កុយ ធួន ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំមិនទាំងប៉ានវិភាគផង ព្រោះវាជាប់នឹងការងារជាជម្រៅ ដែលមានតែអចិន្ត្រៃយ៍ទេដែលយល់ ។ ខ្ញុំជូនទាំងដុលៗទៅមេតែម្តង ។ ឯចំណែកចម្លើយខ្លះដែលខ្ញុំវិភាគ ការវិភាគរបស់ខ្ញុំធ្វើម៉េចសម្រាប់តែសម្រួលដល់ការអាន និងការក្តាប់របស់មេប៉ុណ្ណឹង ។

[០៩:៤៨:៤៨]

ដូចចម្លើយដែលខ្ញុំនិយាយជាមួយលោក វ៉ៃនណឺ ពីម្សិលមិញ ខាងក្នុងខ្ញុំមានចារមែន ខ្ញុំចារជាសេចក្តីជម្រាបបន្ថែម ។ ខ្ញុំចារថា “បង អានេះ ពីឆ្នាំ១៩៧០ វាមានការទាក់ទងជាមួយ កុងហ្គេរីយ៉ា

ចំរើនរិទ្ធិ អ៊ូ!ន៉ែ កំហែងរិទ្ធិ" ។ អ៊ឺ! ខ្ញុំចារអ៊ីចឹង ព្រោះប្រវត្តិនោះ ខ្ញុំចាំច្បាស់ ខ្ញុំជាអ្នកគ្រប់គ្រងពួកហ្នឹង ខ្ញុំចារអ៊ីចឹង របៀបហ្នឹង គ្រាន់តែផ្តល់ព័ត៌មានបន្ថែម ។ ជួនអីខ្ញុំចារ ខ្ញុំអត់ទាំងបានចារផង ។

ឧទាហរណ៍ ដូចឯកសារមួយដែល ឌី ខាំប៉ូលី យកទៅផ្សាយពេញប្រទេសនោះ ។ ខ្ញុំដូចជាចារតិចណាស់ ក្នុងនុំង អត់ទាំងចារផង គ្រាន់តែឆូត ឬយ៉ាងម៉េចមិនដឹងទេ ភ្លេចទៅហើយ ។ ដូច្នេះ ចំណារអស់នេះ គឺសម្រាប់តែមេខ្ញុំ គាត់ស្រួលអាន គាត់ស្រួលក្តាប់បញ្ហាបានប៉ុណ្ណឹងឯង អត់មានវិធីចារអីៗយ៉ាងម៉េច ទៅបង្វែរការពិតឲ្យប៉ះពាល់ដល់ភាពជាសត្យានុម័តរបស់ឯកសារហ្នឹងទេ ។

ដូច្នេះ សួរចម្លើយក៏ចៀស មិនឲ្យអត្តនោម័តិរបស់អ្នកសួរ វាប៉ះពាល់ទៅលើនេះពេក អើគេសួរអាហ្នឹងធម្មតាក្មេងៗទេ។ បើខ្ញុំសួរ ផ្ទាល់ខ្ញុំដែលសួរ កុយ ធួយ ខ្ញុំអត់ដែលនិយាយដល់សាច់រឿងទេ ។ កុយ ធួន គាត់ឧស្សាហ៍ប្រតិកម្ម វិលៗបោកតុ បោកអី កាច់វែនតា កាច់ស្ទីលឡូ កាច់អីចោល ខ្ញុំទុកឲ្យគាត់បាត់ខឹងប្រហែលជាកន្លះម៉ោង មួយម៉ោងអី បានខ្ញុំទៅជួប ។ ដល់ទៅដល់ជួប ខ្ញុំញញឹមបន្តិចទៅម៉េចបងខ្ញុំនៅតែហៅគាត់បងអ៊ីចឹង ទៅធ្វើអីអ៊ីចឹង បងកុំស្មានតែប្អូនហ្នឹងឆោត ទៅវ៉ៃបងឲ្យស្លាប់ដាច់ចម្លើយអត់ទេបង ប្អូនអត់ឆោតទេ ប្អូនចេះ រឿងហ្នឹងប្អូនចេះជាងបង រួចប្អូនបានសន្យាហើយ បងសរសេរមកប្អូនដើរតួជានីរសារជូនសេចក្តីរាយការណ៍របស់បងទៅអង្គការ ។ បងគ្មានផ្លូវឯណាទៅជួបអង្គការក្រៅពីសរសេរកំណត់ហេតុហ្នឹង ជូនទៅអង្គការតាមប្អូនទេ ។ និយាយចុះនិយាយឡើង ធម្មតាយើងមានអំណាចផង កុយ ធួយ សុខចិត្តសរសេរតទៅទៀត នេះរួចហើយខ្ញុំចេញមក ។

ដូច្នេះ ក្នុងការសួរចម្លើយ ខ្ញុំអប់រំគ្នាខ្ញុំ ធ្វើម៉េចកុំឲ្យអត្តនោម័តិរបស់យើង វាទៅសង្កត់លើឯកសារហ្នឹងពេក ។ កាលលើកមុន និយាយអំពីនៅមន្ទីរ១៣ ក្នុងការវ៉ៃស្រីម្នាក់ ខ្ញុំរិះរកវិធីចេញក្រៅយ៉ាងម៉េច ដើម្បីនឹងទៅឲ្យគេមុជទឹកហើយងើបទៅហាលត្រជាក់ ខ្យល់ត្រជាក់ហ្នឹង ខ្ញុំបាននិយាយរួចអស់ហើយ នេះរបៀបសួរ ។

ដូច្នេះសរុបមួយមាត់ របៀបសួរធ្វើម៉េចកុំឲ្យអត្តនោម័តិរបស់អ្នកសួរសង្កត់ទៅលើអ្នកឆ្លើយ នេះមួយ ប៉ុន្តែគ្នាអ្នកមិនមានពិសោធចៀសមិនរួច ពីជះឥទ្ធិពលទៅលើទេ ។ ទីពីរ សួរថ្វីត្បិតតែពឹងផ្អែកលើទារុណកម្មជាជំនួយ ក៏ប៉ុន្តែអ្នកខ្លះសង្កត់ធ្ងន់លើទារុណកម្ម ណ្ហើយហើយបានៗវាលេចរូបភាពទារុណកម្មផ្តេសផ្តាសច្រើន ដែលខ្ញុំបានទទួលស្គាល់ចំពោះមុខជាតិប្រជាជនខ្ញុំរួចទៅហើយថា ទារុណកម្ម វាលើស វាមានទារុណកម្មយ៉ាងអាសអាភាសផង (សុំទោស) យ៉ាងឃោរឃៅផងដែលខ្ញុំត្រូវតែទទួលស្គាល់ ចៀសមិនរួច ។ នេះរឿងទារុណកម្ម ។

[០៩:៥២:៤៧]

ឯកចំណែក រឿងឯកសារ ខ្ញុំជាអ្នកចារ ខ្ញុំគ្រាន់តែមានបំណងធ្វើម៉េចឲ្យមេខ្ញុំគាត់ស្រួលយល់ ហើយបើយើងធ្វើម៉េចឲ្យគេសម្គាល់បានថា យើងវាលម្អៀងចង់ឲ្យចាប់អ្នកនេះលម្អៀងចង់ឲ្យចាប់អ្នកនោះ យើងក៏មិនសុខដែរ នេះរឿងឯកសារដែលខ្ញុំរាយការណ៍ទៅ ។ រួចខ្ញុំសូមបញ្ជាក់ឡើងវិញ ឯកសារ ស-២១ ចេញទៅ គឺវាទៅដល់ដៃលោកគ្រូ សុន សេន នេះតាមការខ្សែចាត់តាំងៗ ដែលយើងធ្លាប់ហៅថាខ្សែបណ្ដោយនោះ ពីខ្ញុំទៅដល់ សុន សេន, សុន សេន គាត់រៀបចំអីស្រួលបួលគាត់ទៅសុំសេចក្ដីសម្រេច ជាពិសេសរបស់ បងប៉ុល បើមិនបានទេ ក៏សម្រេចរបស់ ពូនួន ដែរ នេះឯកសារនៅនេះ គឺគាត់សុំសេចក្ដីសម្រេចរបស់ ពូនួន ដល់បានសម្រេចហើយ បានៗឯកសារហ្នឹងវាប៉ោនចេញទៅលេខាភាគផ្សេងទៀត វាមិនមែនចេះតែអចិន្ត្រៃយ៍មជ្ឈិមចែកគ្នាអានឯកសារ ហើយចែកគ្នាចារនោះទេ នេះសរុបមកវិញ ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងមានន័យថា ដូចអ្វីដែលលោកបានលើកឡើងកន្លងមក ទាក់ទងនឹងពាក្យថា "ខ្មាំង" គឺឲ្យតែត្រូវបានបញ្ជូនមកមន្ទីរស-២១ គឺចាត់ទុកថាស្លាប់ជាមុនរួចទៅហើយ ឬក៏ចាត់ទុកថាជាខ្មាំង ឬក៏ដែលត្រូវកម្ទេចចោលជាមុនរួចហើយ ។ អ៊ីចឹង វាមានសារប្រយោជន៍អ្វីខ្លះនៅក្នុងការធ្វើចំណារ ឬក៏ការវិភាគលើចម្លើយសារភាពឲ្យអ្នកដែលបញ្ជូនមកហ្នឹង ចាំគាត់យល់ ឬក៏ស្រួលស្ដាប់ទៅលើចម្លើយសារភាពដែលគាត់ចាត់ទុកថា ជាខ្មោច ឬក៏ជាខ្មាំងបដិវត្តន៍ហ្នឹងរួចទៅហើយហ្នឹង?

**ឆ៖** អរគុណ លោកម៉េង ឃី ដែលលើកបញ្ហានេះសួរខ្ញុំ ។ មនុស្សដែលគេចាប់មកហើយ គ្នាស្លាប់ហើយស្រេច នេះពិត ក៏ប៉ុន្តែខាងលើគេត្រូវការសេចក្ដីសារភាព ដើម្បីយកទៅតាមចាប់អ្នកផ្សេងទៀត នេះជាវត្ថុបំណងទីពីរ ។ វត្ថុបំណងទីមួយ គឺកម្ទេចមនុស្សដែលគេឲ្យចាប់ វត្ថុបំណងទីពីរ យកទៅស្រាវជ្រាវចាប់អ្នកផ្សេងទៀត ។

[០៩:៥៥:៥៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនៅមានសំណួរច្រើនទេ ដូចជាក្រុមមួយ ក្រុមបីនេះ ចំណាយពេលវេលាមួយម៉ោងហើយនែ៎ ។ ហើយសុំសួរខ្លី ហើយចំបញ្ហា ហើយការឆ្លើយតបក៏ដូច្នោះដែរ ឃើញថាមានការវិលចុះវិលឡើង មានការច្រំដែលមួយចំនួន វាមិនទាំងអស់ទេ ។ អ៊ីចឹង រៀបចំនូវសំណួរ របៀបសួរជាថ្មីឲ្យបានច្បាស់លាស់ ហើយចៀសវាងនូវបញ្ហាច្រំដែល ហើយសុំរំឭកដល់ជនជាប់ចោទផងដែរថា សុំឆ្លើយ

ឲ្យចំនឹងសំណួរ នៅក្នុងករណីណាដែលមានការច្រំដែលគឺ មិនអាច ប្រើសិទ្ធិមិនឆ្លើយតបក៏បាន នេះជាសិទ្ធិរបស់ជនជាប់ចោទដែលមានជាដរាប នៅក្នុងដំណើរការនីតិវិធី ។

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន! ខ្ញុំមានសំណួរមួយចំនួនទៀតដែលត្រូវសួរ តែខ្ញុំមិនដឹងថារយៈក្នុងការឆ្លើយហ្នឹង វាអាចត្រូវចំណាយពេលយូរ ឬក៏ឆាប់ទេ វាអាស្រ័យទៅលើសំណួរ ទៅនឹងការបកស្រាយរបស់ជនជាប់ចោទ ។ ក៏ប៉ុន្តែ ខ្ញុំនឹងព្យាយាមសង្ខេបនូវសំណួររបស់ខ្ញុំ តាមលទ្ធភាពដែលអាចធ្វើទៅបាន ហើយនិងចៀសវាងនូវសួរសំណួរច្រំដែល ។ ហើយដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានថា បើសិនជាខ្ញុំអាចបន្តសំណួរបាន ខ្ញុំសុំបន្តសំណួរទៅកាន់ជនជាប់ចោទបន្តទៀត មុននឹងឈប់សម្រាកឬក៏មានការឈប់សម្រាកហើយ ខ្ញុំអាចបន្តនូវសំណួររបស់ខ្ញុំក្រោយពីការឈប់សម្រាក ឬក៏យ៉ាងដូចម្ដេច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៅទៀត ប៉ុន្តែគ្រាន់តែរំឭកអំពីការពេលវេលា ដែលត្រូវប្រឹងប្រែងដើម្បីជាការពន្លឿននៅក្នុងដំណើរការនីតិវិធីសវនាការ ។ អ៊ីចឹង យើងបានរំឭកពីព្រឹកហើយ អំពីបច្ចេកទេសក្នុងការសួរគឺរិះរកមធ្យោបាយគិតគូដើម្បីតាំងសំណួរឲ្យបានខ្លី ឲ្យបានចំបញ្ហា ងាយក្នុងការស្ដាប់ ហើយជនជាប់ចោទក៏ដូចគ្នា លោកនឹងស្ដាប់បាន ហើយនឹងឆ្លើយតបចំនឹងសំណួរ ដោយចំត្រង់តែម្ដងចៀសវាងការបកស្រាយនូវសំណួរមួយ ដែលមានលក្ខណៈវែង ហើយនិងមានបញ្ហាច្រំដែលជាច្រើន ទាំងការសួរទាំងការឆ្លើយនោះ ។

**សួរដោយលោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។

[០៩:៥៨:២១]

**ស៖** អ៊ីចឹងខ្ញុំសូមបន្តសំណួរទៅកាន់លោក កាំង ហ្គេកអ៊ាវ បន្តទៀត ពាក់ព័ន្ធទៅនឹងពាក្យសម្ដីរបស់លោកប៉ុល ពត ដែលនិយាយថា “ដាវដែលមុតគឺដាវដែលត្រូវប្រើ និងសំលៀងជារៀងរាល់ថ្ងៃ” ។ អ៊ីចឹងនៅក្នុងការដឹកនាំរបស់លោកក្នុងការអនុវត្តមាគ៌ាកម្មេចខ្មាំងឲ្យមានប្រសិទ្ធភាពហ្នឹង តើលោកមានរៀបចំជាគោលការណ៍ជាក់លាក់ ឬក៏អ្វីដែលកំណត់នៅក្នុងការដឹកនាំហ្នឹងទេ ដើម្បីឲ្យប្រៀបដូចជាដាវដែលមុត ដែលជាពាក្យសម្ដីរបស់ ប៉ុល ពត ហ្នឹង?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា សេចក្តីត្រូវការចាំបាច់គឺខាងលើតឿន ដើម្បីរត់តាមសំណូមពរខាងលើទាន់ យើងមិនទៅកំហែង ឬឡូឡាដាក់កម្មាភិបាលខាងក្រោមទេ ។ វិធីល្អបំផុត គឺយកគេមករៀន ។ នេះដែលឆ្លើយទៅនឹងសំណូមពរខាងលើបាន ។ ដូច្នេះ ផែនការអីជាក់លាក់យ៉ាងម៉េច ពេលណាត្រូវបំពាក់បំប៉នរឿងអី អត់មានទេ គឺការបំពាក់បំប៉ន វាឆ្លើយទៅតាមសំណូមពរដែលខាងលើត្រូវការ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ខ្ញុំអស់សំណួរដែលពាក់ព័ន្ធទៅនឹងបញ្ហានេះហើយ ក៏ប៉ុន្តែ ខ្ញុំមានសំណួរពាក់ព័ន្ធនឹងពាក្យស្លោកមួយចំនួន ដែលខ្ញុំយល់ថា វាអាចជាការលែងពាក្យរបស់អ្នកនយោបាយសម័យនោះ ឬក៏វាអាចជាគោលនយោបាយរបស់បក្សសម័យនោះ ដែលគេប្រើពាក្យស្លោកមួយចំនួន ហើយបើសិនជាលោកអាចបកស្រាយនូវពាក្យស្លោកនោះបាន ខ្ញុំនឹងសួរនូវពាក្យស្លោកនោះ ទីមួយគឺថា "ទុកក្អមិនចំណាយ ដកចេញមិនខាត" តើពាក្យស្លោកហ្នឹងគឺជាគោលនយោបាយក្នុងការកម្ទេចខ្មាំងដែរឬទេ? ឬក៏ជាទ្រឹស្តីដែលគេគ្រាន់តែនិយាយសម្រាប់តែការកែកំសាន្ត?

**ឆ៖** ពាក្យស្លោកហ្នឹង អត់កែកំសាន្ត ។ នៅស-២១ ត្រចៀកខ្ញុំឮពីមាត់លោកគ្រូ សុន សេន ដើមបណ្តឹងរដ្ឋប្បវេណី ក៏មាននិយាយពាក្យហ្នឹងដែរ នោះអ្នកបងគាត់សរសេរនៅក្នុងបណ្តឹងគាត់ ដូច្នេះ មិនមែនមានឮតែនៅស-២១ ទេ នៅជនបទក៏មានដែរ ។

**ស៖** អ៊ីចឹង វាមានន័យជាក់លាក់យ៉ាងដូចម្តេច? តើលោកអាចពន្យល់ឡើងសង្ខេបបានទេ?

**ឆ៖** នេះជាដោះសាររបស់អចិន្ត្រៃយ៍ ឬរបស់បុគ្គលណាមួយនៃពួកបួនក្រុម ។ កាលណាយើងតវ៉ាគេអ៊ីចេះអ៊ីចុះ គេថាអ្នឹ១ ទុកក៏មិនចំណាយ ដកចេញក៏មិនខាតដែរ ។ ម្សិលមិញខ្ញុំប្រើពាក្យស្លោកនេះ នៅពេលដែលខ្ញុំចុះចាញ់ទស្សនៈគោលជំហររបស់លោកគ្រូ សុន សេន និយាយអំពីអនីតិជនកុមារតូច កុមារធំ ខ្ញុំប្រើពាក្យស្លោកនេះ ហើយតាមពិតក្នុងបញ្ហានេះ ជាការវិភាគរបស់ខ្ញុំនៅពេលនេះទេ ដែលខ្ញុំប្រើពាក្យស្លោកនេះ ចេញពីមាត់គាត់រឿងផ្សេង មិនដឹងរឿងអីទេ ខ្ញុំភ្លេចទៅហើយ ប៉ុនខ្ញុំឮដំបូងពីមាត់គាត់ច្បាស់ ។

[១០:០២:៤៥]

**ស៖** អ៊ីចឹង ខ្ញុំបន្តពាក្យស្លោកមួយទៀតដែលនិយាយថា "តវ៉ាខ្មាំង ប្រឆាំងខ្មោច" តើពាក្យហ្នឹងមានដែរឬទេ?

**ឆ៖** ពាក្យនេះ ខ្ញុំមិនឮពីសំឡេងដឹកនាំទេ ក៏ប៉ុន្តែ ខ្ញុំជឿថា សម្រែកដួងចិត្តរបស់ប្រជាជនកម្ពុជាដែលរងទុក្ខវេទនា ។

**ស៖** ជាបន្តទៀត គឺពាក្យស្លោកដែលលោកលើកកាលពីម្សិលមិញគឺថា “វៃរហ័ស ឈ្នះរហ័ស” ពាក្យនេះគឺសំដៅទៅលើការកម្ទេចឲ្យបានរហ័ស នឹងទទួលបានផលរហ័ស ឬក៏យ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ ខ្ញុំប្រើពាក្យនេះ នៅពេលដែលខ្ញុំនិយាយអំពីរឿងឆ្លៀតបង្រៀន ឆ្លៀតពេលមួយម៉ោងបាន ខ្ញុំឆ្លៀត ។ ដូច្នេះ វៃមួយម៉ោងនេះ ដើម្បីឈ្នះការងារចំពោះមុខរបស់ខ្ញុំដែលចោទក្នុងរយៈមួយអាទិត្យ ពីរអាទិត្យហ្នឹង ។ ដូច្នេះ និយាយអំពីខ្លឹមសារដែលខ្ញុំបង្រៀនទេ ។

**ស៖** អ៊ីចឹង បន្តទៅសំណួរចុងក្រោយរបស់ខ្ញុំ ទៅលើពាក្យស្លោកដដែលពាក្យថា “ដឹកស្មៅត្រូវដឹកទាំងឫស” តើជាទ្រឹស្តីដែលអនុវត្តនៅស-២១ ឬក៏ជាពាក្យដែលគេប្រើប្រាស់នៅខាងក្រៅទេ?

**ឆ៖** ខ្ញុំមិនធ្លាប់ប្រើពាក្យនេះ បង្រៀនកូនចៅខ្ញុំទេ ហើយខ្ញុំក៏ដូចជាមិនឮ គេប្រើក្នុងស-២១ទេ ។ ដូច្នេះ ខ្ញុំអាចជឿថា ពាក្យនេះមានប្រើហូរហែនៅខាងក្រៅ ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន តំណាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី អស់សំណួរសួរទៅកាន់ជនជាប់ចោទហើយ ។ សូមអរគុណ ។

**លោកស្រី វ៉ាំបេសាន់ជ្រាតាណា៖**

លោកប្រធានខ្ញុំមានសំណួរពីរ-បី ដើម្បីសួរទៅជនជាប់ចោទបន្តទៀត ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញមេធាវី ។

**សួរដោយលោកស្រី វ៉ាំបេសាន់ជ្រាតាណា៖**

**ស៖** លោកបាននិយាយអំពីវិធីនៃការបង្រៀនគឺ វៃរហ័ស ឈ្នះរហ័ស តើលោកអភិវឌ្ឍន៍នូវវិធីសាស្ត្រនេះ ដោយខ្លួនឯងឬ?

[១០:០៦:០១]

**ឆ៖** ពាក្យនេះមិនមែនជាៗពាក្យខ្ញុំទេ ជាពាក្យរបស់ថ្នាក់ដឹកនាំ ។ ប៉ុន្តែ ខ្ញុំមិនចាំថា ពាក្យនេះខ្ញុំបានទទួលឮពីឆ្នាំហើយ តាមរយៈទង់បដិវត្តន៍ ឬតាមរយៈការអប់រំទេ ។

**ស៖** តើលោកបានប្រើឃ្លានេះ ដាក់ជាឧបករណ៍ក្នុងការបង្រៀនឬ?

**ឆ៖** មាគ៌ាសកម្មភាពរបស់ខ្ញុំខាងបង្រៀនៗវាស្ថិតនៅក្នុងពាក្យស្លោកនេះ ។

**ស៖** តើលោកនឹងរាយការណ៍អំពីការប្រើវិធីនេះដល់ទៅថ្នាក់លើរបស់លោកឬ?

**ឆ៖** វិធីនេះ យុទ្ធវិធីនេះ យើងរៀនពីគេ យើងអនុវត្តតាមគេ ដូច្នេះមិនបាច់វាយការណ៍ទេ ។

**ស៖** ទៅតាមការយល់ដឹងរបស់លោក ថាតើវិធីនេះត្រូវបានគេប្រើនៅឯទីកន្លែងផ្សេងទៀតដែរឬទេ?

**ឆ៖** ខ្ញុំអត់ប្រើវិធីនេះពាសវាលពាសកាលក្រៅពីការងារអប់រំទេ ព្រោះខ្ញុំជាបុគ្គលតែមួយនាក់គត់នៅក្នុងមន្ទីរស-២១ ដែលទទួលភារៈខាងអប់រំ ។

**ស៖** តើលោកត្រូវចំណាយអស់រយៈពេលប៉ុន្មានក្នុងការបណ្តុះបណ្តាល? តើពេលវេលាដែលលោកចំណាយសម្រាប់ការបណ្តុះបណ្តាលហ្នឹង វាស៊ីពេលប៉ុន្មានបើប្រៀបធៀបទៅនឹងសកម្មផ្សេងៗដែលលោកធ្វើនោះ?

**ឆ៖** សូមបញ្ជាក់ឲ្យច្បាស់មក *ដុងឡុងស្បង់ដឺហ្វូមីស្យុង* ហ្នឹង ខ្ញុំមិនដឹងជាឆ្លើយពីរឿងអីទេ ។

**អ្នកបកប្រែ៖**

សុំឲ្យជនជាប់ចោទនិយាយម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្កេកអ៊ាវ ឆ្លើយនឹងសំណួរមិញឲ្យបានច្បាស់ ពីព្រោះអ្នកបកប្រែ បកអត់បាន ។ ស្ដាប់មិនបាន ស្ដាប់មិនទាន់ លោកឆ្លើយអម្បាញ់មិញ នូវសំណួរចុងក្រោយនេះ ។

**ជនជាប់ចោទ៖**

ខ្ញុំសូមអ្នកស្រីមេធាវីបញ្ជាក់ឲ្យច្បាស់ពីសំណួររបស់អ្នកស្រី ពីព្រោះខ្ញុំចាប់មិនបាន ។

**សួរដោយលោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

**ស៖** ខ្ញុំនឹងដាក់សំណួរម្ដងទៀត ថាតើការបង្រៀន និងសកម្មភាពអប់រំរបស់លោក ដែលលោកធ្វើសម្រាប់បុគ្គលរបស់លោកហ្នឹង តើការងារហ្នឹងវាស៊ីពេលច្រើនជាងគេ បើប្រៀបធៀបទៅនឹងការផ្សេងៗទៀតរបស់លោកឬ?

[១០:១០:១០]

**ឆ៖** នៅស-២១ ការងារជាសំខាន់របស់ខ្ញុំមានបី ។ ទីមួយ គឺបង្រៀននេះឯង ។ ទីពីរ គឺបញ្ជូនចម្លើយសារភាពទៅលើ ។ រយៈកាលដំបូងខ្ញុំខំចារណាស់ដល់ក្រោយមកខ្ញុំមិនសូវបានគិតគូរពីរឿងចារប៉ុន្មានទេ សេចក្ដីសារភាព ។ ហើយទីបី គ្រប់គ្រងគ្រប់បញ្ហាជារួម ពីលើគេ ។

**ស៖** បើសិនជាខ្ញុំយល់លោកត្រឹមត្រូវនោះ មានន័យថា លោកមានភារកិច្ចសំខាន់ពីរ ដែលមានន័យថា ស៊ីពេលពីរភាគបី នៃការងាររបស់លោក ។ មានន័យថា គឺការងារបណ្តុះបណ្តាលមួយ ហើយនិងការបញ្ជូនចម្លើយសារភាពទៅថ្នាក់លើ ។ តើលោកអាចបញ្ជាក់ត្រង់ចំណុចនេះបានទេ?

**ឆ៖** ត្រូវហើយ ខ្ញុំទទួលតាមហ្នឹង ។

**ស៖** សូមអរគុណ ។ ដូច្នេះ ខ្ញុំអាចយល់ថា ភារកិច្ចរបស់លោកសំខាន់បំផុត គឺទាក់ទងទៅនឹងបញ្ហានយោបាយជាងបញ្ហាបច្ចេកទេស ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំតាមពិតមែន វាមានលក្ខណៈនយោបាយ ជាជាងបច្ចេកទេស ។

**ស៖** សូមអរគុណ ។ តើលោកគិតថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាគឺជាគោលនយោបាយល្អសម្រាប់ប្រទេសកម្ពុជាឬ?

**ឆ៖** និយាយបោកម៉េចបាន ជានយោបាយឧក្រិដ្ឋ មហាឧក្រិដ្ឋ ឧក្រិដ្ឋជាងពួកអាក្រុមបួននាក់នៅប្រទេសចិនទៅទៀត ។

**ស៖** សូមអរគុណ ។ ឥឡូវ មានន័យថា លោកបាននិយាយឥឡូវនេះមានន័យថា នៅស្ថានភាពបច្ចុប្បន្ននេះ ឬក៏នោះគឺជាអ្វីដែលលោកបានជឿនៅសម័យកាលនោះ?

**ឆ៖** ការយល់ដឹងបច្ចុប្បន្ននេះនាំឲ្យខ្ញុំនិយាយបែបនេះ ។ ជំនាន់នោះ ខ្ញុំគ្រាន់តែចាប់អារម្មណ៍ថាការកាប់សម្លាប់នេះរាលដាលណាស់ ក៏ប៉ុន្តែ ខ្ញុំជាប៉ូលិស រដ្ឋាភិបាលគេទទួលខុសត្រូវចំពោះមុខច្បាប់ជាតិ និងអន្តរជាតិចុះ ។ នេះជំនាន់នុ៎ង ។

**លោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

ខ្ញុំបានបញ្ចប់សំណួររបស់ខ្ញុំហើយ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមអញ្ជើញមេធាវីក្រុមបួន មានសំណួរទេ? បើសិនជាមានសំណួរ សូមអញ្ជើញ ។

[១០:១៤:៣៨]

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទមានសំណួរដើម្បីសួរទៅលើលោក កាំង ហ្គេកអ៊ាវ ហៅឌុច ខ្លះថែមទៀត ហើយខ្ញុំបាទក៏មិនព្យាយាមអូសបន្លាយនាំឲ្យមានការសួរទាក់ទងច្រំដែលដែរបាទ ។

ជាដំបូង ខ្ញុំបាទសូមគោរពលោកប្រធាន និងលោក លោកស្រីសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាទីគោរព ។ ទាក់ទងនៅក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ប្រសិនជាមានសំណួរខ្លះដែលជាន់ ឬក៏ស្រដៀងគ្នា ខ្ញុំបាទបានលើកហើយថាមិនព្យាយាមនិយាយច្រំដែលទេ តែកន្លែងខ្លះខ្ញុំបាទមិនទាន់ច្បាស់ ខ្ញុំសុំឲ្យលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច លោកឆ្លើយទៅនឹងសំណួរខ្ញុំដូចតទៅនេះ៖

**ស៖** ពីម្សិលមិញលោកបានជម្រាបលោកប្រធាននិងអង្គសវនាការរួចហើយ ទាក់ទងជាមួយនឹងការប្រជុំ ឬបង្រៀន ឬអប់រំបុគ្គលិក ឬកម្មាភិបាលនៅក្នុងមន្ទីរស-២១ ។ ហើយលោកបានជម្រាបអង្គសវនាការផងដែរថា លោកចិត្តទុកដាក់ខ្លាំងក្នុងការប្រើប្រាស់ ឬការអនុវត្តតាមលក្ខន្តិកៈបក្សកុម្មុយ-នីស្តកម្ពុជា ។ បើខ្ញុំមិនច្រឡំទេ លោកបានមានប្រសាសន៍អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំនិយាយមែន ហើយនិយាយហូរហែ ។

**ស៖** សូមអរគុណ ។ ក្រៅពីលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងមានឯកសារទង់បដិវត្តន៍មានលេខពិសេស មានឯកសារយុវជន យុវនារី មានលិខិត ឬសេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួនដែលលោកតែងតែលើកឡើង ដែលមានឯកសារចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ តើមានឯកសាររបស់គណៈមជ្ឈិមបក្សផ្សេងៗទៀត ដែលចេញជាបន្តបន្ទាប់ លោកយកមកសិក្សាផងដែរឬទេ?

**ឆ៖** អរគុណលោក គឹមសួន ដែលលើកបញ្ហានេះ ។ សូមបញ្ជាក់ថា កាលនោះមានតែឯកសារលក្ខន្តិកៈបក្សជាឯកសារស្នូល ហើយធំបំផុត ។ ចំណែកទង់បដិវត្តន៍ហើយនិងយុវជនបដិវត្តន៍ ជាឯកសារប្រើនៅក្នុងផ្ទៃក្នុងបក្សមែន ក៏ប៉ុន្តែ វាមិនមែនជាគ្រឹះមូលដ្ឋានទេ ។ ចំណែក រដ្ឋធម្មនុញ្ញខ្ញុំបានជម្រាបលោកចៅក្រមរួចហើយ ថាវាជារបាំង រនាំងដាក់លម្អប៉ុណ្ណឹងឯង ខ្ញុំមិនបានយកចិត្តទុកដាក់អានទេ ។ ហើយសូមបញ្ជាក់ថា ក្នុងឋានៈខ្ញុំជាបក្ខជន កម្មាភិបាលមធ្យម ជាបក្ខជនពេញសិទ្ធិ ជំនាន់នុំងខ្ញុំអត់ឃើញទាល់តែសោះ សេចក្តីសម្រេចចិត្តផ្សេងៗរបស់អចិន្ត្រៃយ៍ ជាពិសេសសេចក្តីសម្រេចចិត្តថ្ងៃទី៣០ មីនា ១៩៨៦ ។ ខ្ញុំឃើញនឹងនៅ អ.វ.ត.ក យើងនេះ ដែលលោកចៅក្រមស៊ើបអង្កេតប្រគល់មកឲ្យខ្ញុំអាន ដើម្បីវិភាគ ហើយឆ្លើយនឹងសំណួររបស់លោកប៉ុណ្ណឹង ។ ឯចំណែកឯកសារថ្ងៃ៩ តុលា ខ្ញុំទើបនឹងឃើញមកដល់នេះទេ និងជាឯកសារសំខាន់មួយទៀត ដែលខ្ញុំតែងតែយោងទៅដល់ ។ ខ្ញុំទើបនឹងឃើញមកដល់យើង អង្គជំនុំជម្រះសាលាដំបូងយើងនេះទេ ។

[១០:១៩:០៩]

ដូច្នេះសរុបមក គ្រឹះសម្រាប់ខ្ញុំរៀនសូត្រ ហើយការពារអាយុជីវិត ធ្វើម៉េចកុំឲ្យជ្រុះ កុំឲ្យធ្លាក់ គឺលក្ខន្តិកៈបក្ស ។ សូមចប់ ។

**ស៖** សូមអរគុណ ។ សំណួរតទៅទៀត ការបង្រៀន ឬការអប់រំកម្មាភិបាលនៅក្នុងបន្ទុកនៃមន្ទីរស-២១ ពីម្សិលមិញលោកបានជម្រាបអង្គសវនាការនិយាយអំពីការប្រជុំ ឬការរៀនសូត្រទោះមានបួនប្រាំនាក់ក៏ដោយ ក៏លោកបើកការប្រជុំនៅកន្លែងមួយដែលលោកតែងតែប្រើមីក្រូហ្វូននិយាយជានិច្ចនោះ ។ តើការអប់រំជាប្រចាំ ខ្ញុំមិននិយាយអំពីរឿងថា ឆក់ឱកាស ដូចលោករៀបរាប់អម្បាញ់មិញនោះទេ ។ ច្រើនតែអប់រំ ឬប្រជុំនិយាយអំពីរឿងអ្វីជាសំខាន់ ?

**ឆ៖** រឿងនេះខ្ញុំដូចជាឆ្លើយហួរហែហើយ ខ្ញុំសូមទុកពេលជូនលោកពិចារណាលើចម្លើយរបស់ខ្ញុំកន្លងរួចមកហើយ សុំទោស ។

**ស៖** សូមអរគុណ ។ អម្បាញ់មិញលោកបានជម្រាបអង្គសវនាការអំពីមនុស្សដប់បួននាក់ ហើយថាមានតែ សុន សេន ជាលោកគ្រូរបស់លោកទេដែលមានតួនាទី ឬមានអំណាចមកលើមន្ទីរស-២១ ។ ក្នុងនេះដោយសារខ្ញុំបាទចង់ឲ្យដឹង ឲ្យឮទាំងអស់គ្នា ហើយក៏មានពាក្យពេចន៍ជាភាសាខ្មែរជាច្រើននិយាយអំពីតើពាក្យថា “អង្គការ” ពាក្យថា “មជ្ឈិមបក្ស” ពាក្យថា “គណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍” វាមានន័យដូចគ្នា ឬខុសគ្នាដូចម្ដេច និងមានអំណាចនិងបង្គាប់ឲ្យធ្វើដូច ម្ដេច?

**ឆ៖** អរគុណខ្ញុំសូមជម្រាបឲ្យច្បាស់លាស់ម្ដងទៀត ។ គណៈកម្មាធិការមជ្ឈិមមានបួនថ្នាក់ ។ ថ្នាក់ក្រោមជាងគេបំផុតគេហៅថា ជំនួយការមជ្ឈិម ។ ពួកនេះមានសិទ្ធិទៅរៀងសូត្រជាមួយនឹងគេ ។ តែដល់មហាសន្និបាតមជ្ឈិមមិនមានសិទ្ធិមានមតិទេ ។

[១០:២២:១៦]

ទីពីរ សុំទោសមុននឹងបន្តទៅទៀត ខ្ញុំសុំនិយាយ មួយម៉ាត់ពីរ ។ អ្នកដែលស្ថិតនៅក្នុងជំនួយការមជ្ឈិមនេះ បុគ្គលទីមួយគឺ ឈឹម សំអោក ហៅ ប៉ង់ ហើយក្នុងនោះក៏មាន ស៊ូ ម៉េត ហើយនិង មាស មុត ។ គ្នាគេប៉ុន្មាននាក់ខ្ញុំក្ដាប់មិនបានទេ មិនមានឯកសារអីសម្រាប់ដល់ខ្ញុំទេ ខ្ពស់ពីជំនួយការមជ្ឈិមទៅវាមានសមាជិកមជ្ឈិមត្រៀមៗ សមាជិកមជ្ឈិមត្រៀមធំដែរ មានអំណាចធំដែរ ពេលមហាសន្និបាតបក្សមួយៗពួកនេះទៅរៀនជាមួយនឹងគេមានសិទ្ធិមានមតិប៉ុណ្ណឹង សិទ្ធិពីរហ្នឹង ។ សមាជិកមជ្ឈិមត្រៀមដែលខ្ញុំស្គាល់ម្នាក់ គឺបង៨១ អនុលេខាគណៈកម្មាធិការសេនាធិការ ។ ខ្ពស់ជាងនេះទៅទៀត សមាជិក

មជ្ឈិមពេញសិទ្ធិ ។ ពួកនេះមានសិទ្ធិទៅរៀននឹងគេ មានសិទ្ធិមានមតិ ហើយមានសិទ្ធិរួមមតិសម្រេច បោះឆ្នោតសម្រេចមាគ៌ាតូចធំរបស់បក្ស ។

ខ្ញុំសូមលើកសមាជិកមជ្ឈិមពេញសិទ្ធិពីរបីនាក់ដែលស្លាប់ទៅចុះ ។ បង ពក លេខាភូមិភាគឧត្តរនេះជា សមាជិកមជ្ឈិមពេញសិទ្ធិម្នាក់ ។ កុយ ធួន ដែលស្លាប់ទៅនេះក៏ជាសមាជិកមជ្ឈិមពេញសិទ្ធិម្នាក់ដែរ ។ ខ្ពស់ជាងនោះទៅទៀត គឺអចិន្ត្រៃយ៍មជ្ឈិម ។ ពីសន្និបាតមួយទៅសន្និបាតមួយអ្នកទទួលខុសត្រូវក្នុងការអនុវត្តមាគ៌ាហ្នឹងគឺអចិន្ត្រៃយ៍មជ្ឈិម មានសិទ្ធិសម្រេចគ្រប់កិច្ចការទៅតាមមហាសន្និបាតបក្សកំណត់ ។ ក្នុងអចិន្ត្រៃយ៍មជ្ឈិមនេះ មេខ្ញុំលោកគ្រូ សុន សេន ជាបុគ្គលទីប្រាំពីរ ។ បងប៉ុល ជាបុគ្គលទីមួយ ។ នេះខ្ញុំសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង ។ អំណាចធំបំផុតនៅលើអចិន្ត្រៃយ៍មជ្ឈិម ។

**ស៖** សូមអរគុណ ។ អំមិញលោកបានរៀបរាប់ទាក់ទងជាមួយមជ្ឈិម ឬមជ្ឈិមបក្ស?

**ឆ៖** ខ្ញុំឆ្លើយមិនទាន់ចប់សំណួរលោកសួរខ្ញុំអ្វីដែលហៅថា "អង្គការ" ។ សម្រាប់ ស-២១ អ្នកដែលចេញតំណាងអចិន្ត្រៃយ៍មកដឹកនាំ ខ្ញុំហៅថាអង្គការហើយ ។ សុន សេន ខ្ញុំហៅគាត់ថា អង្គការហើយ ។ ក៏ប៉ុន្តែ សុន សេន ហៅ បងប៉ុល ហៅអង្គការ ពីក្រោយខ្នង ។ ខ្ញុំក៏ហៅមេខ្ញុំលោកគ្រូ សុន សេន ពីក្រោយខ្នងអង្គការ ។

**ស៖** សូមអរគុណ ។ នៅក្នុងតួនាទីរបស់លោកមុនពេលឡើងធ្វើជាប្រធានស-២១ តាមដែលលោកបានរៀបរាប់ពីមុនមក គឺមានការរៀនសូត្រជាមួយលោក សុន សេន នៅម្ដុំស្ថានីយ៍រថភ្លើងជាមួយនិងសមមិត្ត អ៊ិន លន ហៅ ណាត អានេះខ្ញុំបញ្ជាក់ឡើងវិញបន្តិចអ៊ីចឹងមែនទេ?

**ឆ៖** ខុសហើយមិនមែនទេ ។ ខ្ញុំមកស្នាក់នៅស្ថានីយ៍រថភ្លើង ហើយមេហៅខ្ញុំទៅធ្វើការនៅទុំងអត់រៀនទេ ដើម្បីចាត់តាំងស-២១ ប្រើពេលប្រហែលជាដប់ទៅដប់ប្រាំមីនុតប៉ុណ្ណឹង អត់រៀនទេ ។ ទៅជួបហ្នឹងដើម្បីតែឧទ្ទេសនាមការកកើតរបស់ស-២១។

[១០:២៦:៥០]

**ស៖** សូមអរគុណ ។ តើការរៀបចំ ឬការចេញជាគំនិតបង្កើតមន្ទីរស-២១ នេះ តាមលោករៀបរាប់អម្បាញ់មិញ គឺសេចក្ដីសម្រេចទាំងឡាយ គឺចេញពីសមាជិកបក្សមជ្ឈិម ។ អ៊ីចឹងនៅក្នុងនេះ សុន សេន បានហៅលោកទៅជួប ដែលលោកនិយាយថា ប្រហែលជាប្អូនដប់នាទីនេះ ជាគំនិតរបស់ សុន សេន ដែលណែនាំលោក ឬក៏ជាសេចក្ដីសម្រេចរបស់សមាជិកមជ្ឈិមបក្ស?

**ឆ៖** សូមជម្រាបបញ្ជាក់ ខ្ញុំសូមមានមតិលើការយល់ដឹងរបស់លោកបន្តិចចុះ ។ លោកនៅច្របូកច្របល់ក្នុងអារម្មណ៍នៅឡើយ ស្អីមជ្ឈិម? ខ្ញុំសូមបញ្ជាក់ថា ការដែលលោកគ្រូ សុន សេន ហៅខ្ញុំ និង ណាត ទៅជួបនេះ ខ្ញុំជឿថា វាចេញមកពីសេចក្ដីសម្រេចចិត្តរបស់ បងប៉ុល មេធំបំផុតនោះ ។ ដូច្នេះ ចេញមកពីសេចក្ដីសម្រេចចិត្តរបស់លេខាបក្ស ។

**ស៖** សូមអរគុណ ។ នៅក្នុងមន្ទីរស-២១ ក្រោយពេលដែលឈ្មោះ ណាត ជាប្រធានមុន ចេញទៅ គឺលោកទទួលបន្ទុកជាប្រធានបន្ត ។ ពីម្សិលមិញលោកបាននិយាយអំពីឈ្មោះ ហ៊ុយ ខ្ញុំមិន ច្បាស់ទេ ថា ហ៊ុយ នោះ ហ៊ុយ ស្រែ ឬ ហ៊ឹម ហ៊ុយ សូមបញ្ជាក់កន្លែងហ្នឹងបន្តិច?

**ឆ៖** សូមអរគុណដែលលោកបានសួរខ្ញុំ ។ មិត្តហ៊ុយ, ហ៊ឹម ហ៊ុយ នេះ គ្នាកាលណោះនៅជាអនុ សេនាតូចទេ ។ ឯចំណែក នុន ហ៊ុយ គឺ ហ៊ុយ ស្រែ បាននៅក្នុងគណៈកម្មាធិការជាមួយនឹងខ្ញុំ នុន ហ៊ុយ (ប្រកប នុន) ។

**ស៖** សូមអរគុណ ។ ជាទូទៅ នៅក្នុងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាធិបតេយ្យនៅពេលនោះកម្មាភិបាលកម្រិតណា? ឧទាហរណ៍ដូចលោកផ្ទាល់ លោកតែងតែនិយាយថា ជាកម្មាភិបាលមធ្យម តើមានជាការកំណត់ ឬសម្រេចជាឯកសាររបស់ថ្នាក់លើរបស់លោក កំណត់ថាកម្មាភិបាលនៅក្នុងមន្ទីរស-២១ កម្រិតណាខ្លះដែលមានសិទ្ធិទៅចូលរួមប្រជុំជាមួយនឹង សុន សេន ឬជាមួយនឹងគណៈមជ្ឈិមបក្ស?

**ឆ៖** អ្នកដែលទៅចូលរួមប្រជុំរៀនសូត្រប្រចាំឆ្នាំជាមួយមជ្ឈិមបក្សទាល់តែមនុស្សចាប់ពីជំនួយការមជ្ឈិមឡើងទៅ ដូចខ្ញុំរាប់រៀបអំមិញ ។ ឯចំណែកខ្ញុំអត់បានចូលមជ្ឈិមនឹងគេ ជាបក្សជនពេញសិទ្ធិ តែមិនទាន់បានចូលមជ្ឈិម គេហៅថាកម្មាភិបាលមធ្យម ។ កម្មាភិបាលមធ្យមនេះ ខ្ញុំសូមរាប់ឈ្មោះខ្លះទៅចុះ ។ ខ្ញុំក៏ជាកម្មាភិបាលមធ្យម ។ ណាត ក៏ជាកម្មាភិបាលមធ្យម ។ អៀង ធីរិទ្ធ នេះក៏នៅតែជាកម្មាភិបាលមធ្យម ព្រោះមិនទាន់បានចូលមជ្ឈិម ។

[១០:៣០:៥៣]

ដោយឡែក ឈឹម សំអោក ហៅ ប៉ង់ គេទៅជា សមាជិកមជ្ឈិមហើយ ។ ស៊ូ ម៉េត ក៏ទៅជាសមាជិកមជ្ឈិមដែរ ។ មាស មុត ក៏ទៅជាសមាជិកមជ្ឈិមដែរ ។ នេះខ្ញុំញែកឲ្យដាច់ពីគ្នា ដែលគេហៅថាកម្មាភិបាលមធ្យម គឺអ្នកដែលមិនទាន់បានចូលមជ្ឈិម ។ ឯចំណែក កម្មាភិបាលមធ្យមខ្ញុំទៅធ្វើការជាប់ជាមួយលោកគ្រូ សុន សេន មិនមែនដោយសារខ្ញុំមានតួនាទីជាមជ្ឈិមទេ ដោយសារអំណាចនៃ

មាត្រា៨ នៃលក្ខន្តិកៈបក្ស គេចាត់តាំងឲ្យខ្ញុំនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អចិន្ត្រៃយ៍ ។ ដូច្នេះ មានតែខ្ញុំម្នាក់ទេ ស-២១ ដែលចេញទៅជួប ។ កាលដែលខ្ញុំធ្វើជា អនុប្រធានកាន់កាប់កិច្ចការពេញកណ្តាប់ដៃជាអនុប្រធានមេហៅខ្ញុំទៅទាំងពីរនាក់ ខ្ញុំក៏ទៅ ណាត ក៏ទៅ ។ មេមិនដែលហៅ ណាត ម្នាក់ឯងទេ ហៅខ្ញុំម្នាក់ឯង ។ ដល់ពេល ណាត ចេញទៅមេមិនដែល មិត្តហ៊ី ទៅជាមួយទេ ហៅតែខ្ញុំទៅ ។ នេះការងារខាងសន្តិបាល ។

**ស៖** សូមអរគុណ។ ខ្ញុំសួរចូលមកក្នុង ទាក់ទងនឹងមន្ទីរស-២១ ដដែលលោកបានរៀបរាប់ច្រើនហើយ ប៉ុន្តែខ្ញុំចង់ឲ្យលោកជម្រាបក្នុងអង្គសវនាការបន្តិច គឺខ្ញុំបានយល់ បានដឹង បានឮហើយលោកថាមនុស្សដែលចាប់បញ្ជូនមកស-២១ ចាត់ទុកថាស្លាប់រួចទៅហើយនោះ ។ ក៏ប៉ុន្តែ ទាក់ទងនឹងការបញ្ជូនមនុស្សមកពីគ្រប់មជ្ឈដ្ឋានមកមន្ទីរស-២១ លោកថា ជួនកាលមានបញ្ជូនទាំងឯកសារមកជាមួយ ដូចលោកព្រះរាជអាជ្ញាសួរពីម្សិលមិញទាក់ទងមនុស្សបញ្ជូនពីប្រទេសថៃមកប្រទេសកម្ពុជាវិញ ប្រហែលជាមកទាំងឯកសារផងដែរ បើខ្ញុំមិនច្រឡំទេ តើលោកថាអាចមានអ៊ីចឹងដែរឬទេ?

**ឆ៖** អរគុណលោក គឹមស្រួន ។ លោកមានប្រសាសន៍ឯកសារវាទូលាយណាស់ ។ បញ្ជីៗឈ្មោះម្សិលមិញដែលខ្ញុំឃើញចំណារខ្ញុំនៅលើបញ្ជីឈ្មោះ ។ បញ្ជីៗឈ្មោះ វាខុសពីឯកសារ ។

ដូច្នេះ រឿងនេះខ្ញុំមិនអាចនិយាយបានថា គ្រប់មនុស្សដែលបញ្ជូនមកវាសុទ្ធតែមានបញ្ជីឈ្មោះទេ ។ ឥឡូវ វាទាល់តែឃើញបញ្ជីហ្នឹងទៅ យើងនិយាយគ្នាមួយៗ គ្រប់បញ្ជីទៅវាស្រួលជាង ។

**ស៖** សូមអរគុណ ។ សូមលោករៀបរាប់ ឬក៏បញ្ជាក់បន្តិច តាមគោលការណ៍ ឬក៏មាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យពាក្យថា “ខ្មាំង” តើជាទូទៅការយល់ដឹងរបស់លោកតើចែកចេញជាប៉ុន្មានយ៉ាង? ខ្ញុំមិនសួរថាតើច្បាស់លាស់មានឯកសារ ឬក៏សេចក្តីសម្រេចទេ? ព្រោះថា ខ្ញុំសូមពន្យល់បន្តិច “ខ្មាំង” តើមានជាខ្មាំងសតិអារម្មណ៍ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ខ្មាំងក្នុងជួរក្រៅជួរជាដើម អ៊ីចឹងខ្ញុំសូមឲ្យលោកបញ្ជាក់បន្តិចថា ខ្មាំងនោះរៀបរាប់បញ្ចូលពីណាខ្លះ?

[១០:៣៤:៥៤]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ពាក្យខ្មាំងសតិអារម្មណ៍នេះ មានប្រើយូរហើយ ប៉ុន្តែ គេមិនសម្លាប់មនុស្សដែលមានខ្មាំងសតិអារម្មណ៍នៅក្នុងខ្លួនទេ ។ គេអប់រំឲ្យមនុស្សនោះមានសតិអារម្មណ៍វណ្ណៈអធនឡើង ឆ្លងកាត់ការវាតត្បាតឆ្នាំ១៩៦៨ ប៉ុល ពត គាត់លើកបញ្ហាហ្នឹង ប្រយុទ្ធតស៊ូនឹងខ្មាំងក្នុងសតិអារម្មណ៍ ទើបចែងជាចម្រៀងមួយ ។ ខ្មាំងសតិអារម្មណ៍មានប្រើយូរហើយ។

ឯខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង វាឃើញក្រោយ១៧មេសា ជាពិសេសក្រោយថ្ងៃ៣០ មីនា ១៩៧៦នេះ បើតាមខ្ញុំចាំ ខ្ញុំសូមវិភាគព្រាវៗអ៊ីចឹងសិន ហើយទុកឱកាស ទុកសិទ្ធិកែប្រែពេលវេលានេះក្រោយ ។

ឯចំណែក ខ្មាំងវណ្ណៈ ដែលជារបបសេដ្ឋកិច្ច ដែលជារបបនយោបាយ អ្នកណាក៏ឃើញច្បាស់ដែរ ។ បក្សកុម្មុយនីស្តកម្ពុជា គេកម្ទេច គេជម្លៀស គេអីៗនៅក្រោយ១៧ មេសា ។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណេះ ។ ហើយទន្ទឹមនេះ ក៏ខ្ញុំសូមជូនយោបល់លោក គឹម សួន មួយម៉ាត់ សូមអធ្យាស្រ័យ ។ បក្សកុម្មុយនីស្តកម្ពុជា អត់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យទេ ។ កម្ពុជាប្រជាធិបតេយ្យជារដ្ឋាភិបាលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សនេះ ។ ដូច្នេះ បក្សផ្សេងៗ រដ្ឋាភិបាល គេគិតផ្សេង ។ អានេះជាពាក្យលោកប្រើទេ ខ្ញុំសូមជូនប៉ុណ្ណឹង ។ សូមទោស ។

**ស៖** សូមអរគុណ ។ អំមិញលោកបានជម្រាបសាថ្មីឡើងវិញហើយ ទាក់ទងអំពីគោលការណ៍តស៊ូវណ្ណៈ ។ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកតែងតែបាននិយាយថា ប៉ុល ពត បានប្តូរក្រឡាប់ចាក់ខុសពីគោលការណ៍មុនឆ្នាំ១៩៧៥ ។ នេះខ្ញុំគ្រាន់តែរំឭកឡើងវិញបន្តិច ។ ការតស៊ូវណ្ណៈអធន ឬតស៊ូវណ្ណៈដែលលោកបានរៀបរាប់អំពីវណ្ណៈកម្មករ វណ្ណៈកសិករ ។ ក្នុងនេះ ក្នុងការចាប់មនុស្សបញ្ជូនពីប្រភពនានា ចូលមកមន្ទីរស-២១ ចាត់ទុកជាការវាយកម្ទេចខ្មាំងវណ្ណៈដែរឬទេ?

**ឆ៖** ខ្មាំងវណ្ណៈ វាកំណត់ជារួម ។ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងក៏គេហៅខ្មាំងវណ្ណៈដែរ ។ ប៉ុន្តែវាគ្រាន់តែមានធាតុជាខ្មាំង ប៉ុន្តែវាបន្លំរូបភាពនៅក្នុងជួរ និយាយមួយម៉ាត់ វានៅតែខ្មាំងវណ្ណៈ ។ នេះបើតាមលោកទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជាជំនាន់នោះ ។

[១០:៣៩:០១]

**ស៖** សូមអរគុណ ។ ទាក់ទងអំពីការ ខ្ញុំសួរបន្ទាប់ពីដែលលោកបានជម្រាបអង្គសវនាការអម្បាញ់មិញ មន្ទីរស-២១ មានវត្ថុបំណងពីរ ។ ទីមួយ យកមនុស្សដែលបញ្ជូនមក គឺដើម្បីសួរយកចម្លើយ ហើយទីពីរ តាមចាប់មនុស្សតាមការឆ្លើយរបស់អ្នកទោសដែលសារភាព ។ នេះខ្ញុំសូមបញ្ជាក់បន្តិច អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ត្រូវហើយ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងតើការ ក្នុងការដឹកនាំរបស់លោក ឬក៏ក្នុងនាមលោកជាប្រធានមន្ទីរស-២១ ការរៀបចំរចនាសម្ព័ន្ធ ឬរៀបចំវិធីសាស្ត្រនៃការសាកសួរ ដែលលោកតែងតែនិយាយថា ទៅដល់នោះ គេហៅថាអ្នកទោសហើយហ្នឹង និងការយកទៅសម្លាប់ទោះនោះជុំវិញមន្ទីរស-២១ ឬនៅ

មន្ទីរបឹងជើងឯកក៏ដោយ តើជាគោលការណ៍ដែរ ឬទេ របៀបនៃការសម្លាប់មនុស្ស?

**ឆ៖** របៀបនៃការសម្លាប់មនុស្ស ខ្ញុំបានជម្រាបស្មើរតែពេញលេញ ជូនលោកចៅក្រម ធូ មណី ពីលើកមុន ។ ឥឡូវនេះ ខ្ញុំសូមបញ្ជាក់ខ្លីថា ពេលដែលចាប់ផ្ដើមកកើតស-២១ ណាត សួរខ្ញុំថា នៅឯមន្ទីរ១៣ហ្នឹង គេសម្លាប់ម៉េច ឌុច? ខ្ញុំឆ្លើយថា គេវ៉ៃនឹងគល់ឬស្សី ។ ណាត គាត់ពេញចិត្ត នឹងអាការចាក់ដោយកាំបិតស្នៀតនេះ ត្រង់នេះ ឲ្យដាច់សរសៃឈាមក្រហមធំ ។ គាត់បញ្ជាឲ្យស-២១ ដែលកាន់កាប់ជាកងពិសេសស្រាប់ អនុវត្តរបៀបនេះ ។

នៅពេលដែលបក្សឲ្យខ្ញុំ ឲ្យស-២១ កម្ទេច នង សួន ហើយនិង សួស នៅ ហៅ ឈួក នៅពេលម៉ោងប្រាំភ្លឺ បក្សឲ្យខ្ញុំទៅមើល តើគេកម្ទេចមែន ឬមិនមែន? មែន គេចាក់កាំបិត ។ ដល់ក្រោយមក ខ្ញុំឮមិត្តហ៊ុយ, ហ៊ឹម ហ៊ុយ និយាយរឿងអំពីគេវ៉ៃ ក៏ខ្ញុំអាចជឿថាប្រហែលជាមានវិធីប្តូរមកអ៊ីចឹង នេះជារឿងពិត ។ ក៏ប៉ុន្តែ ដល់ក្នុងការអនុវត្តជាក់ស្តែង វាមានរឿងប្លែកបន្តិចទៅទៀត ។ អ្នកណាដែលបក្សភ័យបារម្ភខ្លាចស-២១ ដោះលែង សម្លាប់ហើយ ឲ្យថតរូបទៅទៀត ។ ដូច្នេះ អ្នកណាត្រូវថត បក្សបញ្ជាមក ។ ឧទាហរណ៍ លី ផែល ឧទាហរណ៍ មិត្តប៊ុន នៅខាងស្រែអំបិល អង្គាលហ្នឹង ឈ្មោះនេះថ្មី ។ ឧទាហរណ៍ វ៉ន វេត, ឆាយ គឹមហ៊, អ៊ិន លន ហៅ ណាត អតីតប្រធានស-២១ នេះត្រូវតែថត ។ នេះជាយុទ្ធវិធីមួយដែលប្លែក បក្សណែនាំមកចំពោះបញ្ហានេះដោយផ្ទាល់ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ម៉ោងត្រូវសម្រាកហើយ ហើយម្យ៉ាងទៀតដោយសារ ឌីវីឌី សម្រាប់ថតរូបភាពក៏អស់ហើយដែរ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសឈប់សម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយ បន្តដំណើរការនីតិវិធីសវនាការតទៀត ។

*[សវនាការសម្រាកពីម៉ោង១១:៤៣នាទី ដល់ម៉ោង១១:០៣ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការ ។ ជាកិច្ចបន្តនេះ សូមអញ្ជើញលោកមេធាវី ហុង គឹមសួន បន្តសំណួរ ហើយតើលោកមេធាវី អាចត្រូវចំណាយពេលវេលាប៉ុន្មានទៀតទៅ ដើម្បីក្នុងការតាំងសំណួរដល់ជនជាប់ចោទ?

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទមានសំណួរប្រហែលជាប្រាំសំណួរទៀតតែប៉ុណ្ណោះ ហើយ

ខ្ញុំបាទនឹងព្យាយាមឲ្យកាន់តែខ្លីជាងនេះទៅទៀត ដើម្បីឲ្យបានបន្តនីតិវិធីឲ្យលឿនទៅមុខទៀត ។

ខ្ញុំបាទសូមបន្តសំណួររបស់ខ្ញុំបាទទាក់ទងជាមួយនឹងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្ត នៅក្នុងមន្ទីរស-២១ តទៅទៀត ។ អម្បាញ់មិញខ្ញុំបាទបានសួរមកដល់ទាក់ទងជាមួយគោលការណ៍នៃការសម្លាប់ ។ ហើយលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច លោកបានឆ្លើយហើយ ។ ហើយលោកប្រៀបធៀបអំពីការអនុវត្តនៅមន្ទីរម-១៣ ។

ដូច្នេះ សំណួររបស់ខ្ញុំដែលខ្ញុំបានសួរលោក ទាក់ទងជាមួយនឹងការអនុវត្តទៅតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា លោកថា វាជាមូលដ្ឋានគ្រឹះនៃការអនុវត្ត ។ ដោយសារខ្ញុំបានអានផងដែរ នូវលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានេះ អ្វីដែលខ្ញុំបាទចង់បានឲ្យច្បាស់នោះគឺថា គោលការណ៍ ឬការច្នៃប្រឌិត បើនិយាយអំពីការច្នៃប្រឌិតអាចថា អ្នកដែលអនុវត្តតាម គឺធ្វើយ៉ាងម៉េចឲ្យបានលទ្ធផលល្អទៅតាមថ្នាក់លើបញ្ជា ឬគោលការណ៍ដាក់ចុះមក ។ អ៊ីចឹង ទាក់ទងជាមួយនឹងការសាកសួរយកចម្លើយអ្នកទោសនៅមន្ទីរស-២១រួចហើយ ទើបត្រូវយកទៅកម្ទេច ឬយកទៅសម្លាប់តាមក្រោយនោះ ។ ខ្ញុំបាទចង់ដឹងថា មានជាគោលការណ៍ ជាមាគ៌ា ឬសេចក្តីណែនាំឲ្យធ្វើ មានន័យថា ការយកទៅសម្លាប់ចោល មានលម្អិត ឬបញ្ជាក់ច្បាស់ទេថា ប្រភេទ មនុស្សប្រភេទណាដែលត្រូវយកទៅសម្លាប់នៅជើងឯក មានការវ៉ៃនឹងត្បូងចប ឬនឹងគល់ឫស្សី ឬនឹងដំបង ឬមនុស្សប្រភេទណាត្រូវយកអារ-ក ឬមនុស្សប្រភេទណាយកទៅដុតទាំងរស់? នេះខ្ញុំសួរថា ជាគោលការណ៍ណែនាំពីលើ ឬក៏ជាការច្នៃប្រឌិតនៃអ្នកអនុវត្តខាងក្រោម?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

[១១:០៦:៥២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់សួរខ្លួនឯង លោកប្រធាន បើសិនជាយើងមិនចង់និយាយពីលម្អិត គឺទាក់ទងទៅនឹងប្រធានបទមួយទៀត ដែលចំណុចចុងក្រោយមួយទៀតទាក់ទងទៅនឹងប្រតិបត្តិការរបស់ស-២១ ។ ខ្ញុំគិតថា សំណួរនេះប្រហែលជាអាចត្រូវសួរនៅពេលក្រោយនៅពេលដែលទាក់ទងនឹងអង្គហេតុនោះ ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមអរគុណ ។ ខ្ញុំបាទសូមអរគុណលោកចៅក្រម ។ ខ្ញុំមិនឲ្យគាត់លម្អិតមកវិញ និយាយ

ឲ្យលើឧទាហរណ៍ទេ គ្រាន់ថាជាគោលការណ៍ដាក់ចុះទៅដូច្នេះដែរឬទេ? អ៊ីចឹង សូមអរគុណ។

អ៊ីចឹង ខ្ញុំបាទសូមបង្វែរសំណួររបស់ខ្ញុំបាទទៅសំណួរមួយទៀត ។ អំពីបុគ្គលិក ឬអ្នកក្រោមបង្គាប់ ឬកម្មាភិបាល ដែលទទួលបន្ទុកបន្តពីលោក តើលោកយកជាគោលការណ៍ដែលមានចែងនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឲ្យពួកគេអនុវត្តដូចចែងនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឬក៏មានការច្នៃប្រឌិតបន្តទៅទៀត?

**ឆ៖** ខ្ញុំសូមឆ្លើយថា មាគ៌ាសម្រាប់បក្សកុម្មុយនីស្តកម្ពុជា មាគ៌ានយោបាយវាមានលក្ខណៈមួយម៉ឺងម៉ាត់ មិនអាចល្មើសបាន ។ ពាក្យច្នៃប្រឌិត គំនិតដើមរស់រវើក វាបានតែចំពោះក្របខ័ណ្ឌនៃការអនុវត្តណាមួយប៉ុណ្ណោះ ។ ឧទាហរណ៍ នៅក្នុងអង្គភាពផ្សេងៗទៀតគេមិនមាន បើតាមខ្ញុំជឿ គេមិនមានការបើកវគ្គរៀនសូត្រឆក់កណ្ដៀត វ៉ៃរហ័ស ឈ្នះរហ័ស ដូចខ្ញុំទេ ។ តែខ្ញុំច្នៃប្រឌិតរឿងនេះ ដើម្បីសម្រួបតាមសំណូមពរដែលខាងលើដាក់មក។ ដូច្នេះ មាគ៌ានៅដដែល ការដំណើរការវាលក្ខណៈពិសេសរបស់ ស-២១ ត្រង់ដែលពេលបង្រៀន ឆក់បង្រៀនទៅបាន ។ ត្រង់ច្នៃប្រឌិតទៅបំផ្លើសមាគ៌ាគេទៅតាមចិត្តគំនិតយើង មិនបានទេ មាគ៌ាគឺមាគ៌ា ។ អើ! យើងនិយាយតាមបក្សកុម្មុយនីស្តកម្ពុជា គេថាម៉ឺងម៉ាត់ ក៏ប៉ុន្តែ បើយើងនិយាយតាមបែបជាទូទៅ ថាសក្ការៈ ប៉ះមិនបានទេ ប៉ះអត់បានទេរំលោភអត់បានទេ ។ នេះគឺខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរសំណួរទីបី អំមិញខ្ញុំបាទជម្រាបលោកចៅក្រមហើយ ថាខ្ញុំនឹងព្យាយាមឲ្យបានខ្លីជាងនេះ ។ ខ្ញុំដូចជាសំណួរត្រឡប់ទៅក្រោយបន្តិចវិញទាក់ទងជាមួយនឹងពាក្យថាកម្មាភិបាល ដែលមានឱកាស ឬមានសិទ្ធិទៅចូលរៀន ឬក៏ចូលទៅរួមស្ដាប់ការអប់រំណែនាំថ្នាក់មជ្ឈិមបក្ស ។ មិញលោក កាំង ហ្គេកអ៊ាវ លោកបានមានប្រសាសន៍អំពីថា ដូចលើកឧទាហរណ៍ពីឈ្មោះ ស៊ូ ម៉េត ឈ្មោះ ប៉ង់ ឈ្មោះអីជាដើម ។ ហើយលោកស្ថិតនៅក្នុងកម្មាភិបាលមធ្យម ហើយលោកបានជម្រាបអង្គសវនាការមុនសម្រាកនេះថា មានតែលោកទេដែល សុន សេន បានអនុញ្ញាត ឬបង្គាប់ ឬបញ្ជាឲ្យទៅចូលរួមប្រជុំ ឬក៏ទៅស្ដាប់ការរៀនសូត្រជាមួយថ្នាក់មជ្ឈិម ។ តើដូច្នេះមែនទេ?

[១១:១១:២០]

**ឆ៖** មួយ រៀនសូត្រ ខ្ញុំគ្មានសិទ្ធិចូលរួមនឹងគេទេ ។ ពីរ មេហៅទៅដើម្បីទទួលបទបញ្ជាអាហ្នឹង គេហៅថា ពាក្យយើងធ្លាប់ប្រើសន្និសីទការងារ ប្រជុំការងារណា ។ ប្រជុំការងារមេហៅខ្ញុំទៅមែន ប្រជុំការងារទៅដើម្បីរាយការណ៍ជូនមេថា ការងារដល់ណាហើយ មេកែតម្រូវការងារ ហើយ

បញ្ហាការងារមកថ្មីយ៉ាងហ្នឹងមែន មេហៅខ្ញុំទៅមែន ។ ដល់ទៅរៀនសូត្រ ខ្ញុំអត់មានសិទ្ធិចូលរៀននឹងគេទេ នេះសូមបញ្ជាក់ថែមប៉ុណ្ណេះ ។ ហើយខ្ញុំសូមភ្លេច សំណួរមុនពេលសម្រាក ខ្ញុំនិយាយអត់ទាន់ចប់ទេ (សុំទោស) ។

**ស៖** សូមអរគុណ ។ អ៊ីចឹង នេះភ្ជាប់នឹងសំណួរដែលលោកបានមានប្រសាសន៍ពីម្សិលមិញទាក់ទងនឹងសំណួរលោកព្រះរាជអាជ្ញា ឬលោកមេធាវីមុន ខ្ញុំក៏រៀងភាំងបន្តិចថា អម្បាញ់មិញលោកនិយាយអំពីគ្មានសិទ្ធិចូលរៀនសូត្រជាមួយថ្នាក់លើ តើការចូលរួមប្រជុំ ឬវគ្គអ្វីទៅដែលលោកថា បានជួបនឹង ប៉ុល ពត ជាមួយ អៀង ធីរិទ្ធ ជាមួយមិត្ត ហ៊ុយ នោះ?

**ឆ៖** គឺវគ្គរៀនសូត្រនយោបាយឆ្នាំ១៩៧៨ សម្រាប់កម្មាភិបាលមធ្យម១ ។ កម្មាភិបាលមជ្ឈិមគេរៀនមុនរួចទៅហើយ កម្មាភិបាលមធ្យមរៀនក្រោយមានខ្ញុំ មាន ធីរិទ្ធ មានបង យន់ យ៉ាត ជាមួយគ្នា មានមិត្តហ៊ុយ មិត្តហ៊ី ខ្ញុំជាមួយគ្នាហ្នឹង ។

**ស៖** សូមអរគុណ ។ ទាក់ទងនឹងមន្ទីរស-២១ ដដែល ដោយសារលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច លោកបានធ្វើជាប្រធានស-២១ ក្រោយសមមិត្ត ណាត ។ នេះជាសំណួរមួយដែលទាក់ទងជាមួយនឹងការដោះលែង ហើយទីពីរអំពីការបញ្ជូនទៅឱ្យរៀនសូត្រ ឬកសាងខ្លួន ។ តើលោកបានជ្រាបទេថា ក្នុងអំឡុងនៃការបង្កើតមន្ទីរស-២១ មានការដោះលែងមនុស្ស មិនចំពោះតែលោកទេ មុនលោកក៏ដោយ ដែលនិយាយអំពីស-២១ តើមានឬទេ?

[១១:១៤:១០]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! លោកប្រធាន ជម្រាបប្រសាសន៍លោកប្រធាន បញ្ហានេះខ្ញុំចង់បញ្ជាក់បន្តិចដែរ  គ្មានច្បាប់ឯណាឱ្យដោះលែងមនុស្សទេ ។ មនុស្សដែលបក្សចាប់ហើយត្រូវតែសួរចម្លើយ ហើយកម្ទេច ។ គោលការណ៍នេះម៉ឺងម៉ាត់ ។ ខ្ញុំបានជម្រាបរួចទៅហើយថា សូម្បីតែ ប៉ុល ពត ខ្លួនគាត់ ក៏អត់ទទួលសិទ្ធិដោះលែងនេះដែរ ។ បានន័យថា គាត់មានសិទ្ធិដោះលែង តែគាត់មិនប្រើសិទ្ធិនេះ ។ ខ្ញុំបានជម្រាបអង្គសវនាការ ហើយក៏ដូចជាជម្រាបលោកចៅក្រមស៊ើបអង្កេត មួយជីវិតស-២១ បក្សបញ្ជាឱ្យខ្ញុំដោះលែងមនុស្សបីនាក់ គឺពួក *ហ្វូលរ៉ូ* បញ្ហានេះខ្ញុំទុកបញ្ជាក់លើកក្រោយ ។ ម៉េចបានជាដោះលែង១? បើក្នុងករណីដែលចាំបាច់ខ្ញុំនឹងបញ្ជាក់ជូន ប៉ុន្តែ វាមាននៅក្នុងសំណុំរឿងរួចមកហើយខ្ញុំឆ្លើយជូនលោកចៅក្រមស៊ើបអង្កេត ។

ដូច្នេះ ពាក្យដែលនិយាយថា មានបញ្ជីដោះលែងនោះ ហើយ ក្រេក អេតធេសាន់ គាត់និយាយថា

វាជាឯកសារដោះបន្ទុករបស់ជនរងគ្រោះ ជាបញ្ហាធ្វើឲ្យខ្ញុំផ្អើលភ្ញាក់ ។ ខ្ញុំសូមបញ្ជាក់ថា ពេលនោះ មានសំណុំរឿងពាក្យបណ្តឹង ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់នៅនឹងដៃខ្ញុំរួចហើយ គឺដើមបណ្តឹងរដ្ឋប្បវេណី E2/47 ដើមបណ្តឹងរដ្ឋប្បវេណី E2/55 និងដើមបណ្តឹងរដ្ឋប្បវេណី E2/56 អ្នកទាំងអស់នោះសុទ្ធតែប្តឹងអំពីកូនគាត់ឈ្មោះ មិន កាន (បាត់) បងគាត់ឈ្មោះ ប៉េង ពុំ (បាត់) ក្មួយកំសត់របស់គាត់ម្នាក់ ឈ្មោះ យន់ ឌឿន (បាត់) ហើយឯកសារ ស-២១ សរសេរថាដោះលែង ខ្ញុំរង់ចាំជួបដើមបណ្តឹងរដ្ឋប្បវេណីអស់នោះ ដើម្បីថ្លាថ្លែងជម្រាបការពិតដល់គេ ចេញមុខឲ្យគេចោទប្រកាន់ខ្ញុំចុះ ខ្ញុំសូមទោសគេ ។ ដូច្នេះ គ្មានទេ រឿងដោះលែងពិតប្រាកដនុ៎ងអត់ទេ ។

ដូច្នេះ ខ្ញុំសូមតាមរយៈអង្គសវនាការនេះជម្រាប ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីនេះ សូមឲ្យលោកជឿទុកចិត្តចុះ ខ្ញុំមិនយកពាក្យពីរម៉ាត់នេះទៅលប់ ឧក្រិដ្ឋកម្មរបស់ខ្ញុំដាច់ខាត ។ ពីរម៉ាត់នេះបិទបាំងឧក្រិដ្ឋកម្មរបស់ខ្ញុំអត់បានទេ ។ ដំរីងាប់យកចង្អេរទៅ បាំងមិនបានទេ អានេះមិនមែនចង្អេរទៀត កូនស្លឹកអំពិលពីរសន្លឹកហ្នឹង ខ្ញុំបិទបាំងម៉េចមិនបាន ខ្ញុំអត់ទទួលស្គាល់ថាស-២១ មានសិទ្ធិដោះលែងទេ នេះខ្ញុំសូមនិយាយខ្លីប៉ុណ្ណេះ ។ ឯចំណែករឿងដោះលែង ខ្ញុំទុកពេលនេះនិយាយថ្ងៃក្រោយនៅពេលណាដែលលោកប្រធាន និងអង្គសវនាការតម្រូវឲ្យយើងខ្ញុំអធិប្បាយ ។

**ស៖** សូមអរគុណ ។ ជាសំណួរចុងក្រោយ ដោយសារមន្ទីរស-២១ នេះគ្របដណ្តប់ទៅលើតំបន់ព្រៃស ឬយើងហៅ ស-២៤ នៅមានឈ្មោះ ស-២៤ ។ តើវិធី ឬមានបញ្ជូនមនុស្សពី ស-២១ ទៅ អប់រំ ឬទៅកែប្រែនៅមន្ទីរស-២៤ ឬទេ?

[១១:១៨:២៥]

**ឆ៖** បញ្ហានេះខ្ញុំសូមឆ្លើយបញ្ជាក់ដូចតទៅ៖ បុគ្គលិកពេញសិទ្ធិរបស់មន្ទីរស-២១ ធ្វើខុសយើងខ្ញុំ បញ្ជូនទៅអប់រំកែប្រែនៅព្រៃស រួចសូមកុំប្រើពាក្យស-២៤ ទៀត មិនមែនជាពាក្យដែលបក្សកុម្មុយនីស្ត កម្ពុជាទទួលស្គាល់ជាផ្លូវការទេ ។ ឯកសារនៅមាន ដែលបក្សកុម្មុយនីស្តកម្ពុជាហៅមិត្ត នួន ហ៊ុយ ទៅធ្វើការជាមួយពីការបង្កបង្កើនផល មិត្ត ហ៊ុយ ចេញទៅតាងនាម ស-២១ ។ ដូច្នេះមនុស្សជាបុគ្គលិកពិតជាយើងខ្ញុំបានបញ្ជូនទៅមែន ។ សោម ម៉េត សាក្សីមួយហ្នឹង គឺចេញពីកងពិសេសទៅៗជាយុទ្ធជនដែលអប់រំសាថ្មី នេះពិត ។ ក៏ប៉ុន្តែ ឲ្យបញ្ជូន ខ្ញុំសូមប្រើពាក្យអ្នកទោសទៅចុះ សូមទោស ឲ្យបញ្ជូនអ្នកទោសពីស-២១ ភ្នំពេញ ទៅ ស-២១ នៅព្រៃសគ្មានទេ គ្មានទាល់តែសោះ ។ សូមបញ្ជាក់ប៉ុណ្ណេះ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ដោយសារលោកមេធាវី គង់ ពិសី លោកជាមេធាវីនៅក្នុងក្រុមប្អូនផងដែរ លោកមានសំណួរពីរបី សូមបន្តពីសំណួរខ្ញុំបាទ ហើយខ្ញុំបាទមានសំណួរត្រឹមប៉ុណ្ណេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពលោកចៅក្រម ហើយនិងលោកស្រីចៅក្រម ដែលបានអនុញ្ញាតឲ្យខ្ញុំបាទ សួរសំណួរដល់ជនជាប់ចោទ ។

**ស៖** ខ្ញុំបាទជាបឋម សូមជម្រាបទៅលោកជនជាប់ចោទថា សូមលោកមេត្តាជួយពន្យល់ពីពាក្យថា "មាគ៌ា" ហើយនិង "គោលនយោបាយ" នៅក្នុងជំនាន់ បក្សកុម្មុយនីស្តកម្ពុជា ដែលលោកអនុវត្តនៅក្នុងស-២១ តើពាក្យទាំងពីរហ្នឹងខុសគ្នាយ៉ាងម៉េចដែរ ?

**ឆ៖** "មាគ៌ា" មានលក្ខណៈទូទៅ ឯចំណែក "គោលនយោបាយ" មានលក្ខណៈជាចំពោះបញ្ហាមួយៗ ។ ឧទាហរណ៍ គោលនយោបាយរបស់បក្សចំពោះខ្មាំង ដែលចាប់ ហើយបញ្ជូនទៅដល់មន្ទីរសន្តិបាលហើយ នេះគោលនយោបាយ ។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ រួចមាគ៌ានយោបាយខ្ញុំរកឧទាហរណ៍ លើកអត់ទាន់ទេ សួរប្រញាប់អ៊ីចឹងពេក រឿងវាភ្លេចរួចមកហើយ ខ្ញុំរកឧទាហរណ៍ ជូនមិនទាន់ទេ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង សួរថាតើ មាគ៌ាអ្នកណាជាអ្នកអនុម័ត ដែលលោកឡើងថាវាជាទូទៅហ្នឹង?

**ឆ៖** ឯកសារដែលមានប្រើពាក្យមាគ៌ានេះ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដំបូងគឺអនុម័តនៅឆ្នាំ ១៩៦០ សៀវភៅរបស់គេដែលចែងនោះ គេហៅថា "មាគ៌ានយោបាយជាយុទ្ធសាស្ត្រក្នុងការតស៊ូធ្វើបដិវត្តន៍នៅកម្ពុជា និងគោលនយោបាយជាយុទ្ធវិធីប្រមូលកម្លាំងធំទូលាយ" នេះចំណងជើងគឺអ៊ីចឹង ។ ហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង គឺមហាសន្និបាតមជ្ឈិមបក្សជាអ្នកកំណត់ៗ ដល់ឆ្នាំ១៩៧០ មានមហាសន្និបាតម្តងទៀត, ១៩៧១ (សូមទោស) ១៩៦៣ មានមហាសន្និបាតម្តងទៀត, ១៩៧១ មានមហាសន្និបាតម្តងទៀត, ១៩៦៦ មានមហាសន្និបាតម្តងទៀត, ១៩៦៨ មានមហាសន្និបាតចុងក្រោយបំផុត ។ ដូច្នេះ

មាគ៌ាកំណត់ដោយមហាសន្និបាត មាគ៌ាគឺកំណត់ដោយមហាសន្និបាត ដើរតួជាងគេក្នុងការកំណត់មាគ៌ាគឺលេខាបក្ស ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ចុះទាក់ទងទៅនឹង "គោលនយោបាយ" តើសមត្ថកិច្ចណាជំនាន់នោះ ជាអ្នកសម្រេច?

**ឆ៖** តាមពិត "មាគ៌ានយោបាយ" និង "គោលនយោបាយ" អនុម័តនៅក្នុងមហាសន្និបាតមជ្ឈិមៗ ក្នុងការអនុវត្តជាក់ស្តែងនូវបក្សកុម្មុយនីស្តកម្ពុជា ដើរតួនាទីធំបំផុតគន្លឹះបំផុតក្នុងការអនុវត្ត "មាគ៌ានយោបាយ" និង "គោលនយោបាយ" គឺលេខាបក្ស ។ ទាំងគោលនយោបាយ ទាំងមាគ៌ានយោបាយ គឺលេខាបក្ស ។

**ស៖** សូមអរគុណ ។ អ៊ីចឹង លោកអាចផ្តល់ជាឧទាហរណ៍បានទេថា មានអ្វី ឯកសារអី ដែលជា "គោលនយោបាយ" របស់បក្ស?

**ឆ៖** ឥឡូវ "មាគ៌ា" ខ្ញុំនឹកឃើញហើយ ។ កថាខណ្ឌទី១ នៃសេចក្តីសម្រេចរបស់មជ្ឈិមបក្សចំពោះបញ្ហាផ្សេងៗថ្ងៃ៣០ មីនា ១៩៧៩ នេះគេហៅថា "មាគ៌ាចាត់តាំងរបស់បក្ស" កំណត់មនុស្សបួនក្រុមហ្នឹងឲ្យមានសមត្ថកិច្ចក្នុងការកម្ទេច នេះមាគ៌ាចាត់តាំង ។ ឯចំណែក "គោលនយោបាយ" ឬក៏ "គោលនយោបាយរបសបក្ស" ឲ្យតែខ្មាំងត្រូវតែកម្ទេច អានេះគេហៅថា "គោលនយោបាយរបស់បក្សចំពោះខ្មាំង" ឲ្យតែខ្មាំងត្រូវតែកម្ទេច ។

**ស៖** សូមអរគុណ ។ ដូច្នេះ ខ្ញុំចង់សួរសំណួរមួយទៀតទាក់ទងទៅនឹងថា ប្រយោគក៏បានថា ខ្លឹមសារក៏បានថា "ជីស្មៅ ជីកទាំងឫស" តើពាក្យនេះជាពាក្យស្លោក ឬក៏ជា "គោលនយោបាយ"?

**ប្រធានអង្គជំនុំ៖**

ពាក្យហ្នឹងដូចជាមានការពាក់ព័ន្ធរួចហើយ ហើយជនជាប់ចោទបានឆ្លើយថា មិនមានការយល់ដឹងអំពីពាក្យនេះទេ ។ អ៊ីចឹងមិនអាច មិនឲ្យសួរសំណួរនេះទេ ហើយអាចសួរសំណួរផ្សេងទៀត ។

**សួរដោយលោក គង់ ពិសី៖**

**ស៖** សូមអរគុណ ។ ពីព្រោះថាកន្លងមកគាត់តែងតែនឹកឃើញ ដូចជាឧទាហរណ៍អម្បាញ់មិញនេះ ក្រែងតែគាត់នឹកឃើញៗទេ ។ អ៊ីចឹង ខ្ញុំសូមសួរសំណួរតទៅទៀតទាក់ទងទៅនឹង "ជីកស្មៅ ជីកទាំងឫស" ហ្នឹង ខ្ញុំមិនសួរទេ ប៉ុន្តែ ខ្ញុំចង់ដឹងថា នៅពេលដែលអ្នកណាម្នាក់ចាត់ទុកថាជា ខ្មាំងបញ្ជូនមក ស-២១ ចាត់ទុកជាខ្មាំងហើយ ។ ដូច្នេះ បងប្អូនប្រពន្ធរបស់គេនោះ ដែលមិនបានប្រព្រឹត្តអីនោះ តើ

គេនឹងបញ្ជូនមក ស-២១ ដែរឬទេ?

**ឆ៖** ជាទូទៅ ខ្ញុំឃើញមកអ្នកដែលនៅសល់ដូចមិនថាំ ។ គេចាប់បង វ៉ន គឺ វ៉ន វេត នេះក៏គេចាប់ប្រពន្ធគាត់ឈ្មោះ វិន ដែរ ។ គេចាប់ ណាត ប្រធានស-២១ នេះក៏គេចាប់ មិត្តគន់ ប្រពន្ធ ណាត ដែរ ។ ដូច្នេះ ជាទូទៅខ្ញុំឃើញមក នៅសល់អ្នកណាខ្លះខ្ញុំអត់ដឹងទេ អ៊ូសៗ មានសល់ៗ គេចាប់មិត្ត ពូល ទឿន មក ស-២១ ប្រពន្ធគាត់ឈ្មោះ កាំង ស៊ីវហ្សួរ អត់ចាប់មកទេ ។ មិនជានៅឯណា? យ៉ាងម៉េចបានមិនចាប់? ខ្ញុំភ្លេចអស់ទៅហើយ ប៉ុន្តែ ឯកសារវាមានមកហើយ ពូល ទឿន ចាប់ , កាំង ស៊ីវហ្សួរ អត់ចាប់ទេ ។ ដូច្នេះ វាមានអ៊ីចឹង មិនដឹងរឿងអីបានមិនចាប់ យ៉ាងម៉េចទេ ។ ខាងលើ គេអ្នកសម្រេចទេ ។ ខ្ញុំសូមឆ្លើយមួយម៉ាត់គេអ្នកសម្រេចទេ ប៉ុន្តែ មាននៅសល់អ៊ីចឹងមែន ។

**ស៖** ខ្ញុំសូមអរគុណ ។ បើតាមខ្ញុំយល់ពីចម្លើយរបស់លោក អ្នកដែលត្រូវជាសាច់ញាតិរបស់ដែល ជនដែលគេត្រូវចោទហ្នឹង គឺគេចាត់ទុកជាខ្មាំងដែរ អ៊ីចឹងមែនទេ?

**ឆ៖** តែគេចាប់ហើយ គេចាត់ទុកជាខ្មាំងហើយ ។

**ស៖** ខ្ញុំសូមអរគុណ ។ ហើយលោកបានជម្រាបអង្គសវនាការហើយថា ឲ្យតែមេរបស់ លោក គឺលោកតែងតែហៅគាត់ថា “អង្គការ” ហើយដូចលោក សុន សេន លោកគ្រូ សុន សេន អ៊ីចឹង ហៅគាត់ថា “អង្គការ” អ៊ីចឹងលោក នួន ជា, លោក សុន សេន គាត់ហៅ នួន ជា ថាអង្គការដែរ អ៊ីចឹងខ្ញុំចង់ដឹងថា បញ្ជារបស់គាត់នោះ ជាគោលនយោបាយ ឬមួយក៏ជាអ្វី?

**ឆ៖** បញ្ជារបស់គាត់ វាជាការអនុវត្តសេចក្ដីសម្រេចចិត្ត ជាសេចក្ដីសម្រេចចិត្តតូចធំរបស់បក្សក្នុងលក្ខន្តិកៈ ខ្ញុំមិនបានមើលឲ្យច្បាស់ឡើងវិញទេ ក៏ប៉ុន្តែ ភារកិច្ចរបស់បក្សជនត្រូវអនុវត្តសេចក្ដីសម្រេចចិត្តតូចធំរបស់បក្សៗ ។ ដូច្នេះ បញ្ជារបស់គាត់ជាសេចក្ដីសម្រេចចិត្តរបស់បក្ស ។

ភារកិច្ចរបស់បក្ខជនត្រូវអនុវត្តសេចក្ដីសម្រេចចិត្តតូចធំរបស់បក្ស ។

ដូច្នេះបញ្ជារបស់គាត់ជាសេចក្ដីសម្រេចចិត្តរបស់បក្ស ។

**ស៖** លោកលើកឡើងថាបញ្ជារបស់គាត់ គឺជាសេចក្ដីសម្រេចរបស់បក្ស ហើយមុនទៀតលោកថា សេចក្ដីចិត្តរបស់បក្សគឺជាគោលនយោបាយ ។ អ៊ីចឹង តាមដែលខ្ញុំយល់ថា បញ្ជារបស់គាត់ជាគោលនយោបាយរបស់បក្សដែរ? តើខ្ញុំយល់ហ្នឹងត្រឹមត្រូវទេ?

**ឆ៖** បញ្ជារបស់គាត់តូចៗ អ៊ីចឹង ជាការអនុវត្តគោលនយោបាយ ចេញមកពីការអនុវត្តគោលនយោបាយ ។ សេចក្ដីសម្រេចចិត្តរបស់មជ្ឈិម អាចំណាងឯកសារយើងហ្នឹង សេចក្ដីសម្រេចចិត្តរបស់

គណៈមជ្ឈិម អាហ្នឹងជាគោនយោបាយរួម ដល់សេចក្ដីសម្រេចរបស់ឯកជន ពូនួន ក្នុងឋានៈគាត់ជាអចិន្ត្រៃយ៍ ជាការអនុវត្តសេចក្ដីសម្រេចចិត្ត ។

**ស៖** សូមអរគុណ ។ អ៊ីចឹង នៅពេលដែលមេរបស់លោកដាក់បញ្ជាមក បើលោកមិនអនុវត្តតាមបានទេ?

**ឆ៖** គ្មានបើទេ ត្រូវតែអនុវត្តតាម បើយើងល្មើស គឺត្រូវតែស្លាប់ ។ ខ្ញុំសូមលើឧទាហរណ៍មួយឈ្មោះ ប៉ាង ប្រធានគណៈកម្មាធិការពេទ្យ៩៨ គេឱ្យឌុបមនុស្សម្នាក់ឈ្មោះ សារ៉ន យកទៅឱ្យគេចាប់ ។ ប៉ាង ក៏ដឹងថាគាត់ឌុប សារ៉ន យកទៅឱ្យគេចាប់ ។ ឱ្យ សារ៉ន រត់រួច គាត់ត្រូវគេចាប់ៗ ដោយចោទថាចូលជើងចូលដៃ ។ ចាប់ឈ្មោះ ប៉ាង នៅក្នុងបញ្ជើស-២១ អ្នកទោសរបស់ ស-២១ នៅនុំង ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរបន្តទៀតទាក់ទងទៅនឹងសំណួរហ្នឹងដដែល ។ បើសិនជាណាលោកផ្ដល់ហេតុផលឱ្យបានសមរម្យត្រឹមត្រូវទៅមេរបស់លោក សួរថាតើគាត់យល់ព្រមទេ?

**ឆ៖** ហេតុផលអី? យ៉ាងម៉េច?

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់ឱ្យច្បាស់បន្តិចទៀត ។ ហេតុផលអីក៏ដោយ ឧទាហរណ៍ថា ការបញ្ជាឱ្យសម្លាប់អ៊ីចឹង លោកផ្ដល់ហេតុថានេះមិនចាំបាច់សម្លាប់ទេ មូលហេតុអ៊ីចេះៗ ផ្ដល់ជូនទៅគាត់ អ៊ីចឹងគាត់យល់ព្រមទទួលពីលោកទេ?

[១១:៣២:៥២]

**ឆ៖** ជាមាគ៌ានយោបាយ ជាគោលនយោបាយផ្ដល់ហេតុផលតវ៉ាមិនបានទេ មាគ៌ារបស់បក្សមិនអាចតវ៉ាបាន ។

**ស៖** សូមអរគុណ លោកមានចាំទេ ដែលលោកបានឆ្លើយចំពោះមុខអង្គសវនាការថា លោកនួន ជា បានបញ្ជាឱ្យលោករើជើងឯកហ្នឹងទៅកប់ស្រូវ ហើយលោកបានជម្រាបគាត់ពីហេតុទៅ លោកនួន ជា គាត់យល់ព្រមតាមលោក ។

**ឆ៖** នេះជាសេចក្ដីសម្រេចចិត្តៗមួយ មិនមែនជាមាគ៌ាបក្សទេ ជាការអនុវត្តមាគ៌ាបក្ស ជាសេចក្ដីសម្រេចចិត្តមួយ ក៏ប៉ុន្តែ យើងមានហេតុផលលើក នៅក្នុងសិទ្ធិអំណាចរបស់យើងៗ ជាអ្នកអនុវត្តយើងលើកហេតុផល ។ នេះជាសេចក្ដីសម្រេចចិត្តមួយ ដើម្បីអនុវត្តគោលនយោបាយគ្រប់គ្រងខ្មាំង កម្ទេចខ្មាំង សង់សំណង់មួយសម្រាប់គ្រប់គ្រងខ្មាំង ហ្នឹងជាការអនុវត្តគោលនយោបាយទេ ។

**ស៖** អ៊ីចឹងនៅពេលនោះ គាត់ឱ្យលោករើ លោកផ្ដល់យោបល់ទៅគាត់--

**ឆ៖** សូមទោសណ៎ា ខ្ញុំនិយាយឲ្យវាច្បាស់រឿងហ្នឹងឡើងវិញម្តងទៀត ។ គាត់ប្រាប់ខ្ញុំ ថាបក្សថាមិត្តទៅកប់ស្រូវ តាំងពីដើមមកខ្ញុំថា បាទ ។ រួចឥឡូវទៅៗ កុំនៅភ្នំពេញទៀត ខ្ញុំថាទៅម៉េចបង ជើងឯកសុទ្ធតែឆ្អឹង ខ្ញុំដើរចោលម៉េចបាន ឥឡូវខ្ញុំសូមចេញពីភ្នំពេញទៅនៅជើងឯក ។ គាត់នៅស្ងៀម គាត់ថាចាំខ្ញុំសុំយោបល់អង្គការ ។ ចាំខ្ញុំសុំយោបល់អង្គការ ពីរបីថ្ងៃក្រោយមក គាត់ហៅខ្ញុំទៅធ្វើការ គាត់ថាបានអង្គការសុខចិត្តឲ្យមិត្តនៅជើងឯក ។

ដូច្នេះ យើងជាអ្នកអនុវត្តសេចក្តីសម្រេចមួយ យើងមានលើកហេតុផលអ៊ីចឹងបាន ។ នេះអនុវត្តសេចក្តីសម្រេចចិត្តដើម្បីឈានទៅសម្រេចការអនុវត្តមាគ៌ាគោលនយោបាយរបស់បក្ស ។ យើងប្រកែកបាន នេះជាក្របខ័ណ្ឌអំណាចរបស់យើង ។

**ស៖** អ៊ីចឹងនៅពេលនោះគឺថាជើងឯកនោះនៅកន្លែងហ្នឹងដដែល មិនបានរើទៅកប់ស្រូវទៅតាមយោបល់របស់លោក អ៊ីចឹងមែនទេ?

**ឆ៖** ត្រូវហើយ ។

**លោក គង់ ពិសី៖**

សូមអរគុណ ហើយខ្ញុំអស់សំណួរដែរលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះសូមប្រគល់វេទិកានេះជូនទៅមេធាវីការពារជនជាប់ចោទ បើសិនជាមានសំណួរអ្វីសួរដល់ជនជាប់ចោទ ។ សូមអញ្ជើញលោកមេធាវី ។

[១១:៣៥:៤៨]

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក ឌុច ការសួរដេញដោលកាលពីថ្ងៃមុនបានលើកឡើងថា បុគ្គលិកនៅស-២១ មានច្រើនជាងគេ រហូតដល់ជាង២០០០នាក់ ។ តើវាច្រើន ពាក្យថាច្រើនជាងគេនេះ តើលោកទទួលយកបានទេ? បើទទួលយកបានដោយហេតុអី? បើទទួលមិនបានដោយហេតុអី? សូមលោកបញ្ជាក់ ។

**ឆ៖** លោកប្រធានជាទីគោរព! បុគ្គលិកនៅមន្ទីរស-២១ វាមានឯកសាររបស់វាច្បាស់លាស់ដែលវាស្ថិតនៅក្នុងអគ្គសេនាធិការ ឬក៏នៅ៨៧០ នោះ ។

ដូច្នេះ ចំនួនបុគ្គលិកពីរពាន់បីរយប្លាយនាក់នេះ វាមានឯកសាររបស់វាបញ្ជាក់ច្បាស់លាស់ គ្មាន

អ្នកណាប៉ានប្រកែកទេ ឯកសារប៉ុណ្ណេះ ។ ក៏ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថាស-២១ វាមានមជ្ឈមណ្ឌលរបស់វាពីរ មជ្ឈមណ្ឌលទីមួយនៅភ្នំពេញ ប្រើប្រាស់បុគ្គលិកតិចទេ តិចជាងមជ្ឈមណ្ឌលទីពីរ គឺនៅឯព្រៃស ឯចំណែកមជ្ឈមណ្ឌលនៅជើងឯក ប្រើបុគ្គលិកប្រហែលជា-- តាមខ្ញុំចាំដូចប្រាំនាក់ប៉ុននុ៎ងទេ ។

នេះរឿងល្អិតនៃកម្លាំងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ។ សួរថាតើខ្ញុំសុខចិត្តទទួលស្គាល់ថាកម្លាំងនេះច្រើនជាងនេះទេ? ដរាបណាមិនទាន់ឃើញឯកសារផ្លូវការណាមួយច្បាស់លាស់អំពីមន្ទីរសន្តិបាលផ្សេងទៀត ខ្ញុំមិនឆ្លើយទេ មិនទទួលទេ ។ នេះជម្រាបដោយស្មោះត្រង់ទៅ ទាមទារឲ្យមានឯកសារច្បាស់លាស់ដូចឯកសារស-២១ អ៊ីចឹងយកមកដាក់លើតុទាំងអស់គ្នាមក ។ តើចំនួននេះរបស់មន្ទីរសន្តិបាលទាំងអស់នោះ ជាចំនួនដែលបូកសរុបទាំងកន្លែងឃុំឃាំង សួរចម្លើយផង ហើយនិងកន្លែងអប់រំសាថ្មីផង មែនឬមិនមែន? ដល់អ៊ីចឹង បានយើងៗវាស្រួលប្រៀបធៀប ។

នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងថា ខ្ញុំមិនព្រម មិនទទួលស្គាល់នៅឡើយទេ ដរាបណាមិនទាន់មានឯកសារដើម្បីប្រៀបធៀបគ្នាឲ្យច្បាស់លាស់ ។

**ស៖** អរគុណ ។ ពីម្សិលមិញលោកបាននិយាយថា លោក ក្រេក អេតឆេសាន់ នៅក្នុងរបាយ-ការណ៍របស់គាត់ គឺមានចំណុចល្អមែនទែន គឺកថាខណ្ឌទី២៤ និងកថាខណ្ឌទី៥៦ ហើយមានចំណុចល្អធម្មតាច្រើន និងមានចំណុចដទៃទៀត ត្រូវតែសួរដេញដោលឲ្យបានច្បាស់លាស់ ។ អ៊ីចឹង ខ្ញុំសូមសួរលោកថា តើកថាខណ្ឌ២៤ ដែលលោកថាល្អមែនទែននោះ តើល្អយ៉ាងម៉េច? នេះជាសំណួរទីមួយ សូមលោកបញ្ជាក់ ។

[១១:៣៩:៣៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន កថាខណ្ឌ២៤ របស់ អេតឆេសាន់ មានពីរឃ្លា ។ ឃ្លាទីមួយន័យយោងទៅរកឯកសារចុះថ្ងៃ៣០ ខែមីនា ១៩៧៦ ។ បញ្ហានេះអង្គជំនុំជម្រះបានដេញដោលគ្នាច្រើនណាស់ទៅហើយ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា ស-២១ ក្តី កងពលនានាក្តី មាន៥០២ របស់ ស៊ូ ម៉េត, ៧០៣ របស់ ខឹម ពីន, ៣១០ របស់មិត្តអឿន គ្មានសិទ្ធិសម្រេចកម្ទេចអ្នកណាទេ ។ អ្នកដែលមានសិទ្ធិសម្រេចកម្ទេច គឺសេនាធិការ ។ ការប្រជុំនៅថ្ងៃ០៦ កញ្ញា ១៩៧៦ ដែលមានបង៨១ ដឹកនាំបន្តពីបង៨៩ ជាឧទាហរណ៍ស្រាប់ ។ នេះខ្ញុំសូមប្រកាសតែប៉ុណ្ណឹង ។

ឃ្លាទីពីរ នៃកថាខណ្ឌ២៤នេះ និយាយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយបែបទៀត គឺការជម្លៀសមូស្លីមកម្ពុជាចេញពីភូមិភាគបូព៌ា ទៅភូមិឧត្តរ ។ សារទូរលេខលេខ១៥ ចុះថ្ងៃ៣០ ខែវិច្ឆិកា

១៩៧៥ របស់ បងភឹម, ឈ្មោះក្នុងសារទូរលេខគាត់ប្រើពាក្យ ផុន លេខាបូព៌ានេះ បានបញ្ជាក់ថា ប៉ុល ពត លេខាមជ្ឈិមបញ្ជាឲ្យភូមិភាគទាំងពីរសហការគ្នាជម្លៀសមូស្លីមដំបូងប្រាំម៉ឺននាក់ ។ ទិដ្ឋភាពនេះ វាបញ្ជាក់ឲ្យឃើញថា ជម្លៀសប្រជាជនជារូបភាពមួយទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅភូមិភាគបូព៌ា ហើយនិងឧត្តរនេះ មានអចិន្ត្រៃយ៍មជ្ឈិមបក្សជាអគ្គបញ្ជាការខ្ពស់បំផុត ហើយមានលេខាភូមិភាគបូព៌ា និងលេខាភូមិភាគឧត្តរជាបញ្ជាជាប់មូលដ្ឋាន ជាប់សមរភូមិ ជាប់កម្លាំង ។

ដូច្នេះ កថាខណ្ឌ២៤នេះវាបញ្ជាំងឲ្យឃើញផ្នែកមួយដែលយើងអាចសន្និដ្ឋានជារួមបាន ថាគ្រប់សកម្មភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅកម្ពុជា គឺអចិន្ត្រៃយ៍បក្សជាអគ្គបញ្ជាការខ្ពស់បំផុត ។ លេខាភូមិភាគ ហើយនិងបីក្រុមទៀតជាអគ្គបញ្ជាជាប់ជាក់ស្តែង ជាប់សមរភូមិ ។ នេះដែលវាមានប្រយោជន៍សំខាន់ ល្អបំផុតគឺនៅត្រង់កថាខណ្ឌ២៤ នេះនៅប្រការនេះ ។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណេះ ។

**សៈ** ចុះតើកថាខណ្ឌទី៥៦ ដែលលោកថាល្អមែនទែនដែរនោះ តើវាយ៉ាងម៉េចដែរ? សូមលោកបញ្ជាក់មក ។

[១១:៤៣:១៥]

**ឆៈ** អរគុណ លោកប្រធានជាទីគោរព! ឃ្លាទីមួយនៃកថាខណ្ឌ៥៦នេះ លោក អេតធេសាន់ សរសេរថា ជាទូទៅភស្តុតាងដែលមានបង្ហាញទំនាក់ទំនងភូមិភាគត្រូវរៀបចំតាមរយៈខ្សែបណ្តោយជាមួយខ្សែចង្វាក់បញ្ជា ។ ត្រូវហើយនេះជាភាសាច្បាប់អន្តរជាតិ ដែលប្រទេសនីតិរដ្ឋគេប្រើពាក្យនេះ គេប្រើពាក្យខ្សែបណ្តោយ ក៏ប៉ុន្តែដើម្បីស្រួលយល់ ខ្ញុំសូមនិយាយតាមភាសារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបក្ខជនផ្សេងទៀត គេប្រើពាក្យតាមបែបគេ ។ ពាក្យថាខ្សែបណ្តោយនេះ ក្នុងបក្សកុម្មុយនីស្តកម្ពុជាយើងខ្ញុំ ប្រើថា "តាមខ្សែចាត់តាំងដែលបក្សកំណត់ តាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ" គឺអំណាចវាប្រមូលផ្តុំនៅខាងលើនោះ នៅអចិន្ត្រៃយ៍នោះ ។ គ្មានអ្នកណាប៊ានទាក់ទងផ្តេសផ្តាសក្រៅការចាត់តាំងទេ ព្រោះអំណាចវាទៅប្រមូលផ្តុំខាងលើហើយ ប្រជាធិបតេយ្យប្រមូលផ្តុំ ។ ហើយបក្សកំណត់ទៀតថា ប្រជាធិបតេយ្យប្រមូលផ្តុំ វាជាវិន័យដ៏រឹងប៉ឹងតែមួយគត់របស់យើង ដើម្បីទប់ទល់ឧបាយកលខ្មាំង ។ ឧបាយកលជាចំហ ឧបាយកលខ្មាំងជាសម្ងាត់ ឧបាយកលខ្មាំងដោយផ្ទាល់ ឧបាយកលខ្មាំងដោយប្រយោល ។ គឺយើងទប់បានដោយសារអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំនេះ ។ នេះជាខ្លឹមសារដែលមានចែងនៅក្នុងលក្ខន្តិកៈបក្ស ត្រង់ចំណុចទី៦ នៃលាក់ការណ៍និងគោលជំហរជាមូលដ្ឋាន

របស់បក្ស ។ វាកំណត់ច្បាស់អ៊ីចឹង ។ ដូច្នេះ វាស្រប ទូទាំងប្រទេសគ្មានអ្នកណាហ៊ានល្មើសទេ ។

នេះខ្ញុំសូមនិយាយប៉ុណ្ណឹងសិន ។

[១១:៤៥:៤២]

ហើយអានឃ្លាតទៅទៀត ទំនាក់ទំនងខ្សែរយៈទទឹងក្នុងកម្រិតអប្បរមារវាងភូមិភាគទាំងឡាយ ទំនាក់ទងពីភូមិភាគទៅភូមិភាគត្រូវបានគេបញ្ជូនតាមរយៈថ្នាក់មជ្ឈិម ។ ដូចបានបង្ហាញ តាមរយៈតេឡេក្រាមផ្ញើទៅ ប៉ុល ពត ពីលេខាភូមិភាគបូព៌ាឈ្មោះ សោ ភឹម ហៅ ឆុន ត្អូញត្អែរអំពីកង្វះសហប្រតិបត្តិការពីលេខាភូមិភាគកណ្តាលឈ្មោះ កែ ពក ក្នុងការអនុវត្តផែនការមជ្ឈិមដើម្បីនិរទេសអ្នកស្រុកជនជាតិចាមចំនួនមួយសែនប្រាំម៉ឺននាក់ពីភូមិភាគបូព៌ាទៅភូមិភាគផ្សេងទៀត ។ យោងទៅកំណត់ចុងទំព័រលេខ១២១ ។

ខ្ញុំសូមបញ្ជាក់ថា ពាក្យដែលសរសេរនៅក្នុងនេះថា ខ្សែរយៈទទឹងភាសារបស់បក្សកុម្មុយនីស្តយើងខ្ញុំមិនប្រើទេ ។ តាមពិតវាជាភារកិច្ចមួយ ជាបទបញ្ជាមួយ ដែលអចិន្ត្រៃយ៍មជ្ឈិមបក្សបញ្ជាឲ្យលេខាភូមិភាគទាំងពីរនេះសហការគ្នា ដើម្បីជម្លៀសមូស្លីមកម្ពុជាចេញពីបូព៌ាទៅឧត្តរ ។

ដូច្នេះ មិនមានទទឹងទេ ។ គឺជាសហប្រតិបត្តិការរវាងភូមិភាពពីរ ។ ស-២១ ខ្លួនខ្ញុំក៏ធ្លាប់បក្សបញ្ជាឲ្យធ្វើសហប្រតិបត្តិការជាមួយនឹងអង្គភាពផ្សេងទៀតដែរ ។ ទីមួយ នៅពេលដែលខ្ញុំមិនទាន់បានកាន់កាប់កិច្ចការពេញដៃជាអនុលេខា ស-២១ បក្សប្រើខ្ញុំឲ្យសហការជាមួយនឹង មិត្តសុខ ឈ្មោះដើម ស៊ិន ដារា លេខាគណៈកម្មាធិការកម្លាំងសម្ងាត់ក្រុងភ្នំពេញ ។ ដើររើឯកសារពីផ្ទះអ្នកធំ ហើយនិងគ្រឹះស្ថានសាធារណៈនៃរបប លន់ នល់ ។ មិត្តសុខ ហើយនិងខ្ញុំ សហការគ្នា ភស្តុតាងដែលនៅសល់រូបថតមិត្ត សុខ កៀកស្មាខ្ញុំ ដែល ហ្វ្រង់ស្វ័រ ប៊ីហ្សូ យកដាក់នៅសៀវភៅរបស់គាត់ *ឡឺប៉ុកតែល* ហ្នឹងភស្តុតាងដែលនៅសល់ ។ ទន្ទឹមនេះ ក្នុងសភាពការណ៍ពិសេសមួយ បក្សឲ្យខ្ញុំទៅសហការណ៍ជាមួយនឹងមិត្តតាត អនុលេខា១៧០ ហើយនិង បងពីន លេខា៧០៣ ដើម្បីរកឲ្យឃើញថា តើខ្មោចម្នាក់អណ្តែតទឹកម្នាក់ហ្នឹងជាស្អី? មកពីណា? អត់មានភស្តុតាងដែលនៅសល់នៅនឹងស-២១ ទេ ។ សេចក្តីរាយការណ៍ខ្ញុំបែបនៅឯមន្ទីរ៨៧០ ឯណោះ ។

[១១:៤៨:៣៦]

ដូច្នេះ គ្មានរឿងទាក់ទងតាមខ្សែទទឹងទេ មានតែសហប្រតិបត្តិការដែលបក្សបញ្ជា ។ ទាល់តែមានបញ្ជាពីបក្សបាន១យើងធ្វើសហប្រតិបត្តិនឹងគ្នាបាន ។ ដូច្នេះ នេះយើងដែលហៅថាប្រជាធិបតេយ្យ

ប្រមូលផ្តុំ អំណាចទាំងអស់វាប្រមូលផ្តុំទៅខាងលើ ។

ខ្ញុំសូមនិយាយតទៅទៀត ។ អេតធេសាន់ គាត់សរសេរថា "ឲ្យតែទាក់ទងខ្សែទទឹង គឺសន្មតថាភាគច្រើនគេចាប់អារម្មណ៍សង្ស័យថា "ក្បត់" ។ គាត់លើកយកឯកសារជាចម្លើយសារភាពរបស់ ចាន់ ចក្រី និយាយអំពី រស់ ភួន ហើយនិង សួស នៅ ហៅ ឈូក ទាក់ទងគ្នា ។ ឧទាហរណ៍នេះមិនខ្វះទេ ។

ដូច្នេះហើយ ផ្ទាល់ខ្លួនខ្ញុំ ក្នុងការរស់នៅធ្វើការងារនៅមន្ទីរស-២១ មានទៅទាក់ទងនឹងកម្មាភិបាលខ្លះក្នុងនាមមនោសញ្ចេតនា តែជម្រាបមេណ៎ា ពិតជាជម្រាបមេ ។

ខ្ញុំសូមនិយាយជាក់ស្តែងមួយទៅចុះ ខ្ញុំឧស្សាហ៍នាំប្រពន្ធទៅហូបចុកផ្ទះបង ឆាយ គឹមហ៊ី ។ គាត់សួរ "ទៅធ្វើអីហ្នឹង?" ខ្ញុំសុំច្បាប់គាត់ ខ្ញុំថា "ហ៊ឺបង! ខ្ញុំឃ្លានអាស្រាបៀរ ស៊ីងតាវរបស់ចិនហ្នឹង" គាត់សើច ប៉ុន្តែ គាត់ឲ្យទៅ ប៉ុន្តែអត់ប៉ានញឹកទេ ។ បីបួនខែអីយូរៗសុំគាត់ម្តង ។ ដល់សុំលើកទីពីរ គាត់ថា "យ៉ា! កុំញឹកពេក" លែងប៉ានទៅបណ្តោយ ។ ព្រោះឲ្យតែទាក់ទងគ្នាគឺគេចាប់អារម្មណ៍បញ្ហា ឲ្យតែទាក់ទងគ្នាខុសចាត់តាំង គឺគេចាប់អារម្មណ៍បញ្ហាស្អីខានមិនខានជាសម្ងាត់ ។ ដូច្នេះ មិនប៉ានទៅ ។

សរុបមក កថាខណ្ឌទី២៦នេះ វាល្អៗត្រង់ដែរបង្ហាញច្បាស់លាស់ក្នុងការចាត់តាំងរបស់បក្ស គឺសុទ្ធតែពីលើចុះក្រោម ។ ទាក់ទងជាមួយនឹងអង្គភាពផ្សេង វាទាល់តែបក្សពីខាងលើបញ្ជាឲ្យសហប្រតិបត្តិការនឹងគ្នា ។ ខ្ញុំសូមបញ្ចាក់កថាខណ្ឌ២៦នេះត្រង់នេះ ។ អ្ហ៎! ៥៦នេះ ត្រឹមនេះ ។ សូមបញ្ចប់ ។

**ស៖** ហើយតទៅទៀត លោកបានថា ក្នុងរបាយការណ៍របស់លោក គ្រេក អេតធេសាន់ ហ្នឹង ថាមានល្អធម្មតាជាច្រើន ។ អ៊ីចឹង សូមលោកលើកឧទាហរណ៍តែមួយបានហើយយកមកបញ្ជាក់ ។

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមលើកឧទាហរណ៍មួយជូន គឺនៅក្នុងទំព័រ00314784 ជាភាសាខ្មែរ ហើយខ្ញុំសូមទៅរកជាភាសាអង់គ្លេសជូន ។ ភាសាអង់គ្លេសនៅទំព័រ00145661 នេះជាស្នាដៃមួយដែលល្អ ។

[១១:៥១:៥៦]

**អ្នកបកប្រែ៖**

សូមឲ្យជនជាប់ចោទនិយាយលេខERN ឡើងវិញម្តងទៀត ។

**ជនជាប់ចោទ៖**

អង់គ្លេស ឬ ខ្មែរៗ?

**អ្នកបកប្រែ៖**

ជាភាសាខ្មែរ ជាអង់គ្លេសផង ។

**ជនជាប់ចោទ៖**

**ឆ៖** លេខ*ERN* ជាភាសាខ្មែរមាន 00314784 ចំណែកជាភាសាអង់គ្លេស 00145661 ។

នេះជាកថាខណ្ឌមួយដែលល្អធម្មតា ដែលមានច្រើន ហើយដែលពេលនេះខ្ញុំលើកយកមកនិយាយតែឧទាហរណ៍មួយ ។ តទៅទៀតនេះ ខ្ញុំសូមនិយាយចំណុចដែលត្រូវតែពិភាក្សាគ្នាដេញដោល។ ចំណុចមួយយើងបានដេញដោលរួចហើយ គឺសំបុត្រប្រាំបួនច្បាប់របស់ ស៊ូ ម៉េត ទៅខ្ញុំនឹងនៅក្នុងឯកសារនេះដាក់ថាទូរលេខកងទ័ពកម្ពុជាប្រជាធិបតេយ្យ ។ តាមពិតមិនមែនទូរលេខទេ គឺសំបុត្រ ។ ប៉ុន្តែ រឿងយើងដេញដោលរួចទៅហើយ ចប់ ។ ខ្ញុំសូមទុកបញ្ហាមួយនេះ ថាបានដោះស្រាយហើយ ដេញដោលហើយ ។

[១១:៥៤:២៣]

ឯចំណែកបញ្ហាមួយទៀត គឺសេចក្តីសារភាពរបស់ឈ្មោះ គង់ គៀន ហៅ អ៊ឹង វ៉េត។ ម្សិលមិញខ្ញុំឆ្លៀតឱកាសបានជម្រាបអង្គសវនាការទាំងមូលដោយឆ្លើយនឹងសំណួររបស់លោក អាឡាំង វ៉ែនណឺម្តងរួចហើយ ។ គឺឯកសារ ERN 00017305 ជាភាសាខ្មែរ ។ ក៏ប៉ុន្តែ ឯកសារនេះវាមានន័យទៅផ្សេងសេចក្តីបកប្រែជាភាសាអង់គ្លេសក៏រក្សាន័យដើមរបស់គេបានជាមូលដ្ឋាន ។ ក៏ប៉ុន្តែ ដល់លោក អេតធេសាន់ ទៅសរសេរនៅនឹងកំណត់ចុងទំព័ររបស់គាត់ត្រង់លេខ កំណត់ចុងទំព័រលេខ៧៨ គាត់និយាយខុសន័យពីច្បាប់ដើមពិតប្រាដកនៃឯកសារ ។ ដល់គាត់និយាយខុសពិតប្រាដកនៃឯកសារ អ៊ីចឹងធ្វើឱ្យកថាខណ្ឌ៣៧ របស់គាត់ ប្រសិនបើគេមើលមកលេខយោង គេយល់ច្រឡំ ។

កថាខណ្ឌ៣៧ របស់គាត់អត់អី បើសិនជាគ្មានកំណត់ជើងទំព័រជាលេខយោងនេះទេ ល្អ ។ ប៉ុន្តែដល់មានលេខយោងហ្នឹង វាទៅជាច្របូកច្របល់ ។ ដូច្នេះ យើងខ្ញុំសូមលើកបញ្ហាដែលមិនប្រក្រតីបែបនេះ ជូនអង្គជំនុំជម្រះ ។

[១១:៥៦:១៩]

បញ្ហាមិនប្រក្រតីមួយទៀត គឺដំបូងខ្ញុំសូមលើកអំពីសេចក្តីសម្ភាសន៍របស់ កែ ពក ។ សេចក្តីសម្ភាសន៍របស់ កែ ពក នេះខ្ញុំសូមជូនជាភាសាអង់គ្លេស លេខយោងជាភាសាអង់គ្លេស ។ ខ្ញុំអត់ទាន់មានលេខយោងជាខ្មែរទេ ។ លេខERN ជាខ្មែរទេ ។ បទសម្ភាសន៍របស់បងពក, កែ ពក នេះ មានលេខ

00080-- សូមទោស វាមានច្រើនទំព័រ ឥឡូវខ្ញុំសូមស្ងូត្រតែទំព័រលេខERN ត្រង់តែទំព័រ00089713 ត្រង់ដែលបងពក គាត់និយាយអំពីកាលគាត់មកភ្នំពេញ ។ ខ្ញុំមិនអានទេ ហើយសុំមិនឲ្យអានទេ គ្រាន់តែសុំជូនថាវាមាននៅក្នុងទំព័រ00089713 នេះ ពីបន្ទាត់ទី៨ទៅរហូតដល់បន្ទាត់ទី១២ ។ ខ្លឹមសារវាទៅផ្សេង ដល់ អេតធេសាន់ គាត់យកមកសរុបនៅនឹងលេខ កំណត់ចុងទំព័ររបស់គាត់ត្រង់លេខ១២៣ វាទៅផ្សេង ។ ដល់កំណត់ទៅផ្សេង ធ្វើឲ្យន័យដែលគាត់សរសេរនៅកថាខណ្ឌ៥៧ បើសិនជាគេមិនបានអានទៅដល់លេខយោងទេ គេអត់អីទេ ប៉ុន្តែ គេអានទៅលេខយោង គេច្រឡូកច្របល់ក្នុងចិត្តហើយ ។

ខ្ញុំសូមត្រឡប់ទៅលើកថាខណ្ឌលេខ៣៧ អំមិញ ខ្ញុំច្រឡំៗ ។ កថាខណ្ឌលេខ៣៧ ច្របូកច្របល់មិនធម្មតាទេ ច្របូកច្របល់ ។ ដូច្នេះ ខ្ញុំសូមជូនជាការចាប់អារម្មណ៍ប៉ុណ្ណឹង ។ នៅក្នុងអត្ថបទរបស់ អេតធេសាន់ ដែលខ្ញុំសង្កេតមើលជាបឋម ខ្ញុំឃើញប៉ុណ្ណឹង ។

ទន្ទឹមនេះ នៅពេលដែល អេតធេសាន់ គាត់មានប្រសាសន៍ថា បញ្ជីដោះលែង ជាឯកសារដោះបន្ទុក ។ ជាបញ្ហាមួយធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលដែរ ។ ខ្ញុំមិនបានដោះលែងអ្នកណា ខ្ញុំនឹងជម្រាបជូនអង្គប្រជុំ ។ ពេលនោះខ្ញុំមានឯកសារដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបានជម្រាបជូនអង្គប្រជុំតាមដែលខ្ញុំឆ្លើយជាមួយលោក គីម សួន អំមិញ ។ ច្បាស់លាស់ ខ្ញុំមិនភ្លេចទេ ឧក្រិដ្ឋកម្មរបស់ខ្ញុំ ។ ខ្ញុំមិនយកអាឯកសារដោះលែងក្លែងក្លាយមកលុបបំបាត់ឧក្រិដ្ឋកម្មរបស់ខ្ញុំទេ ទទួលស្គាល់ទាំងស្រុង ។

ដូច្នេះ ខ្ញុំសូមបដិសេធហើយ ពាក្យដែលលោក អេតធេសាន់ មានប្រសាសន៍ថា បញ្ជីដោះលែងនេះ វាជាឯកសារដោះបន្ទុកខ្ញុំ ខ្ញុំសូមបដិសេធ មិនមែនជាឯកសារដោះបន្ទុកខ្ញុំទេ ។ ឧក្រិដ្ឋកម្មរបស់ខ្ញុំ ខ្ញុំទទួល ។ នេះខ្ញុំសូមបញ្ជាក់ ។ ខ្ញុំអត់ទទួលបានទេ ពាក្យលោក អេតធេសាន់ ដែលមានប្រសាសន៍អ៊ីចឹង ។

ចុងបញ្ចប់តាមដែលខ្ញុំស្តាប់ ហើយសូមជម្រាបអង្គសវនាការទាំងមូលថា ខ្ញុំបាទ អង់គ្លេសមិនខ្លាំងទេ មិនយល់ទេ គេនិយាយខ្ញុំអត់យល់ទេ ក៏ប៉ុន្តែនៅចុងបញ្ចប់ហ្នឹង ខ្ញុំឮដូចជាពាក្យមួយ ដែលលោក អេតធេសាន់ មានប្រសាសន៍ថា “ឌុច នេះ មានឥទ្ធិពលទៅលើអចិន្ត្រៃយ៍មជ្ឈិម អូសទាញមជ្ឈិមឲ្យធ្លាក់ខ្លួនទៅក្នុងសភាពការណ៍” ដែលអង់គ្លេសគេហៅថា ប៉ារ៉ាណូយ៉ា បានន័យថា ធ្លាប់ខ្លួនទៅក្នុងផ្អើលកែង ធ្លាក់ខ្លួនទៅក្នុងត្រដេវវិច យកជើងទ្រមេឃ ។

[១២:០០:២១]

ខ្ញុំដូចជាចាំថាមានពាក្យហ្នឹង ។ បើសិនជាមានពាក្យ ពេលខ្ញុំស្តាប់ហ្នឹងភ្លាម ខ្ញុំនឹងដល់ព្រឹត្ត-

ការណ៍មួយនៅពេលដែល លន់ នល់ គាត់ធ្វើរដ្ឋប្រហារសម្តេច នរោត្តម សីហនុ ។ គាត់ជេរសម្តេច នរោត្តម សីហនុ តាមវិទ្យុហ្នឹងអស់ចិត្តហើយ ក៏ប៉ុន្តែមានឧបាយកលមួយទៀត គាត់ចង់ចាប់ ភួងម៉ាហ្គាំង ។ ចាស់ៗជំនាន់មុនប្រហែលស្គាល់ហើយ ភួងម៉ាហ្គាំង ជាពិសេស លោកជំទាវ មាស កេត លោកអញ្ជើញមកថ្ងៃក្រោយ លោកគង់ជ្រាបហើយ អ្នកណា ភួងម៉ាហ្គាំង ។ គាត់ចង់ចាប់ ភួងម៉ាហ្គាំង គាត់ចោទ ភួងម៉ាហ្គាំង ថារុញច្រានព្រះមហាក្សត្រឲ្យធ្លាក់ទៅក្នុងផ្លូវខុស ការភ័ន្តច្រឡំ *អាំងឌុយឡឺវ៉ែ អង់ណែរី* ។

ដូច្នេះ អេតឆេសាន់ គាត់មានប្រសាសន៍បែបនេះ ធ្វើឲ្យខ្ញុំនឹងទៅដល់បញ្ហានោះ ។ នេះខ្ញុំគ្រាន់តែលើកជូនអង្គសវនាការជ្រាបទេ ។ សរុបមកវិញស្នាដៃរបស់លោក អេតឆេសាន់ មានចំណុចល្អពីរ ខ្ញុំអត់បំភ្លេចទេ ចំណុចល្អធម្មតាអាចច្រើនទៀត តែចំណុចដែលទើសទាល់ ខ្ញុំនៅតែសុំរក្សាសិទ្ធិមានការតទល់មួយច្បាស់លាស់ ដោយមានឯកសារឈររៀងខ្លួន ។ ឧទាហរណ៍ ដូចជាចំនួនកម្លាំងទៅតាមអង្គ-ភាពនានាឲ្យមានឯកសារច្បាស់លាស់ដូចគ្នា ហើយមកប្រៀបធៀប ។ ហ្នឹងខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

សូមបញ្ចប់ដោយគោរព ។

**លោក ការ សាវុត្ថៈ**

**សៈ** សូមអរគុណ ហើយសូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ សុំឲ្យខាងមេធាវីការពារខាងអន្តរជាតិ ។

**ប្រធានអង្គជំនុំៈ**

ឥឡូវ យើងដល់ម៉ោងត្រូវសម្រាកពិសារអាហារថ្ងៃត្រង់ហើយ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសារថ្ងៃត្រង់ ហើយចំណែកឯមេធាវីការពារជនជាប់ចោទអន្តរជាតិដែលប៉ុនប៉ងក្នុងការសួរពាក់ព័ន្ធនឹងជនជាប់ចោទនឹងបញ្ហានេះ សូមលើកទៅពេលរសៀល ។ អង្គសវនាការលើកពេលរសៀល បន្តនៅម៉ោងមួយកន្លះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់ត្រឡប់មកវិញនៅល្ងាចនេះឲ្យបានមុនម៉ោងមួយកន្លះ ។ ហើយភាគីទាំងអស់ក៏ដូច្នោះដែរ សូមអញ្ជើញមកចូលរួមសវនាការតាមពេលវេលាកំណត់ដូចបានជម្រាបជូនខាងលើនេះ ។

*[សវនាការសម្រាកពីម៉ោង១២:០៣នាទី ដល់ម៉ោង១៣:៤៥ នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាស បន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ហើយកាលពីព្រឹកមិញ យើងបានសម្រាកត្រឹមមេធាវីការពារក្តីអន្តរជាតិ ដែលត្រូវឡើងសំណួរសួរពាក់ព័ន្ធជាមួយនឹងជនជាប់ចោទលើអង្គហេតុដែលកំពុងធ្វើសវនាការនេះ អំពីការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅស-២១ ។ អ៊ីចឹង ជាកិច្ចបន្តនេះ សូមប្រគល់វេទិកានេះជូនទៅលោកស្រីមេធាវីការពារជនជាប់ចោទ ដើម្បីអាចមានសំណួរសួរទៅជនជាប់ចោទពាក់ព័ន្ធនឹងអង្គហេតុ ដែលបានជម្រាបជូននេះ ។ សូមអញ្ជើញលោកស្រី ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន ។ មុននឹងលើកឡើងនូវបញ្ហាមួយចំនួន សំណួរមួយចំនួនដែលត្រូវសួរទៅលោក កាំង ហ្គេកអ៊ាវ ខ្ញុំសូមអនុញ្ញាតសុំឲ្យដើម្បីដាក់បញ្ចូលនូវដំណើរការនីតិវិធីនេះ នូវអង្គការលេខមួយដែលលោក ក្រេក អេតធេសាន់ បានកែតម្រូវនៅក្នុងកិច្ចសវនាការពេលមុន យើងបានសួរលោក ក្រេក អេតធេសាន់ ឲ្យបញ្ជាក់អង្គការលេខនោះ ដែលគាត់បានលើកឡើងនោះ ។ ដូច្នេះ ខ្ញុំសុំឲ្យអង្គការលេខទាំងស្រុងនេះ ដាក់បញ្ចូលទៅក្នុងផ្នែកនៃនីតិវិធីនៃសវនាការនេះ ។

លោកប្រធាន ខ្ញុំមានតារាងអង្គការលេខនេះ ដែលខ្ញុំអាចបង្ហាញជូនដល់អង្គសវនាការបាន ។

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំជឿថា ផ្នែកមួយនេះ បានពិនិត្យនៅក្នុងសវនាការសាធារណៈរួចហើយ ។ ខ្ញុំគ្រាន់តែចង់ដឹងថាតើមានការជំទាស់អ្វីទេទៅនឹងសំណើនេះ បើមិនដូច្នោះទេ យើងនឹងលើកឡើងមកពិភាក្សាបាន?

**លោក វីលៀម ស្មីត៖**

យើងមិនមានការជំទាស់ទេ ទៅនឹងសំណើរបស់មេធាវីនោះទេ ។

**លោក អាឡាំង វែ៌នណឺ៖**

បាទ, ហើយក៏មិនមានការជំទាស់ពីមេធាវី វែ៌នណឺ ដែរ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី! អញ្ជើញ ។

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

**ស៖** សូមអរគុណលោកប្រធាន ។ សំណួរទីមួយ ដែលខ្ញុំចង់សួរជនជាប់ចោទ ខ្ញុំត្រឡប់ទៅនឹងចំណុចមួយដែលការអះអាង ដែលលើកឡើងដោយលោក ក្រេក អេតធេសាន់ ដែលបានប្រកាសនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ដែលខ្ញុំពិនិត្យមើលប្រតិចារឹកនៅទំព័រ២៦ បន្ទាត់ទី៦ ដល់១៣ ខ្ញុំនឹងអានសេចក្តីថ្លែងការណ៍របស់លោក ក្រេក អេតធេសាន់ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើត ជាអាទិភាពរបស់ខ្លួនដើម្បីឲ្យគោរពវិន័យ ហើយបានទទូចឲ្យគោរព ហើយព្រមទាំងដូចជាការអនុវត្តដោយម៉ឺងម៉ាត់នូវមាគ៌ារបស់បក្ស ដូចជា ដូចដែលកំណត់ដោយអង្គការកំពូលរបស់បក្ស ហើយលោក អេតធេសាន់ បានបន្តទៀតថា ដូច្នេះហើយ ខ្ញុំអាចអះអាងថា នៅក្នុងទីកន្លែងជាច្រើន ហើយនិងគ្រប់ពេលវេលាកម្មាភិបាលបានធ្វើការងាររបស់ខ្លួនអស់ពីសមត្ថភាព ដើម្បីគោរពតាមមាគ៌ារបស់បក្ស ។ ហើយនៅក្នុងករណីផ្សេងទៀត ឲ្យបានយល់ជ្រាបច្បាស់ប៉ុនណា គឺអនុវត្តប៉ុណ្ណឹង ហើយលើខ្លឹមសារទាំងអស់នោះដើម្បីអនុវត្ត ។ អ៊ីចឹង តើលោកឯកភាពទៅលើការអះអាងហ្នឹងទេ លោកជនជាប់ចោទ?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមបញ្ជាក់ថា នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា កម្មាភិបាលគ្រប់ជាន់ថ្នាក់គិតគូរជានិច្ច អំពីភាពស្មោះត្រង់ ភាពគោរព និងជំនឿជាក់លើថ្នាក់ដឹកនាំ គ្មានដែលហ៊ានល្មើសនឹងស្អីទេ ។ នេះជារឿងពិតៗ ។ ខ្ញុំសូមបញ្ជាក់ត្រឹមប៉ុណ្ណេះឯង ។

**ស៖** ដូច្នេះ តើយើងអាចនិយាយទេថា លោកមានការយល់ដឹងបានច្បាស់ល្អ និងបានដឹងពីមាគ៌ានយោបាយរបស់បក្សបានច្បាស់លាស់ ហើយបានយល់ដឹងពីគោលការណ៍ទូទៅរបស់បក្សផងដែរ?

**ឆ៖** លោកប្រធានជាទីគោរព! នៅស-២១ គ្មានអ្នកណាយល់អំពីគោលការណ៍ និងមាគ៌ាបក្សជាជាងខ្ញុំទេ មានតែខ្ញុំទេដែលយល់ជាងគេ ។ ខ្ញុំពន្យល់បន្តិចទៅចុះ ខ្ញុំចូលបដិវត្តន៍ពី១៩៦៤ ខ្ញុំខំណាស់រៀនសូត្រមាគ៌ាបក្ស សូម្បីតែ ណាត ដែលចូលបដិវត្តន៍តំណាលគ្នា ប្រហែលគ្នាហ្នឹង ក៏គាត់មិនយកចិត្តទុកដាក់រៀនសូត្រមាគ៌ាអីដែរទេ មានតែខ្ញុំទេដែលចេះជាងគេ ។ ខ្ញុំសូមបញ្ជាប់ប៉ុណ្ណឹង គឺមានតែខ្ញុំទេដែលយល់ជាងគេ ។

[១៣:៥៤:១៤]

**ស៖** តើគឺមកពីចំណេះដឹងឬ ដែលនាំឲ្យលោកមានការយល់ដឹងបានច្បាស់ល្អ អំពីការណែនាំរបស់មេរបស់លោក និងអនុវត្តនូវការណែនាំអស់ទាំងនុ៎ង ដោយតាមវិធីដែលមានការបញ្ជាក់ពីការស្មោះត្រង់បំផុតចំពោះមេរបស់លោកនោះ?

**ឆ៖** សំណួរនេះ ខ្ញុំសុំឆ្លើយទទួលទាំងស្រុង គឺពិតអញ្ចឹង ។

**ស៖** លោកជឿថា នេះហើយឬដែលជាហេតុផល ដែលលោកអាចនៅរស់រានមានជីវិតនោះ?

**ឆ៖** បញ្ហានេះ វាជាបញ្ហាគន្លឹះដែលនាំឲ្យខ្ញុំនៅរស់រហូតទល់សព្វថ្ងៃ ។

**ស៖** តើលោកអាចពន្យល់បញ្ជាក់ ឲ្យបានក្បោះក្បាយជាងនេះបានទៀតទេ?

**ឆ៖** កត្តាដែលនាំឲ្យខ្ញុំរស់រហូតទល់សព្វថ្ងៃ បើតាមខ្ញុំពិនិត្យមានច្រើនដែរ ។ ទីមួយ គេប្រាប់ឲ្យធ្វើអីខ្ញុំធ្វើនុ៎ង មិនឲ្យលើសទេ ហើយក៏មិនឲ្យខ្វះ ។ ទីពីរ គ្រប់រឿងគ្រប់រ៉ាវយ៉ាងម៉េចក៏ដោយ ក៏ខ្ញុំមិនដែលលាក់ស្អីនឹងគេដែរ ។ ដូច្នេះ សរុបមកភាពស្មោះត្រង់ហើយនិងការខ្នះខ្នែងធ្វើការងារហ្មត់ចត់នៅតែជាមូលដ្ឋានសំខាន់ដែលនាំឲ្យខ្ញុំរស់បាន ។ អ្នកផ្សេងទៀតដែលនៅរស់ ហើយដែលខ្ញុំស្គាល់ក៏ប្រហែលជាមានគុណសម្បត្តិបែបនេះឯងដែរ ។ នេះខ្ញុំសុំបញ្ចប់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ នៅពេលដែលលោកត្រូវបានដឹកទៅទួលស្លែងកាលពីខែមេសា ឆ្នាំ២០០៨ ដើម្បីធ្វើការបង្ហាញឡើងវិញ ពេលហ្នឹងលោកចង់ធ្វើសេចក្តីថ្លែងការណ៍មួយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងនៅចំពោះមុខជនរងគ្រោះ ហើយនិងអ្នកដែលធ្លាប់ជាអតីតបុគ្គលិករបស់លោកមួយចំនួន ហើយនៅពេលនោះ លោកបាននិយាយថា នេះគឺឯកសារ D48 ដែលមានលេខ ERN ជាភាសាបារាំង 00181506, 00181508 ហើយនិងភាសាខ្មែរដែលមានលេខ 00181503 ដល់ 00181505 ហើយជាភាសាអង់គ្លេស 00198082 ដល់ 00198083 ។ លោកបានថ្លែងនៅថ្ងៃនុ៎ងថា "ខ្ញុំខឹងនឹងខ្លួនឯងខ្លាំងណាស់ ដែលសុខចិត្តធ្វើតាមគំនិតរបស់ពួកគេ ដូច្នេះហើយដែលខ្ញុំធ្វើតាមបញ្ជាឧក្រិដ្ឋរបស់គេទាំងងងឹតងងល់ ហើយខ្ញុំមានការសោកស្តាយខ្លាំងណាស់ ចំពោះអំពើហ្នឹង ។ ហើយដែលខ្ញុំចេះតែអនុវត្តតាមអ្វីដែលគេដាក់មកឲ្យខ្ញុំធ្វើរួមទាំង អំពីឧក្រិដ្ឋទាំងផង" ។ តើការថ្លែងការណ៍នេះមានជាចំណុច ជាជំហររបស់លោកទាក់ទងទៅនឹងអ្វីដែលត្រូវបានធ្វើឡើងកាលពីជាង៣០ឆ្នាំមុននោះឬ?

[១៣:៥៩:៤៣]

**ឆ៖** លោកប្រធានជាទីគោរព! ការសោកស្តាយ ការឈឺចាប់ វាអត់ស្រាកស្រាន្តទេ វាអត់ស្ងប់ទេ ។ វាអត់ស្ងប់ទេ ។ កាលណានឹកដល់រឿងចាស់ ខ្ញុំនៅស្មោះត្រង់នឹងវិប្បដិសារីរបស់ខ្ញុំជានិច្ច ។ ខ្ញុំមិនក្បត់វិប្បដិសារីរបស់ខ្ញុំ ខ្ញុំមិនលុបបំបាត់វិប្បដិសារីខ្ញុំនេះ ចោលទទេៗទេ ខ្ញុំចងចាំជានិច្ច ខ្ញុំឈឺចុកចាប់ណាស់ ខ្ញុំតែងតែនិយាយថា សម្រេចខុស គឺសម្រេចតែមួយដង្ហើមទេ តែរងទុក្ខ រងការឈឺចាប់ រងការសោកស្តាយមួយជីវិត ។

ដូច្នេះ ការដែលខ្ញុំឱនក្បាលចូលមកទទួលជំនុំជម្រះនេះ គឺជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលខ្ញុំធ្វើ ។ ខ្ញុំមិនឆ្លើយទម្លាក់កំហុសទាំងស្រុងនៅលើមេទេ ទៅលើមេខ្ញុំទេ ហើយក៏មិនទម្លាក់កំហុសទៅលើកូនចៅខ្ញុំដែរ មានន័យថា ខ្ញុំអត់គេចយករួចខ្លួនទេ ។ ឧក្រិដ្ឋកម្មនេះ ថ្វីត្បិតតែមានតួនាទីរបស់មេ ក៏វាមានតួនាទីរបស់ខ្ញុំដែរ នៅស-២១ឧក្រិដ្ឋកម្មទាំងអស់ខ្ញុំទទួលតែម្នាក់ឯង គ្មានគេច គ្មានទម្លាក់កំហុសទៅលើកូនចៅទាល់តែសោះ កំហុសឧក្រិដ្ឋកម្មទូទាំងប្រទេស ដូចដែលខ្ញុំបានថ្លែងការណ៍នៅពេលបើកសវនាការនេះអ៊ីចឹង ។ ខ្ញុំទទួលខុសត្រូវខាងផ្លូវចិត្ត ចំពោះការវិនាសហិនហោចរបស់ប្រជាជនកម្ពុជាយើងទាំងមូល ខ្ញុំរំលែកទុក្ខវេទនា សុំរំលែកទុក្ខ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សុំទោសលោកប្រធាន ខ្ញុំសុំកាត់បន្តិច យើងបានពិភាក្សាកាលពីរសៀលនេះ អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងការអនុវត្ត ។ ហើយអ្វីដែលជនជាប់ចោទកំពុងតែនិយាយគឺជាសេចក្តីថ្លែងការណ៍ចុង ឬក៏ជាសេចក្តីថ្លែងការណ៍ ដែលវាមិនស៊ីគ្នាទៅនឹងអង្គហេតុកំពុងតែធ្វើនៅក្នុងសវនាការ ។ ដូច្នេះ ខ្ញុំចង់ឲ្យយើងធ្វើការពិភាក្សាតែទៅលើអង្គហេតុ ដែលយើងត្រូវពិភាក្សាគ្នា ហើយសុំឲ្យមេធាវីជនការពារក្តីនោះ សួរជនជាប់ចោទទៅលើអង្គហេតុនេះ ។ សូមអរគុណ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកមេធាវី កាលពីមុនលោកបានសួរសំណួរដល់ជនជាប់ចោទ យើងមិនឡើងកាត់លោកស្រីទេ ។ លោក កាំង ហ្កេកអ៊ាវ នៅក្នុងដំណើរការពន្យល់នូវចំណុចដ៏សំខាន់បំផុតមួយ ហើយខ្ញុំមិនដឹងថាតើលោកស្រីមានសិទ្ធិអ្វី ក្នុងការកាត់នូវការពន្យល់របស់គាត់នេះទេ? ដូច្នេះ ខ្ញុំនឹងសូមអរគុណដល់លោកចៅក្រម បើសិនលោកចៅក្រមអនុញ្ញាតឲ្យគាត់បន្តទៀត ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៧:១៣]

**ប្រធានអង្គជំនុំ៖**

មតិជំទាស់របស់លោកមេធាវី ស្ទួតហ្សីនស្គី តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ អង្គជំនុំជម្រះបដិសេធលើមតិជំទាស់នេះ ហើយអនុញ្ញាតឲ្យមេធាវីការពារក្តីអាចបន្ត នូវសំណួររបស់លោកស្រីពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ ពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលដាក់មកពិភាក្សាដេញដោលនេះគឺការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជានៅស-២១ ។

**ជនជាប់ចោទ៖**

**ឆ៖** ខ្ញុំសូមអនុញ្ញាតបន្តទៅទៀត។ ការអនុវត្តនយោបាយនេះនៅទូទាំងប្រទេស ក៏ដូចជានៅស-២១ ។ នៅស-២១ វាមានឧក្រិដ្ឋកម្មទៅលើមនុស្ស យ៉ាងតិចណាស់ក៏មួយម៉ឺនពីរពាន់បីរយប៉ែតសិប (១២៣៨០)នាក់ដែរ នៅទូទាំងប្រទេស ខ្ញុំមិនទាន់មានតួលេខច្បាស់លាស់ទេ តែខ្ញុំជឿថាជាងមួយលាននាក់ នេះជាការអនុវត្តមាគ៌ានយោបាយខុស ។ ខុសនេះ ខ្ញុំខុសនឹងគេដែរ មិនមែនរឿងមេតែម្នាក់ឯងទេ មានតួនាទីរបស់ខ្ញុំនៅក្នុងនុំង ទូទាំងប្រទេស តួនាទីរបស់ខ្ញុំក្នុងថ្នាក់ជាសមាជិកបក្សម្នាក់ ខ្ញុំអត់ចោលទេ ការទទួលស្គាល់កំហុសនេះ កំហុសនេះ គឺពិតជាកំហុសក្នុងការអនុវត្តមាគ៌ានយោបាយហើយ ។

នៅស-២១ កំហុសនេះកំហុសនៃការអនុវត្តមាគ៌ានយោបាយរបស់បក្ស ដែលជាមាគ៌ាមហាឧក្រិដ្ឋ ដូចខ្ញុំបានបញ្ជាក់ព្រឹកមិញអ៊ីចឹង ឧក្រិដ្ឋជាងមាគ៌ារបស់ពួកអាក្រុមបួននាក់នៃមហាបដិវត្តន៍វប្បធម៌ចិនតទៅ ធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតមនុស្សជាងមួយម៉ឺននាក់ ។ ខ្ញុំចាំអត់ភ្លេចទេ រឿងអស់ទាំងនេះ ។

នេះសូមសារភាពជូនតុលាការ ជូនជាតិប្រជាជនកម្ពុជា ឲ្យលោកយល់បញ្ហានេះ ។ នេះខ្ញុំអត់ចោលទេវិប្បដិសារី ។ វិប្បដិសារី គឺក្នុងការអនុវត្តមាគ៌ានយោបាយខុសនេះឯង នេះខ្ញុំសុំបញ្ចប់ប៉ុណ្ណេះ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកចៅក្រមជាទីគោរព! ដោយមានការអនុញ្ញាតពីលោកចៅក្រម ខ្ញុំសុំស្នើថា ការពិនិត្យមើលនូវកំណត់ដកស្រង់ពីរ គឺថា វីដេអូ អំពីនិយាយអីការសម្តែងឡើងវិញនៅទួលស្លែងនោះ ហើយនៅក្នុងសេចក្តីដកស្រង់នេះ ខ្ញុំមានចំណុចមួយចំនួន ខ្ញុំចង់សួរសំណួរទៅជនជាប់ចោទ អំពីសេចក្តីដកស្រង់ពីរនេះដែលនឹងប្រើពេលតែដប់ប្រាំមីនុតទេ ។

**ប្រធានអង្គជំនុំ៖**

ភាពពាក់ព័ន្ធទៅនឹងអង្គហេតុនឹងយ៉ាងដូចម្តេចទៅ? លោកស្រីមេធាវីអាចពន្យល់បានទេ? អំពីការប៉ុនប៉ងដើម្បីបញ្ចាំងនូវវីដេអូ ដែលបានសម្តែងឡើងវិញនៅស-២១នោះ? អាចពន្យល់បានទេអំពីភាពពាក់ព័ន្ធនៃការប៉ុនប៉ង ដែលលោកស្រីចង់លើកយកបញ្ហានេះមកពិភាក្សានេះ ពីព្រោះវាអាចក្រែងលោច្រឡំគ្នា រវាងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្ត ហើយនិងប្រតិបត្តិការស-២១ ។ នេះដើម្បីឲ្យបញ្ជាក់ឲ្យច្បាស់លាស់ កុំឲ្យវាការលើកយកមកដេញដោលទៅអង្គហេតុនុំង ត្រូវជាអង្គហេតុដែលត្រូវលើកដេញដោលនៅប្រតិបត្តិការស-២១ វានាំមានការយឺតយាវ ហើយវាខុសជាមួយនឹងអង្គហេតុ ។ តាមការយល់ដឹងរបស់ខ្ញុំ ឃើញថា ការបញ្ជាក់ឡើងវិញនូវខ្សែភាពយន្ត ដែលបានសិក្សាកន្លង

មកនេះ គឺមានអត្ថន័យធំធេងទាក់ទិនជាមួយនឹងប្រតិបត្តិការ ជាអង្គហេតុមួយដែលយើងនឹងធ្វើបន្ទាប់ពីអង្គហេតុនៃជម្លោះប្រដាប់អាវុធ ហើយអង្គហេតុនេះយើងបានបំបែកជាអង្គហេតុតូចៗជាច្រើន ដែលអង្គជំនុំជម្រះប្រកាសជម្រាបជូនដំណឹង នូវបន្ទាប់ពីដំណើរការសវនាការ លើអង្គហេតុជម្លោះប្រដាប់អាវុធចប់ ដើម្បីឱ្យភាគីទាំងអស់មានការរៀបចំទុកជាមុន ដើម្បីចូលរួមនៅក្នុងដេញដោលហ្នឹងឱ្យវាល្អិតល្អន់ ហើយមិនច្រំដែលនោះ ។

[១៤:១២:៤៧]

**លោកស្រី ម៉ារីប៉ូល កានីហ្សារះ**

លោកប្រធាន ជាទីគោរព! សំណើគឺចេញមកគឺតាមលំដាប់លំដោយ ទៅនឹងសំណួរដែលខ្ញុំបានសួរពីខាងដើម ខ្ញុំបានយោងទៅរកសេចក្តីដកស្រង់ ដែលជនជាប់ចោទបាននិយាយ អំពីការអនុវត្តនូវនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅស-២១ ។ ហើយមានសេចក្តីថ្លែងការណ៍ ដែលយោងទៅរកនូវអារម្មណ៍ នៅពេលដែលធ្វើការសម្តែងឡើងវិញ ហើយអារម្មណ៍របស់គាត់ហ្នឹង គឺទាក់ទងទៅនឹងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅទីនោះឯង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើលោកអាចពន្យល់យើងថែមទៀតទេ ថាតើអ្វី តើវីដេអូនេះនឹងបង្ហាញពីអ្វី ឬក៏វាទាក់ទងទៅអ្វីដែលយើងធ្វើសវនាការទីនេះហើយឬនៅ? ដោយយើងបានធ្វើសវនាការជនជាប់ចោទ អំពីការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅស-២១ ថាតើអ្វីជាតម្លៃបន្ថែមទៅលើវីឌីអូហ្នឹង សម្រាប់ឱ្យយើងចៅក្រមអាចនឹងពិនិត្យមើលបាន បន្ថែមលើអ្វីដែលលោកស្រីមានហើយ ។

[១៤:១៤:២១]

**លោកស្រី ម៉ារីប៉ូល កានីហ្សារះ**

តាមគំនិតខ្ញុំ វីដេអូនេះបានថតឡើងនៅកាលៈទេសៈដ៏ពិសេសមួយ ទៅលើរូប កាំង ហ្គេកអ៊ាវ ដែលបានសម្តែងឡើងវិញ នៅកន្លែងជាក់លាក់មួយចំនួននៅក្នុងស-២១ ។ ហើយនៅក្នុងវីដេអូនេះ យើងអាចនឹងឃើញថាគាត់បានធ្វើសេចក្តីថ្លែងការណ៍ដែលគាត់និយាយថា គាត់បាន មានវន្តត់ណាស់ដែលបានទៅស-២១ ជាលើកក្រោយនេះ ហើយយើងចង់ពិនិត្យឃើញគាត់ថា តើអារម្មណ៍របស់គាត់នោះយ៉ាងដូចម៉េច នៅពេលដែលគាត់បានទៅកន្លែងហ្នឹងម្តងទៀត? ហើយជាពិសេសជាទីតាំងនៅ ស-២១ ថាតើគំនិតហ្នឹង អាចបន្ថែមតម្លៃអ្វីទៅនឹងសេចក្តី ថ្លែងការណ៍ដែលគាត់ធ្វើថ្ងៃនេះទេ? ហើយនៅទីនេះ

នៅក្នុងអង្គជំនុំជម្រះនេះ ហើយនេះជាចំណុចសំខាន់ណាស់ ។ សវនាការនេះ គឺជាសវនាការសាធារណៈ ហើយក៏ជាឱកាសដ៏សំខាន់មួយ ដើម្បីមានលទ្ធភាពក្នុងបង្ហាញនូវការសម្តែងនូវអារម្មណ៍ ឬក៏ប្រតិកម្មរបស់គាត់នៅពេលដែលគាត់ទៅពិនិត្យទីតាំង ស-២១ នៅក្នុងពេលសម្តែងនោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណលោកប្រធាន ។ សូមអរគុណចំពោះសេចក្តីពន្យល់នេះ ខ្ញុំៗគិតថា ការសម្តែងមតិអារម្មណ៍របស់ជនជាប់ចោទ គឺជាបញ្ហាសំខាន់សម្រាប់តុលាការដើម្បីពិចារណាហើយ ។ ប៉ុន្តែ ហើយខ្ញុំក៏យល់ឃើញដែរថា វាអាចនឹងមានជាពេលសមស្រប ដើម្បីឲ្យនឹងលើកទិដ្ឋភាពនេះនូវឯកសារនៅក្នុងសំណុំរឿងដូចជា នៅក្នុងពេលសវនាការអំពីអត្តចរិតរបស់ជនជាប់ចោទ ។ ប៉ុន្តែ ខ្ញុំគិតថា យើងមិនឃើញថា វាមានការពាក់ព័ន្ធទាំងស្រុងទេ ចំពោះការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា តើលោកស្រីមានមតិយោបល់អីបន្ថែមទៀតទេ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ប៉ុន្តែ ខ្ញុំយល់ថា សេចក្តីដកស្រង់ដែលខ្ញុំបានសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញនៅក្នុងសវនាការនេះ គឺទាក់ទងជាមួយនឹងចំណុចមួយដែលជនជាប់ចោទនិយាយអំពីការអនុវត្តគោលនយោ-បាយបក្សកុម្មុយនីស្តកម្ពុជានៅស-២១ ។ អាចនឹងចេញមកពីការពិចារណានេះហើយ ចំណុចនៃការពិភាក្សានោះ គឺថានឹងមានតម្លៃបើសិនជាយើងបានមើលសេចក្តីដកស្រង់វីឌីអូនេះ នៅពេលនេះ ។ ហើយបើសិនយកទៅកន្លែងផ្សេង ពេលផ្សេងទៀត ក៏អាចនឹងបន្ថែមតម្លៃទៅខ្លឹមសារអ្វីដែលសវនាការនេះដែរ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៩:៥១]

**ប្រធានអង្គជំនុំ៖**

ពាក់ព័ន្ធនឹងសំណើសុំរបស់មេធាវីការពារក្តី ដែលបានលើកឡើងនេះ អង្គជំនុំជម្រះសូមមានការពាក់ព័ន្ធទៅនឹងអ្នកជំនាញខាងសោតទស្សន៍នេះ ថាតើអាចប្រើពេលវេលាប៉ុន្មានទៅក្នុងរឿងដែលលើកឡើងដោយ ស្នើសុំដោយមេធាវីការពារក្តីនេះ?

សុំមន្ត្រីតុលាការជួយសម្របសម្រួលបញ្ហានេះផង ។ ហើយដោយឡែក បញ្ហាចំពោះអ្នកមេធាវីការពារក្តី តើមានឯកសារហ្នឹង មានអីជាសម្គាល់ច្បាស់លាស់ទេ? ដើម្បីឱ្យខាងផ្នែកសោតទស្សន៍ហ្នឹង គេអាចពិនិត្យលើលទ្ធភាពក្នុងការរៀបចំឯកសារនេះឲ្យបាន ហើយអាចបញ្ជាក់ទេថា ពិតជាចំណាយពេលតែត្រឹមដប់ប្រាំមីនុតនោះ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន ។ សេចក្តីយោងទៅលើឯកសារនោះ គឺ D48/2 ។ លេខERN ជាភាសាខ្មែរ 00210051-00210051 ។ សេចក្តីដកស្រង់ទាំងពីរនេះក្នុងចំណោមមួយនេះ គឺមានតែបីមីនុតហាសិបបួនសឺហ្គុង មួយទៀតគឺថាបួនមីនុតសាមសិបប្រាំបួនសឺហ្គុង ។

អ៊ីចឹង សរុបទៅ មួយដប់បួនមីនុត មួយបីមីនុត អ៊ីចឹងប្រហែលជាដប់ប្រាំបីមីនុតប៉ុណ្ណឹងទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

បញ្ហាមួយទៀត លោកស្រីមេធាវីការពារ សេចក្តីដកស្រង់ តើមានបង្ហាញពីសាក្សីណាដែលមិនទាន់បានផ្តល់សក្ខីកម្មដែរឬទេ? ពីព្រោះថាមកដល់ពេលនេះ យើងនៅប្រើលេខរហស្សនាម ហើយយើងមិនទាន់ផ្សាយជាសាធារណៈនៅឡើយ ។ ដែលអាចនឹង គឺថា អាចជាមូលហេតុមួយដើម្បីនឹងយោងពន្យារទៅធ្វើនៅពេលក្រោយវិញ ។

**លោក អាឡាំង វែនណឺ៖**

ហើយខ្ញុំអភ័យទោសដែលថា សុំកាត់ដែលថា ដើមបណ្តឹងរដ្ឋប្បវេណី គឺថាយើងនៅប្រើរហស្សនាម ជាឈ្មោះសម្ងាត់នៅឡើយទេ មិនទាន់ប្រកាសទេ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ខ្ញុំគិតថា គឺថាពាក្យដែលលោកស្រីរំឭកហ្នឹង គឺខ្ញុំបានកត់សម្គាល់ ហើយខ្ញុំមិនបានពិនិត្យលម្អិតដូចចំណុចលោកស្រីចៅក្រមលើកឡើងនោះទេ ។

[១៤:២៣:២៩]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

គិតថា អ៊ីចឹងហើយទាក់ទងទៅនឹងយើងអាចនឹងកាត់ការផ្សាយបន្តផ្ទាល់ហ្នឹង គឺថាអាចនឹង

ប៉ះពាល់ទៅគោលការណ៍សាធារណៈ ឬក៏អាចនឹងពន្យារពេលសវនាការ ។ អ៊ីចឹង យើងទុកចំណុចនេះទៅធ្វើការបង្ហាញនៅពេលក្រោយដំណាក់កាលណាមួយ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ខ្ញុំគិតថា ត្រូវហើយ គប្បីតែផ្អាកការផ្សាយវីឌីអូ ដែលលោកស្រីបានលើកឡើងហ្នឹងបាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះបញ្ហាដែលប៉ុនប៉ងស្នើសុំហ្នឹង គឺមេធាវីបានសុំដកវិញហើយ ហើយយល់ព្រមថានឹងលើកទៅបញ្ចាំងជូនជានៅអង្គជំនុំជម្រះនេះ នៅពេលកាលៈទេសៈសមស្របណាមួយនៅពេលខាងមុខ។ ហើយជាបន្តនេះ តើលោកស្រីមេធាវីមានសំណួរអ្វីពាក់ព័ន្ធត្រូវសួរដល់ជនជាប់ចោទថែមទៀតទេ? បើសិនជាមានសូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន ដែលថាមេធាវីការពារមិនមានសំណួរអ្វីថែមទៀត សួរទៅជនជាប់ចោទទេ ។ សូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ ឥឡូវនេះ យើងដល់ការធ្វើសវនាការលើអង្គហេតុនៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ឃើញថាដល់ទីបញ្ចប់ហើយ ។ អ៊ីចឹង គឺយើងឈានចូលទៅអង្គហេតុមួយទៀត គឺអង្គហេតុនៃជម្លោះប្រដាប់អាវុធ ដែលក្នុងអំឡុងពេលសវនាការកន្លងមកនេះយើងបានធ្វើសវនាការចំពោះអ្នកជំនាញ ណាយ៉ាន់ ចាន់ដា រួចហើយអំពីបញ្ហានេះ ។ ប៉ុន្តែ អង្គសវនាការទាំងមូលមិនទាន់បានសួរដេញដោលជនជាប់ចោទអំពីអង្គហេតុនៃជម្លោះប្រដាប់អាវុធនោះទេ ។ អ៊ីចឹង ចាប់ពីពេលនេះតទៅ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីថា យើងចាប់ផ្តើមធ្វើសវនាការលើអង្គហេតុនៃជម្លោះប្រដាប់អាវុធ ដោយមានការសួរដេញដោលចំពោះជនជាប់ចោទអំពីអង្គហេតុនេះ ។

**ស៖** ជនជាប់ចោទអាចត្រៀមនូវឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងអង្គហេតុនេះហើយឬនៅ?

[១៤:២៦:៤៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានត្រៀមជាទិដ្ឋភាពរួមខ្លះហើយ ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណោះ ។

**ស៖** នៅកាលពីលើកមុន គឺជនជាប់ចោទបានឆ្លើយដោយ-- អង្គជំនុំជម្រះបានបង្ហាញអំពីកថាខណ្ឌទី២៨ ដែលបង្ហាញកថាខណ្ឌទី២៨ នេះគឺជនជាប់ចោទមិនជំទាស់ទៅនឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ ។

បញ្ហាសំណួរដែលយើងចង់សួរទៅជនជាប់ចោទថា តើថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ គឺជាពេលស្របគ្នាមួយទៅនឹងសេចក្តីថ្លែងការណ៍ ដែលបានធ្វើឡើងតាមវិទ្យុភ្នំពេញ ដែលនិយាយអំពីការឈ្លានពានរបស់វៀតណាមមកលើប្រទេសកម្ពុជា និងជាការប្រកាសនូវការផ្តាច់ទំនាក់ទំនងផ្នែកការទូតជាបណ្តោះអាសន្នជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ មែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ។ រឿងនេះ ពិតមែន សូមជម្រាបប៉ុណ្ណោះ ។

**ស៖** តើនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ គឺជាពេលដែលសេចក្តីថ្លែងការណ៍ធ្វើឡើងតាមវិទ្យុភ្នំពេញដែលនិយាយអំពីការចូលលុកលុយរបស់វៀតណាមមកប្រទេសកម្ពុជា ព្រមគ្នានឹងការប្រកាសនូវការផ្តាច់ចំណងផ្នែកការទូតជាបណ្តោះអាសន្នជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ពិតមែនដែរឬទេ?

**ឆ៖** ជម្រាប្រសាសន៍លោកប្រធាន រឿងនេះពិត ។

[១៤:២៩:៤២]

**ស៖** តើលោកបានដឹងដែរឬទេ អំពីការផ្តាច់នូវទំនាក់ទំនងការទូតជាបណ្តោះអាសន្នរវាងកម្ពុជាប្រជាធិបតេយ្យជាមួយនិងសាធារណរដ្ឋសង្គមនិយមវៀតណាម? តើប្រព្រឹត្តទៅតាមរបៀបណា? តាមរយៈវិទ្យុ ឬតាមរយៈការប្រាប់ពីថ្នាក់លើរបស់លោក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វិទ្យុខ្ញុំបានស្តាប់ ប៉ុន្តែ បើសិនជានិយាយឲ្យវែង ខ្ញុំសូមជម្រាបដោយស្មោះត្រង់ថា ខ្ញុំមិនសូវចាំព្រឹត្តិការណ៍នេះទេ ។ តែខ្ញុំអត់បដិសេធទេ វាពិតជាមានតែខ្ញុំវាភ្លេច ។ រឿងដែលខ្ញុំយកចិត្តទុកដាក់មែនទែន គឺថ្ងៃ៦ មករា ១៩៧៨ ពេលដែលថ្ងៃ ប៉ុល ពត គាត់ទៅបុរីកីឡាធ្វើបុណ្យមួយដែលគាត់ឲ្យឈ្មោះថា បុណ្យរំឭកជ័យជម្នះកងទ័ពបដិវត្តន៍កម្ពុជាទៅលើកងទ័ពវៀតណាម ។ នេះខ្ញុំចាំជាងសេចក្តីប្រកាសតាមវិទ្យុ ប៉ុន្តែ ដល់លោកប្រធានមានប្រសាសន៍ថាមានសេចក្តីប្រកាសតាមវិទ្យុពិត ថាឲ្យចាំពីមុនមក គឺអត់ទេ ។

ដូច្នេះសរុបមកវិញ ដឹងតាមវិទ្យុ តែដល់ចាំមែនទែន គឺថ្ងៃ៦ មករា នុ៎ងឯង ។ នេះសូមគោរព

វាយការណ៍ជូនប៉ុណ្ណោះ ។

**សៈ** លោកនៅចាំបានទេថា អំពីការមកដល់នៃជនជាតិវៀតណាមលើកដំបូងមកដល់មន្ទីរ ស-២១ ហ្នឹងនៅក្នុង ប្រហែលជានៅក្នុងខែ ឆ្នាំណាទៅ?

**ឆៈ** រឿងនេះវាមានពីរដំណាក់ ។ ដំណាក់ទីមួយ ពីមុនមកវាមកយូរៗមួយ មួយ ពីរៗ អ៊ីចឹង ទាហានវៀតណាមក៏មានមកដែរ មួយ ពីរៗតិចតួចណាស់ ។ ក៏ប៉ុន្តែ ដំណាក់ទីមួយនេះ គ្មានបញ្ហាមក ឲ្យយកសំឡេងផ្សាយវិទ្យុទេ ។ ក្រោយដែលថ្ងៃ៦ មករា ទើបយកសំឡេងផ្សាយវិទ្យុ ។ ហើយខ្ញុំនៅចាំ បានថា សំឡេងមនុស្សម្នាក់ដែលខ្ញុំយកផ្សាយវិទ្យុមុនគេ គឺឈ្មោះ វ៉ ឌឹងង៉ោ អតីតទាហានសក្តិពីរជើង ទឹករបស់រដ្ឋាភិបាលសាធារណរដ្ឋវៀតណាមពីមុននោះដែលគេហៅថា ដែលមានប្រធានាធិបតីឈ្មោះ ង្វៀង យ៉ាំងធីវ ហើយអនុសេនាបតីឈ្មោះ ង្វៀង កៅគី ។ ហើយខ្មែរហៅភ្ជាប់ថា ទ័ពធីវគី ។ គាត់ចូល មកៗយកការណ៍ ហើយបក្សកុម្មុយនីស្តកម្ពុជាចាប់បាន យកគាត់មកផ្សាយវិទ្យុដំបូងគេហើយ ។ នេះខ្ញុំ ចាំបានអ៊ីចឹង នេះសូមជម្រាបលោកប្រធានប៉ុណ្ណឹង ។

**សៈ** និយាយពីរយៈពេលវិញ លោកអាចនឹកឃើញទេថា កាលមកដំបូងគេបង្អស់នៃជនជាតិ វៀតណាមដែលត្រូវបញ្ជូនមកកាន់ មកដល់មន្ទីរស-២១ ហ្នឹងនៅក្នុងអំឡុងឆ្នាំណា? ឬក៏ក្នុងអំឡុងខែ ណា ឆ្នាំ១៩៧៦ ឬក៏១៩៧៧? ពីព្រោះនេះ វាមានកាលប្បវត្តិមួយដែលមានការប្រែប្រួលដោយសារ លោកបានទទួលស្គាល់អំពីអាទិភាពនៃជម្លោះនេះដែលនៅថ្ងៃ៣១ ខែធ្នូ ឆ្នាំ១៩៧៧ ។ ប៉ុន្តែ នៅក្នុងនេះក៏ មានឯកសារដែលមានបង្ហាញអំពីវត្តមាននៃជនជាតិវៀតណាមមកដល់ស-២១ នៅក្នុងឯកសារនេះគឺ មានដំណាក់កាលច្រើន ប៉ុន្តែ ខ្ញុំចង់ដឹងពីរឿងមនុស្ស ជនជាតិវៀតណាមដែលចាប់បញ្ជូនដល់ ស-២១ មុនគេបង្អស់នោះ នៅក្នុងអំឡុងពេលប្រហែលជាឆ្នាំណា តាមដែលលោកចងចាំ?

[១៤:៣៤:០៥]

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន អាណិកជនវៀតណាមនៅកម្ពុជាមាន ។ ក្រោយ ១៧ មេសា មានចាប់ពួកនុ៎ងមកដែរ ។ នៅពេលណាដែលមានបាតុភាពតទល់ជាមួយគេៗចាប់ ហើយទន្ទឹម នេះ ក៏មានចាប់មនុស្សដែលចូលមកទឹកដីខ្មែរជាប្រជាជនវៀតណាមក្តី ជាអតីតទាហានរដ្ឋការចាស់ របស់សាធារណរដ្ឋវៀតណាមក្តី គឺចូលមកមានចាប់មែន ។ ដូច្នេះ យើងខ្ញុំមិនចាំទេ សូមជម្រាប ដោយស្មោះ ត្រង់ពឹងលើបញ្ជីដែលនៅសល់នៅ ស-២១ ។ ក៏ប៉ុន្តែ លក្ខខណ្ឌដែលមកដូចខ្ញុំបានជម្រាប អ៊ីចឹង គឺមកយូរៗ មួយពីរប៉ុណ្ណឹងទេ ។ បញ្ជីវាបញ្ជាក់ហើយ ខ្ញុំទទួលស្គាល់តាមបញ្ជី ហ្នឹងសូមបញ្ជាក់

ជូនប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទដែរឬទេ? អំពីអង្គហេតុនៃជម្លោះប្រដាប់អាវុធនេះ? បើមានសូមអញ្ជើញ ។ អញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណលោកប្រធាន។ លោក កាំង ហ្កេកអ៊ាវ លោកបាននិយាយថា លោកមិនជំទាស់នឹងទិដ្ឋភាពដែលថា មានជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៧៧ មក ប៉ុន្តែ លោកក៏បាននិយាយដែរថា លោកនៅចាំព័ត៌មានមួយចំនួននូវព្រឹត្តិការណ៍ដែលលោកប្រធានទើបតែសួរលោកអម្បាញ់មិញនេះ ។ តើសម្រាប់ហេតុផលហ្នឹងឬ ដែលលោកមិនព្រមទទួលឯកភាពថាមានជម្លោះប្រដាប់អាវុធមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំអត់មានប្រកែកទេរឿងនេះ ប៉ុន្តែ ជាក់ស្តែងរឿងបក្សកុម្មុយនីស្តកម្ពុជា ហើយនិងបក្សកុម្មុយនីស្តវៀតណាមវៃគ្នាទៅវិញទៅមកយូរហើយ ។ ហ្នឹងជម្រាបដោយស្មោះត្រង់ ខ្ញុំឃើញនឹងភ្នែកនៅខាងស្រុកស្អាង កោះធំ លើកដែក ពីខែ៩ រហូតដល់ខែ១២ ឆ្នាំមួយពាន់ប្រាំបួនរយ.. ពីខែ៩ បក្សពលករវៀតណាមគេមកចាត់តាំងរដ្ឋអំណាចនៅនុំង គេសម្លាប់ប្រជាជនកម្ពុជាដែលទារពន្ធឲ្យបក្សកុម្មុយនីស្តវៀតណាម (សុំទោស) ច្របូកច្របល់ណាស់ ខ្ញុំសូមនិយាយម្តងទៀត ខ្ញុំច្រឡំច្របូកច្របល់ហើយ។

ខែ៩ គណៈកម្មាធិការខេត្តអាងយ៉ាង នៃបក្សកុម្មុយនីស្តវៀតណាមចូលមកចាត់តាំងរដ្ឋអំណាចនៅស្អាង កោះធំ លើកដែក និងកៀនស្វាយ ឈ្មោះហៅថា គណៈកម្មាធិការតំបន់៦២ ។ ពេលនុំងទីមួយ គេបាញ់សម្លាប់ខ្មែរម្នាក់ឈ្មោះ អ៊ឹង អែម ជាអ្នកទារពន្ធ គេបាញ់សម្លាប់នៅដងទន្លេបាសាក់ក្នុងដងទន្លេបាសាក់នេះ។ ហើយទីពីរ គេបាញ់សម្លាប់បក្សជន បក្សពលករវៀតណាមម្នាក់ឈ្មោះ ចៅកែន ដែលប្រាថ្នារត់ចេញពីនុំងមកចូលជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា ។ ទន្ទឹមនេះ គេចាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា គឺពួកយើងខ្ញុំនេះដែលចុះទៅពីភ្នំពេញដាក់គុកហូរហែ ។ ដូច្នេះ ទំនាស់ខ្មែរហើយនិងវៀតណាមវាមានជារូបភាពយ៉ាងនេះ យ៉ាងនោះ សូម្បីតែនៅក្នុងស្រុកខ្ញុំនៅឯស្មោងឯណោះរវាងខែ មិថុនា ១៩៧០ ទាហានវៀតណាមគេទៅវៃរដ្ឋាភិបាល គេទៅវៃអង្គភាពនៃរដ្ឋាភិបាល លន់ នល់នៅនុំង សម្លាប់គ្រូបង្រៀនអស់ប្រាំបួននាក់ ហើយចាត់តាំងកសិករមានម្នាក់ឲ្យធ្វើប្រធានរណសិរ្ស ក៏គេ

ចាត់ចែងទាំងអស់ ។ នេះរឿងដែលយើងខ្ញុំដឹងនឹងត្រចៀក ហើយក៏ឃើញនឹងភ្នែក នៅខាងស្អាងកោះធំ ។ ដូច្នេះតៗមកនេះ ដូចខ្ញុំបានជម្រាបអ៊ីចឹង រឿងខ្មែរ ហើយនិងវៀតណាមវាជារឿងទំនាស់រ៉ុាំរ៉ៃ ហើយមានលក្ខណ:ស្លាប់រស់ ។ ដូច្នេះ យើងខ្ញុំមិនសូវបានគិតទេ ជឿជាក់ថា ប៉ុល ពត គេចេះការពារបូរណភាពទឹកដី ។ រឿងរ៉ៃទៅ រ៉ៃមក បញ្ជូនមនុស្សមកដល់ ស-២១ អី ខ្ញុំគិតថាជារឿង ពាលស៊ីពាល រ៉ៃទៅរ៉ៃមក ។ ក៏ប៉ុន្តែ រឿងដែលគេប្រកាសជាផ្លូវការមាន ខ្ញុំដឹង ដូចខ្ញុំបានឆ្លើយជម្រាបលោកប្រធានអ៊ីចឹង ។ មុនថ្ងៃ៦ មករា ហ្នឹង ខ្ញុំទទួលបញ្ជាឲ្យសួរចម្លើយបន្តិចបន្តួចហើយរ៉ៃចោល កម្ទេចមនុស្សទាំងឡាយណាដែលចាប់មក ព្រោះគេចាត់ទុកថាខ្មាំងហើយ ។ ឯចំណែកក្រោយ ៦ មករា នេះមានប្លែកត្រង់ដែលវាយកទៅថតខ្សែអាត់សម្រាប់ផ្សាយតាមវិទ្យុជាតិ វិទ្យុកម្ពុជាភ្នំពេញនោះផង ។ ហ្នឹងប្លែកអ៊ីចឹង ខ្ញុំឃើញប្លែកអ៊ីចឹង ។ ដូច្នេះ បញ្ជាតែមួយទេពីហូរ ពីហែមក ឲ្យតែជនជាតិវៀតណាមក៏ដោយ ស្អីក៏ដោយឲ្យតែ គេចាប់បញ្ជូលមកស-២១ៗ ត្រូវវាយសួរចម្លើយរួចហើយកម្ទេច ។ ហើយក្រោយ ៦ មករា មិនត្រឹមតែវាយសួរចម្លើយកម្ទេចទេ យកថតខ្សែអាត់ មិនត្រឹមថតខ្សែអាត់ទេ ថតរូបយកទៅប្រជុំនៅបានដុងទៀតនៅ ហ្សាកាតា ទៀត ហើយទាំងថតកុនផង។ នេះវាជាទិដ្ឋភាពដែលយើងខ្ញុំចំណាំបាន ។

សរុបមក ខ្ញុំនៅតែឃើញថា ស-២១ អត់ដឹងរឿងរ៉ាវអីច្រើនច្បាស់លាស់ជាមួយគេទេ ចាំតែគេបញ្ជូនមក គេឲ្យសួរយកអី សួរហ្នឹង ។ ដូច្នេះ គឺទិដ្ឋភាពរបស់ ស-២១ ដឹងត្រឹមប៉ុណ្ណឹង ឮត្រឹមប៉ុណ្ណឹង ។ នេះខ្ញុំសូមជម្រាប ដោយស្មោះត្រង់ ។

**ស៖** សូមអរគុណ ។ ដូច្នេះ ជាសង្ខេបទៅ គឺលោកមិនជំទាស់ថា ជម្លោះរវាងកម្ពុជានិងវៀត-ណាមបានបន្តបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ គឺគ្រាន់តែថា លោកមិនមានព័ត៌មានលម្អិតពិស្តារទាក់ទងទៅនឹងព្រឹត្តិការណ៍អស់ទាំងហ្នឹង ពីព្រោះ គឺថាលោកមិនយកចិត្តទុកដាក់ខ្លាំងទៅលើទំនាស់អស់ទាំងនុ៎ះ តើជាការពិតដែរឬទេ?

[១៤:៤១:៤០]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! សេចក្តីសន្និដ្ឋានរបស់លោកជំទាវត្រូវហើយ តែតាមពិតការងារ សូមថែមមួយម៉ាត់ទៀត គឺការងាររបស់ខ្ញុំចោទទៅលើតែរឿងសួរចម្លើយទេ វាអត់បានដឹងទេការងារទំនាស់គេហើយនិងវៀតណាម គេទុកជាសម្ងាត់បក្សពីរមានទំនាស់ដូចគ្នា ជាមួយគ្នា ក៏ប៉ុន្តែទុកទំនាស់នោះជាសម្ងាត់ នេះសូមជម្រាប គោរពជម្រាបលោកជំទាវប៉ុណ្ណោះ ។ សូមទានជ្រាប។

**ស៖** សូមអរគុណ ។ ខ្ញុំមានសំណួរជាច្រើនដើម្បីសួរទៅលោក ថាតើលោកអាចនៅចាំបានអ្វីអំពីជម្លោះប្រដាប់អាវុធ ក៏ប៉ុន្តែ ខ្ញុំយល់ថា មិនមែនជាការចាំបាច់ទេពីព្រោះលោកបានឯកភាពថា តាមពិត គឺមានជម្លោះប្រដាប់អាវុធមែន រវាងកម្ពុជាប្រជាធិបតេយ្យនិងប្រទេសវៀតណាម ពីថ្ងៃទី១៧ ខែមេសា រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តើនេះជាការសន្និដ្ឋានត្រឹមត្រូវរបស់ខ្ញុំទេ? ឬមួយក៏លោកចង់ធ្វើបញ្ចេញមតិបន្ថែមទៅលើការសន្និដ្ឋានរបស់ខ្ញុំនេះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការប៉ះទង្គិចគ្នាមានហូរហែ ។ ប៉ុន្តែ គ្រាន់តែគេមិនចង់ឲ្យខ្ញុំដឹងគេរក្សាបញ្ហានេះជាសម្ងាត់ ។ បក្សពីរដែលជាបក្សម៉ាក្ស-លេនីន ដូចគ្នា គេមិនទម្លាយការងារនេះជាចំហ ។ ដូច្នេះខ្ញុំនៅ តែទទួលស្គាល់ថា វាមាន១ ដូចលោកជំទាវសន្និដ្ឋានអ៊ីចឹង ។ នេះសូមចប់ ។

**ស៖** ដូច្នេះ គឺជាការចាំបាច់ណាស់ដើម្បីពិនិត្យមើល ថាតើលោកបានដឹងអ្វីខ្លះនៅពេលនុ៎ង? ហើយនិងអ្វីដែលលោកបានដឹងនៅពេលបច្ចុប្បន្ននេះ ហើយនិងទទួលស្គាល់នៅពេលបច្ចុប្បន្ននេះ? ដូច្នេះជាការចាប់ផ្តើម តើខ្ញុំអាចសួរលោកបានទេអំពីការដឹងរបស់លោកនូវជម្លោះប្រដាប់អាវុធនៅចន្លោះពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ នៅពេលដែលលោកត្រូវបានតែងតាំងជាអនុប្រធានមន្ទីរស-២១ នោះ ។ នៅក្នុងអំឡុងពេលនេះលោកបាននិយាយថា លោកជាប់រវល់ការងារខ្លាំងណាស់នៅឯម-១៣ នោះ តើជាការត្រឹមត្រូវដែរឬទេ? តើគួរឲ្យខ្ញុំនិយាយឡើងវិញទេ គឺនៅបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ហើយពីរបីអាទិត្យក្រោយមកទៀតហ្នឹង គឺលោករវល់ខ្លាំងណាស់ នៅឯមន្ទីរម-១៣ នោះតើជាការត្រឹមត្រូវដែរឬទេ?

[១៤:៤៥:00]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! នៅម-១៣ នេះ ខ្ញុំផុតការងារតាំងពីថ្ងៃ១ មករា មកម្ល៉េះ ១៩៧៥ មេខ្ញុំដើរចោលខ្ញុំ មកវ៉ៃសម្រុកភ្នំពេញផ្តាច់ព្រាត់ ។ ដល់ថ្ងៃ៣០ មេសា ទើបគាត់ទៅជួបខ្ញុំឲ្យខ្ញុំដោះលែងអ្នកទោសមួយចំនួន មួយចំនួនទៀត បញ្ជូនទៅ៩៩ ហើយឲ្យខ្ញុំនៅចាំគាត់ ។ ថ្ងៃ២០ មិថុនា ទើបគាត់បានហៅខ្ញុំមករៀន ។ ដូច្នេះ ខ្ញុំមិនរវល់ស្អីទេ ក៏ប៉ុន្តែ រឿងទំនាស់រវាងបក្សទាំងពីរនេះ វាមានជាទិដ្ឋភាពនយោបាយខ្លះ ប៉ះទង្គិចគ្នាដោយអាវុធបន្តិចបន្តួចខ្លះ ដូចជាឧទាហរណ៍នៅខាងស្ពានកោះធំ ដែលខ្ញុំបានរាយការណ៍ជូន ដោយខ្ញុំឃើញនឹងភ្នែក ។

សរុបមក ការផ្សព្វផ្សាយរបស់គេឲ្យខ្ញុំដឹង ដូចខ្ញុំបានជម្រាបលោកជំទាវអំមិញអ៊ីចឹង គេច្រើនទុកជាសំខាន់រវាងបក្សពីរដែលនៅជិតខាងគ្នា កុំឲ្យវាបែកធ្លើលគេដោះស្រាយ ។ ដូច្នេះ ខ្ញុំពិតជាបានដឹង

តិចតួច មិនមានប្រាថ្នាលាក់ទេ នេះម្យ៉ាង ។ ម្យ៉ាងទៀត ខ្ញុំផ្ទាល់អត់ ខ្ញុំអត់ចង់ប្រាថ្នាទេ ពីព្រោះវាហួសនឹងសមត្ថភាពខ្ញុំនឹងគិត ជំនឿជឿជាក់ថា គេពិតជាការពារបូរណភាពទឹកដីបាន ការពារអធិបតេយ្យភាពបាន ។ ដូច្នេះ ទុកទៅ ឲ្យគេទៅ ឯចំណែកខ្ញុំ ពីថ្ងៃ-- ពីខែ៩មក ពីខែ៩ ឆ្នាំ១៩៧៥មក ខ្ញុំគិតតែខំការងារជាមួយ ណាត ។ ខែ៩អី ខែ១០ ជាមួយ ណាត នៅ ស-២១ ។ រឿងអីរឿងទៅ ឯចំណែកខ្ញុំគិតតែខំធ្វើការងារដើម្បីឲ្យវាទាន់ការងារ ដែលគេតម្រូវមក ។ ឯចំណែក ជនជាតិវៀតណាម ជាស៊ីវិលអាហ្នឹងទាហានចាស់របស់រដ្ឋការព្រៃនគរចូលមក ខ្ញុំអាងលើបញ្ជាដែលនៅសល់នៅស-២១ ។ នេះសូមជម្រាបដោយត្រង់អ៊ីចឹង ។ នេះខ្ញុំសូមរបៀបហើយថា ការយល់ដឹងរបស់ខ្ញុំអំពីទំនាស់ខ្មែរ ហើយនិងវៀតណាម ខាងកម្លាំងប្រដាប់អាវុធនេះ ខ្ញុំយល់ដឹងមិនជ្រៅទេ ។ ក៏ប៉ុន្តែ អាងលើបញ្ជី ហើយអាងលើការចងចាំបន្តិចបន្តួចហ្នឹង គឺសូមរាយការណ៍ជម្រាបជូនប៉ុណ្ណឹង ។

**សៈ** សូមអរគុណ ។ នៅក្នុងសម្ភាសន៍របស់លោក នៅចំពោះមុខតុលាការយោធា នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០២ ដែលមានលេខERN ជាភាសាអង់គ្លេស00329129 រហូតដល់លេខ 00329132 ហើយភាសាខ្មែរមានលេខERN0095692 ដល់លេខ 0095695 ហើយភាសាបារាំងមានលេខ 00327359 ដល់លេខ 00327362 ។ នៅក្នុងបទសម្ភាសន៍នោះ លោកបាននិយាយថា ពីរបីថ្ងៃបន្ទាប់ពីថ្ងៃ១៧ ខែមេសា លោកបានជួប សុន សេន ហើយគាត់បានចាត់តាំងការងារមួយចំនួន ទាក់ទងនឹងអ្នកទោសនៅម-១៣ មកឲ្យលោក ។ នៅពេលដែលលោកជួប សុន សេន តើគាត់មានបាននិយាយអ្វីអំពីជម្លោះរវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំជួបលោកគ្រូ សុន សេន បើតាមខ្ញុំចាំជួបឯដំណាក់ស្នាច់ឯណោះ នៅថ្ងៃ៣០ មេសា ១៩៧៥ ពេលនុ៎ងហើយ ដែលខ្ញុំតែងតែនិយាយថា គាត់ឲ្យបង្ហើយការងារដែលនៅសល់ ឲ្យដោះលែងអ្នកទោសនៅម-១៣ “ខ” ទាំងអស់ ។ មន្ទីរ ម-១៣ “ក” មួយចំនួនបញ្ជូនទៅ ។ ៩៩ ដែលកាលនោះគ្នាខ្ញុំហៅថា មន្ទីរនគរបាលតំបន់៣២ ហើយមួយចំនួនទៀតដោះលែង ។ នេះខ្ញុំតែងតែនិយាយ ហើយខ្ញុំតែងតែនិយាយចុងក្រោយនេះទៀតថា ពេលហ្នឹងហើយ ដែលមេខ្ញុំឲ្យម៉ូតូខ្ញុំមួយ ប៉ុន្តែមិនឲ្យយក *សេអិល* ទេ ឲ្យយក *ពេសេ* ។ នេះជារឿងពិត ក៏ប៉ុន្តែពេលនុ៎ង អត់ទាន់មាននិយាយជម្លោះប្រដាប់អីគេ ទាស់គ្នាយ៉ាងម៉េចទេ ។ រឿងទាស់គ្នាជានយោបាយ មានរៀនសូត្រយូរមកហើយដែរ ។

[១៤:៥១:០២]

**ស៖** តើគាត់មិនមានផ្តល់ភារកិច្ចអ្វីផ្សេងទៀតទេ បន្ទាប់ពីគាត់បានផ្តល់ម៉ូតូមួយមកឲ្យលោករហូតដល់ខែមិថុនា ឆ្នាំ១៩៧៥នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! នៅពេលនុ៎ង គាត់ឲ្យខ្ញុំនៅចាំៗទទួលដំណឹង ។ នេះសូមជម្រាបខ្លីប៉ុណ្ណឹង ។

**ស៖** អរគុណ ។ តើដោយពិតប្រាកដទៅ តើលោកធ្វើអ្វីដែរនៅក្នុងពេលនោះ នៅពេលដែលលោកបញ្ចប់ការងារនៅម-១៣ រួចហើយនោះ? ហើយលោកបានទទួលការចាត់តាំងថ្មី ហើយនៅពេលដែលលោកបានជួបជាថ្មីម្តងទៀត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៥?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពីថ្ងៃ៣០ មេសា ១៩៧៥ រហូតដល់ថ្ងៃ២០ មិថុនា ១៩៧៥ ខ្ញុំបានជម្រាបលោកចៅក្រមស៊ើបអង្កេតហើយ ខ្ញុំដូចជាមិនចង់ប្រើពាក្យហ្នឹងទេ ខ្ញុំបានជម្រាបលោកចៅក្រមស៊ើបអង្កេតថា ខ្ញុំជិះម៉ូតូដើរលេង តាមពិតខ្ញុំដូចជាដើរលេងអ៊ីចឹងមែន ។ ជិះម៉ូតូទៅប្អូនលោកគ្រូ សុន សេន នេះ ដើម្បីរង់ចាំដំណឹងមកពីគាត់ ហៅខ្ញុំមកភ្នំពេញអង្កាល់? ដល់វានៅយូរៗពេកយី! មិនកើតទេរកសុំការ ដល់រកសុំការ នែ៎គូដណ្តឹងខ្ញុំហ្នឹង គាត់បដិសេធ គាត់សុំពន្យារ ព្រោះគាត់ខ្លាចមេម៉ាយខ្លួនគាត់ទៅអត់មានអ្នកណា ដែលនៅភូមិភាគពិសេសហើយ នៅកប់ទីជនបទ ដូចខ្ញុំទេ ។ នេះគឺរឿងពេលនុ៎ងការងារឯកជនសុទ្ធសាធ ដើរលេង ក៏ថាបាន ថានៅរង់ចាំដំណឹងក៏ថាបាន ។ ហើយនៅពេលនុ៎ងហើយ ដែលចុងខែឧសភា ខ្ញុំជួប ចេង អន ។ ខ្ញុំសុំ ចេង អន ឲ្យជួយអង្វរករខាងលើ ឲ្យខ្ញុំបានទៅឧស្សាហកម្ម ។ ចេង អន ធានាជួយ ប៉ុន្តែ ខាងលើមិនឲ្យ ឲ្យតែខ្ញុំនៅចាំតទៅទៀត ។ នេះទិដ្ឋភាពការងារហ្នឹង ខ្ញុំនៅជាមនុស្សបាត់អាជីព ។ សូមជម្រាបមួយម៉ាត់ទៀតទៅចុះ គឺថាបាត់អាជីព ក៏ថាបានដែរ អត់មានធ្វើបដិវត្តន៍ទេ ។

[១៤:៥៣:៤៤]

**ស៖** សូមអរគុណ។ ខ្ញុំនឹកឃើញអំពីសក្ខីកម្មដែលលោកបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេតពីមុន ប៉ុន្តែខ្ញុំលើកឡើងពីគំនិតពេលមួយ តើលោកបានដឹងដំណឹងអ្វីតាមវិទ្យុ ឬតាមមេដឹកនាំថ្នាក់ខ្ពស់អំពីជម្លោះប្រដាប់អាវុធជាមួយវៀតណាមទេក្នុងអំឡុងពេលនុ៎ង?

**ឆ៖** ក្នុងរយៈកាលនោះ ខ្ញុំគ្មានបានទាក់ទងមេទេ ហើយធម្មតាទេ តែកាលណាមិនបានទាក់ទងមេហើយ មិនបានទទួលការណែនាំអីជាននយោបាយទេ ។ នេះសូមជម្រាបប៉ុណ្ណឹង ។

**ស៖** នៅក្នុងរយៈពេលចាប់ផ្តើមដំបូងនៃកម្ពុជាប្រជាធិបតេយ្យ តើទំនាក់ទំនងនៃការទាក់ទងនឹងយ៉ាងដូចម្តេច? តើមានការផ្សាយវិទ្យុ តើគេបានចាប់ផ្តើបោះពុម្ពទស្សនាវដ្តីទង់បដវិត្តន៍ភ្លាមដែរឬទេ?

**ឆ៖** រឿងទស្សនាវដ្តីទង់បដិវត្តន៍នេះ សូមជម្រាបលោកជំទាវថា ខ្ញុំស្គាល់យូរហើយ តាំងពីទស្សនាវដ្តីនេះ នៅជាទស្សនាវដ្តីទង់ក្រហម ។ ក្រោយ១៩៧១ គេប្រែមកជាទស្សនាវដ្តីទង់បដិវត្តន៍ ហើយនៅក្នុងពេលឈ្នះ៧៥នេះ មិនដឹងជាគេខានប៉ុន្មានលេខទេ អាចមានខានក៏មិនដឹង ។ ហើយដល់ពេលខ្ញុំបានមកដល់ភ្នំពេញ មានតួនាទីមានអីហើយ បានចាប់ផ្តើមបានទស្សនាវដ្តីមកដៃខ្ញុំឡើងវិញ ។ នេះសូមជម្រាបបញ្ជាក់ឡើងវិញ ។

**ស៖** ចាតើការផ្សាយតាមវិទ្យុ តើលោកបានឮទេតាមការផ្សាយវិទ្យុអំពីរឿងការជម្លោះ ជាមួយវៀតណាមនោះ?

**ឆ៖** បើតាមខ្ញុំចាំបក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាបក្សពលករវៀតណាម ដល់ក្រោយមកប្រែឈ្មោះជាបក្សកុម្មុយនីស្តវៀតណាមហ្នឹង ។ លាក់ជម្លោះហ្នឹងជាសំខាន់ ហើយពុះពារដោះស្រាយ ។ ដូច្នេះ ខ្ញុំមិនជឿថា គេផ្សាយវិទ្យុទេ ហើយខ្ញុំក៏មិនបានជានឹកឃើញថា មានការផ្សាយវិទ្យុផងដែរ ។ នេះសូមជម្រាបលោកជំទាវប៉ុណ្ណោះ ។

**ស៖** អរគុណ ។ ឥឡូវនេះ យើងចូលទៅដល់ដំណាក់កាលមួយ ពេលដែលលោកបានទទួលតំណែងជាអនុប្រធាននៃស-២១ តើលោកបានចាប់ផ្តើមរាយការណ៍ជាទៀងទាត់ទៅឲ្យ សុន សេន ក្នុងឋានៈជាអនុប្រធានដែរឬទេ?

[១៤:៥៧:០៧]

**ឆ៖** ជម្រាប្រសាសន៍លោកជំទាវ! នៅពេលដែលខ្ញុំបានទទួលតំណែងជាអនុប្រធាន វាមានពីរដំណាក់។ ដំណាក់ទី១ គឺពីថ្ងៃ១៥ សីហា ១៩៧៥ រហូតមកដល់ក្នុងខែ១០ ។ ក្នុងដំណាក់កាលនេះ ខ្ញុំមានភារកិច្ចដើរប្រមូលឯកសារពីផ្ទះមេធំៗ ហើយនិងគ្រឹះស្ថានសាធារណៈរដ្ឋរបស់ លន់ នល់ យកមកទុក ក៏ប៉ុន្តែពេលខ្លះ ក៏ជួយសួរជួយអីគេផងដែរ ជួយចារលើឯកសារសួរចម្លើយខ្លះ ។ ក៏ប៉ុន្តែ ដែលចូលមកកាន់កាប់កិច្ចការជាប់លាប់ ពេញដៃជាអនុប្រធានប្រហែលជាក្នុងខែ១០ រហូតមកដល់ខែមីនា ១៩៧៦ដែល ណាត ចេញទៅ ខ្ញុំឡើងជាប្រធាន ។ នេះវាមានពីរដំណាក់អ៊ីចឹង អង្កាល់ដែលខ្ញុំទទួលភារកិច្ចជាអនុប្រធានហ្នឹង វាមានពីរដំណាក់អ៊ីចឹង ។

**សៈ** អ៊ីចឹង តើលោកនិយាយថា លោករាយការណ៍ជាទៀងទាត់ទៅឲ្យ សុន សេន មិនបានចាប់ផ្ដើមទេ រហូតដល់ខែតុលា ឆ្នាំ១៩៧៥?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ពីខែតុលា ១៩៧៥ រហូតមកនេះ លោកគ្រូ សុន សេន ឲ្យតែហៅទៅធ្វើការ គឺគាត់ហៅទៅទាំងពីរនាក់ ទាំងខ្ញុំ ទាំងណាត ទាំងប្រធាន និងអនុប្រធានទៅជាមួយគ្នា ។ ដូច្នេះ ការរាយការណ៍ គឺវាមានកំណើតពីពេលហ្នឹងមក ។ តែពីពេលមុននោះ ខ្ញុំមិនចាំ ប៉ុន្តែ ដូចអាងលើឯកសារដែលនៅសល់ ខ្ញុំជឿថា យើងអាចយល់ថា តើខ្ញុំបានរាយការណ៍ឬអត់? អាហ្នឹងឯកសារនៅសល់ វាអាចបញ្ជាក់ជូនហើយ ។ នេះសូមជម្រាបដោយស្មោះត្រង់ប៉ុណ្ណេះ ។

**សៈ** តើការរាយការណ៍ប្រចាំថ្ងៃរបស់លោកធ្វើតាមទូរស័ព្ទ គឺថា ចាប់ផ្ដើមពេលដែលលោកធ្វើជាប្រធានហើយ ឬក៏បានធ្វើរាយការណ៍ប្រចាំថ្ងៃដែរ ពេលដែលលោកនៅជាអនុប្រធាននោះ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ ។ ទូរស័ព្ទដែលខ្ញុំមានប្រើ ក្រោយពេលដែល ណាត ចេញទៅបន្តិចទៅទៀត ប្រហែលជាមួយខែ ពីរខែអីទៀត បានខ្ញុំបានទូរស័ព្ទមកប្រើ ។

[១៥:00:00]

**សៈ** អរគុណ ។ នៅក្នុងការសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៥ ខែឧសភា D72 ក្នុងអង់គ្លេស ERN 00204282 រហូតទៅដល់ 00204300 នៅក្នុងអត្ថបទខ្មែរ 00187649 រហូតទៅដល់00187670, នៅក្នុងភាសាបារាំង 00186168 រហូតទៅដល់ 00186191 ។ លោកបាននិយាយអំពី សុន សេន បញ្ជាក់ថាមានជម្លោះនៅព្រំដែននៅមណ្ឌលគីរី ប៉ុន្តែ លោកមិនចាំច្បាស់ថាតើបាននិយាយពីអ្វីលម្អិតទេនៅពេលដែលលោកទទួលការតែងតាំងនៅក្នុងខែសីហា ឆ្នាំ១៩៧៥ ឬក៏លោកបានក្លាយទៅជាប្រធាននៅខែមីនា ឆ្នាំ១៩៧៦ តើលោកនៅនឹកឃើញទេ អំពីការសន្ទនាជាមួយលោក សុន សេន នោះទេ នៅក្នុងពេលនេះ លោកនៅចាំ នឹកឃើញទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំនឹកឃើញព្រាលៗ កាលដែលលោកគ្រូ សុន សេន មេខ្ញុំប្រាប់រឿងនេះ ឧទ្ទេសនាមនេះឲ្យយល់ ដូចជាថ្ងៃនោះមានប្រជុំកងពលដើម្បីផ្សព្វផ្សាយបញ្ហានេះ មិនដឹងជាបញ្ហាអីទៀតទេ ។ ក៏ប៉ុន្តែ មានបញ្ហានេះមួយនៅពេលដែលគាត់ឧទ្ទេសនាម គាត់ងាកទៅក្រោយខ្នង គាត់ចង្អុលលើផែនទីខ្នាតមួយភាគពីររយហាសិបពាន់ ឲ្យយើងខ្ញុំឃើញទាំងអស់គ្នាហ្នឹង ។ គាត់ថាទំនាស់តែលើដែនដីម្ដុំហ្នឹងទេ ។ បើតាមខ្ញុំចាំដូចជាទំហំសាមសិបប្រាំបីគីឡូម៉ែត្រការ៉េ គាត់មានប្រសាសន៍តែប៉ុណ្ណឹង ។ រួចរឿងក្នុងជម្លោះហ្នឹងយ៉ាងម៉េច? អីយ៉ាងម៉េចខ្ញុំភ្លេចអស់រលីងហើយ ប៉ុន្តែ

គាត់គ្រាន់តែគាត់ងាក់ទៅគាត់លូកដៃចង្អុលក្នុងផែនទីអ៊ីចឹង ខ្ញុំនៅចាំ ។ ដូច្នេះ ខ្ញុំនឹកឃើញតែប៉ុណ្ណឹងឯង មិនមែនជាបទឧទ្ទេសនាមរវាងខ្ញុំ ហើយនិងគាត់តែពីរនាក់ ឬរវាងបីនាក់ ខ្ញុំ ហើយនិងគាត់ទេ ។ ក៏ប៉ុន្តែ បើតាមខ្ញុំគិតទៀតរំឭកឡើងវិញពេលនុ៎ង ណាត ចេញហើយ ខ្ញុំឡើងជាប្រធានហើយ ។ ហ្នឹងជម្រាបប្រសាសន៍លោកជំទាវប៉ុណ្ណេះ ។

**ស៖** អរគុណ ។ តើលោកច្បាស់ទេនៅពេលនោះ ថានោះគឺជាជម្លោះជាមួយវៀតណាម ហើយជម្លោះហ្នឹង គឺជាជម្លោះប្រដាប់អាវុធ? តើលោកច្បាស់អ៊ីចឹងទេ?

**ឆ៖** ពេលនុ៎ង ដូចជាមិនទាន់ចេញមុខនិយាយពីរឿងប្រដាប់អាវុធទេ ។ តាមខ្ញុំចាំរឿងទាហានវៀតណាមម្នាក់ចូលមកដល់ស-២១ ដូចជាក្រោយគាត់ចេញចោលខ្ញុំ គឺក្រោយថ្ងៃ១៥ សីហា ១៩៧៧ ឃើញមានទាហានវៀតណាមម្នាក់ចាប់យកមកស-២១ ហ្នឹង ឬក៏មុននេះបន្តិចមិនដឹង អាហ្នឹងមកហើយ មានទាហានវៀតណាមមកហើយ ហ្នឹងសូមបញ្ជាក់ប៉ុណ្ណេះ ។

[១៥:០៤:១៥]

**ស៖** ក្រោយមក ក្រោយពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ លោកបានរាយការណ៍ទៅឲ្យ នួន ជា តើការរាយការណ៍នោះញឹកញាប់ប៉ុនណាដែរ ដែលរាយការណ៍ផ្ទាល់នោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា សូមទោសដែលហៅខ្ញុំទៅធ្វើការមិនខុសគ្នាប៉ុន្មានទេ រវាងលោកគ្រូ សុន សេន ហើយនិងពូនួន គឺ នួន ជា នេះ បីថ្ងៃយ៉ាងឆាប់ ប្រាំថ្ងៃយ៉ាងយូរ គាត់ហៅខ្ញុំទៅ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** ប៉ុន្តែ ខ្ញុំគិតថា ភាពក្នុងគ្នាក្នុងការទំនាក់ទំនងរវាងលោក ហើយនិង នួន ជា ហើយនិងលោកជាមួយ សុន សេន នោះ គឺថាលោក នួន ជា មិនប្រើទូរស័ព្ទច្រើនទេ ទាក់ទងជាមួយលោកនោះ តើត្រឹមត្រូវទេអ៊ីចឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពូនួន អត់កាន់ទូរស័ព្ទសោះមិនដឹងអាម៉េចគាត់ បើលោកគ្រូសុន សេន គាត់ប្រើទូរស័ព្ទជាមូលដ្ឋានជាមួយនិងខ្ញុំ ។

**ស៖** អរគុណ ។ នៅក្នុងបទសម្ភាសន៍ដដែលនោះ ជាមួយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៥ ខែឧសភា ដែលខ្ញុំទើបតែបានយោងនោះ លោកក៏បានបញ្ជាក់ដែរថា នួន ជា បាននិយាយអំពីខ្សែបន្ទាត់ *ប្រេវីយេ* នៅចុងឆ្នាំ១៩៧៧ តើលោកនៅនឹកឃើញសេចក្តីលម្អិតនៃការពិភាក្សាជាមួយគាត់នោះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ថ្ងៃនោះគាត់ហៅខ្ញុំទៅធ្វើការ ដូចដែលខ្ញុំហើយនិងគាត់តែពីរទេ ។ ដូច ឡេឃន់ ទើបនឹងចេញពីស្រុកខ្មែរ ឬម៉េចទេខ្ញុំមិនចាំទេ សភាពការណ៍នុំង គាត់និយាយថា "មកជជែកគ្នាឡើង តែអារឿង *លើងប្រេវីយ* អាណាគេទៅឆោតតាមវា" គាត់និយាយប៉ុណ្ណឹង បែបរៀងត្រគួសប៉ុណ្ណឹងឯង ។ នេះបើតាមខ្ញុំចាំសម្ដីគាត់ ទឹកមុខគាត់នៅពេលនុំង ហ្នឹងសូមជម្រាប់លោកជំទាវប៉ុណ្ណឹង ។

**ស៖** លោកប្រធានគឺថា អាចនឹងដល់ពេលដើម្បីសម្រាកបន្ដិចហើយ ឬយ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទដល់ពេលម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទី ហើយរហូតដល់ម៉ោងបីម្ភៃនាទីអញ្ជើញចូលវិញ ។

*[សវនាការសម្រាកពីម៉ោង ១៥:០៧នាទី ដល់ម៉ោង ១៥:២៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការដេញដោល លើអង្គហេតុជម្លោះប្រដាប់អាវុធតទៅទៀត ។ ហើយមុននឹងជូនវេទិកាទៅលោកស្រីចៅក្រម ខាតវ៉ាយច៍ អង្គជំនុំជម្រះសូមជម្រាប ជូនដំណឹងដល់ភាគី និងសាធារណជនបានជ្រាបថា ផែនការនៃដំណើរការស្ដាប់សក្ខីកម្ម សាក្សី KW08 ដែលគ្រោងធ្វើនៅរសៀលនេះត្រូវអាក់ខានលើកទៅពេលក្រោយ ដោយឥតកំណត់ ដោយមូលហេតុនៅក្នុងកំឡុងពេលនៃដំណើរការពិភាក្សាដេញដោលអង្គហេតុ ការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅមន្ទីរស-២១ ដោយសារភាគីដែលចូលរួមនៅក្នុងការដេញដោលនេះបានប្រើពេលវេលាអស់យ៉ាងច្រើន ដែលជាហេតុនាំឲ្យការគណនាពេលវេលារបស់អង្គជំនុំជម្រះមិនត្រូវ ។

ដូច្នេះ គឺការដែលធ្វើសវនាការលើស្ដាប់សក្ខីកម្មសាក្សី KW08 មិនអាចធ្វើបាន ហើយអង្គហេតុដែលសមស្របនឹងអញ្ជើញគាត់មកធ្វើសក្ខីកម្មទាំងនោះ គឺអង្គជំនុំជម្រះពិចារណាឃើញថា អង្គហេតុប្រតិបត្តិការស-២១ និងជើងឯក ជាអង្គហេតុសមស្រប ។ ដូច្នេះ កំណត់កាលបរិច្ឆេទនៃការស្ដាប់សាក្សីរូបនេះ អង្គជំនុំជម្រះនឹងជម្រាបជូនដល់ភាគីនៅពេលក្រោយតាមកាលវិភាគសវនាការបន្តបន្ទាប់ ហើយ

ក៏សូមជម្រាបជូនដល់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញផងដែរថា សូមចាត់ចែងដើម្បីជូនសាក្សី KW08 ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ ។

សូមអញ្ជើញលោកស្រីចៅក្រម ដើម្បីបន្តការសួរដេញដោលជនជាប់ចោទលើអង្គហេតុជម្លោះប្រដាប់អាវុធ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក កាំង ហ្កេកអ៊ាវ ខ្ញុំបានសួរលោកអំពីអ្វីដែលលោកបានដឹងទាក់ទងនឹងជម្លោះប្រដាប់អាវុធនៅក្នុងកំឡុងពេល ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ បន្ទាប់ពីបានឮពីសក្ខីកម្មរបស់លោក ណាយ៉ាន់ ចាន់ដា ។ តើលោកមានបានរំឭកមើលឡើងវិញនូវព័ត៌មានលម្អិត អំពីជម្លោះប្រដាប់អាវុធ អំពីជម្លោះ និងថាតើនរណាគេបានផ្តល់ព័ត៌មានអំពីជម្លោះ? ឬក៏តើលោកបានដឹងពីជម្លោះអស់ទាំងហ្នឹង ពីប្រភពណាមក?

[១៥:២៩:០៧]

**ឆ៖** សូមជម្រាបប្រសាសន៍លោកជំទាវ! សក្ខីកម្មរបស់អ្នកជំនាញ ណាយ៉ាន់ ចាន់ដា ខ្ញុំវាចាត់ទុកដូចជាឆ្ងាយពីការយល់ដឹងរបស់ខ្ញុំ មិនមែននិយាយថា គាត់រាយការណ៍មិនពិតទេ តែវាសុទ្ធតែព័ត៌មានថ្មីសម្រាប់ខ្ញុំទាំងអស់ ខ្ញុំអត់ដឹងទេ ។ ខ្ញុំចាំថា មេខ្ញុំដែលចេញពីស-២១ ទៅដំបូងទៅបោះទីតាំងនៅទីណាទេ ដល់ក្រោយមកមកបោះទីតាំងនៅអ្នកលឿង ។ ការទាក់ទងរវាងខ្ញុំនិងគាត់ តាមតែអូ នៅមានមួយ ខែអីម្តង ។ ដូច្នេះ កាលដែលបែកពីមេនេះ ធ្វើឲ្យខ្ញុំគិតថា វាមានរឿងដែលត្រូវត្រៀមរៀបចំ ឬក៏យ៉ាងម៉េចមិនដឹងទេ នៅខាងនុ៎ង ។ ដូច្នេះ ព័ត៌មានទីមួយ ដែលមេផ្សាយឲ្យខ្ញុំដឹងគ្មានទេ មានតែពីរចំណុចសំខាន់ ទីមួយ គឺទំនាស់គ្នានៅត្រង់តំបន់ផ្លែសន្ទួច ខាងត្បូងឆៀងខាងកើតនៃខេត្តមណ្ឌលគិរី ។ ទីពីរ គឺខ្សែ បែងចែកបណ្តោះអាសន្ន ដែលយើងហៅថា លីងប្រេវីយេ តែប៉ុននុ៎ង ។ លីងប្រេវីយេនោះពូ នួន ប្រាប់ ឯចំណែករឿងទំនាស់លើដីគោកនោះ លោកគ្រូ សុន សេន ប្រាប់ ។ ពូនួន ប្រាប់នឹងមុខខ្ញុំពេល ដែលហៅទៅធ្វើការ ឯចំណែកលោកគ្រូ សុន សេន បើតាមខ្ញុំចាំ គឺនៅក្នុងការប្រជុំមួយមានកងពល មានអីគ្រប់គ្រាន់ នៅនុ៎ងប្រហែលជាជាង១០នាក់ប៉ុននុ៎ង ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** នៅស-២១ តើមានវិទ្យុ ដែលលោក ឬក៏បុគ្គលិករបស់លោកបានស្តាប់ជាបន្តបន្ទាប់នោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! វិទ្យុមាន ។ ខ្ញុំមិនដឹងថានរណាមានខ្លះទេ ប៉ុន្តែ ខ្ញុំមានវិទ្យុមួយធំ ប្រមាណ១៤បង់នុំង គ្រួញឌីក ចាក់ ប៉ុន្តែខ្ញុំជួនពេលមិនសូវមានពេលស្តាប់ផង អាវិទ្យុខ្លួនឯងហ្នឹងមិនមានពេលស្តាប់ទេ ។ នេះជម្រាបដោយត្រង់ ។

**សៈ** អ៊ីចឹងលោកនិយាយថា លោកមិនបានឮព័ត៌មានអ្វី ការវាយការណ៍អ្វីអំពីជម្លោះជាមួយវៀតណាម នៅលើវិទ្យុរបស់លោកនោះដែរឬទេ?

**ឆ៖** រឿងចាស់វាច្រើនឆ្នាំហើយ ក៏ប៉ុន្តែបើតាមខ្ញុំចាំ ស្ទើរតែប៉ានអាចជម្រាបអះអាងថា ដូចជាមិនឮនិយាយអំពីជម្លោះប្រដាប់អាវុធ ផ្សាយតាមវិទ្យុមុនថ្ងៃ៦ មករា ដែលខ្ញុំចាំ ៦ មករា ១៩៧៨ ។

**សៈ** ហើយមុនថ្ងៃខែនេះ តើលោកមានបានដឹងអំពីការព្យាយាមកាលពីខែឧសភា ឆ្នាំ១៩៧៥ ដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ព្យាយាមវាយរំដោះយកកោះដែលវៀតណាមបានឡើងមកកាន់កាប់នោះ?

**ឆ៖** រឿងនេះវាមានរឿងល្អេចល្អៀង ដូចច្រឡំគ្នាជាមួយនឹងអារឿងនាវាម៉ាយ៉ាហ្គេ មិនដឹងជាឯណាជាឯណីទេ រហូតមកដល់ឥឡូវនេះខ្ញុំច្រឡំអាព្រឹត្តិការណ៍ពីរហ្នឹង មិនដឹងជាឯណាមួយទេ ។

[១៥:៣៣:៣៨]

**សៈ** អ៊ីចឹងលោកបានឮពាក្យចចាមអារ៉ាម ឬអំពីជម្លោះនៅលើកោះ ឬក៏ទៅលើនាវាម៉ាយ៉ាហ្គេ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទពិតជាត្រឹមត្រូវ ពាក្យចចាមអារ៉ាមហ្នឹងឮ ប៉ុន្តែ នូវច្របូកច្របល់ណាស់ មិនដឹងជារឿង កោះពូលូវ៉ៃ គឺម៉ាយ៉ាហ្គេ ។ ម៉ាយ៉ាហ្គេ ផ្សេង ពូលូវ៉ៃផ្សេង ខ្ញុំមិនដឹងទេ ។

**សៈ** ដូច្នេះ លោកមិនប្រាកដអំពីកោះពូលូវ៉ៃដែលត្រូវបានវៀតណាមវាយប្រហារកាលពីខែមិថុនា ឆ្នាំ១៩៧៥ ទេនោះ? ហើយដូច្នេះមានន័យថាលោកមិនបានពិតប្រាកដ ថាលោកបានឮរឿងនុំងទេនៅពេលនោះ ឬក៏នៅពេលបន្តិចក្រោយពីពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! មិថុនា ១៩៧៥ យើងខ្ញុំចូលមកភ្នំពេញថ្ងៃ២០ ដូច្នេះ ក្នុងខែ មិថុនា ហ្នឹងកំពុងតែរៀនវគ្គ កំពុងតែរៀនសូត្រវគ្គ ។ ដូច្នេះ ដំណឹងអត់មានទេ ឆ្ងាយពីផ្ទះ ឆ្ងាយពីកន្លែងនៅ នេះសូមជម្រាបប៉ុននុំង ។

**សៈ** តើនៅពេលហ្នឹងលោកមានបានស្តាប់វិទ្យុទេ? នៅពេលដែលលោកចូលរួមវគ្គរៀនសូត្រនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពេលដែលចូលវគ្គរៀនសូត្រនោះ យប់ពិភាក្សាគ្នាតាមក្រុមនូវមេរៀនដែលបានរៀនពីថ្ងៃ អត់មានបានស្តាប់វិទ្យុទេ ហើយកាលនោះវិទ្យុនៅឯអមលាំង នុំងអត់បានយកមកផង ។

**សៈ** តើលោកមានបានឮអំពីជម្លោះនៅក្នុងកំឡុងពេលដែលលោករៀនវគ្គសិក្សានោះដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែដូចអត់មានឮអ្នកណានិយាយទេ ។

**សៈ** នៅក្នុងសម្ភាសន៍របស់លោកកាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ ជាមួយចៅក្រមស៊ើបអង្កេតដែលមានលេខ ERN ជាភាសាអង់គ្លេស 00204284 ហើយជាភាសាខ្មែរមានលេខ 00187649 រហូតដល់លេខ 00187670 ហើយភាសាបារាំងមានលេខ 00186168 ដល់លេខ 00186191 ។ លោកមានចាំថា គេបានបញ្ជាឱ្យបង្ហាញនូវភាពផ្សេងគ្នាទាក់ទងទៅនឹងនយោបាយរវាងវៀតណាមហើយនិងកម្ពុជានៅក្នុងវគ្គសិក្សានយោបាយ ។ តើការណែនាំអំពីភាពខុសគ្នាលើនយោបាយនោះ បាននិយាយយោងទៅលើជម្លោះព្រំដែនជាមួយវៀតណាម ឬថៃដែរឬទេ?

[១៥:៣៧:៣៨]

**ឆ៖** ការរៀនសូត្រវគ្គនយោបាយដែលដឹងអំពីទំនាស់រវាងខ្មែរ និងវៀតណាម វាមានរយៈពេលយូរដែរពីឆ្នាំ១៩៧៣ ពីរឿងវៀតណាមចរចា ចង់ទាញខ្មែរឱ្យទៅចរចាដែរ ។ បើកាលណាវៀតណាមទាញខ្មែរឱ្យទៅចរចារបាន វៀតណាមនឹងចំណេញលុយពីអាមេរិកពីររយលានដុល្លារ លើនយោបាយបក្សកុម្មុយនីស្តកម្ពុជា វាទៅជាបក្សមួយដែលរណបបក្សពលករវៀតណាម នេះខ្ញុំដឹង គឺរៀនសូត្រវគ្គនយោបាយឆ្នាំនុំង ហើយខ្ញុំដឹងក្រៅផ្លូវការទេ ក្រៅការរៀនសូត្រទេ ។ ការចាត់តាំងសហករណ៍ គឺដើម្បីទប់ទល់កុំឱ្យវៀតណាមចូលមកទិញស្រូវពីស្រុកខ្មែរយកទៅស៊ីបានតាមចិត្ត នេះដឹង។ ហើយឆ្នាំ១៩៧៣ ឡេ យន់ គាត់ស្នើសុំយកអណិកជនវៀតណាមដែលនៅសល់ទាំងប៉ុន្មាននៅដីរំដោះ យកទៅស្រុកគាត់ដើម្បីត្រៀមរៀបចំបោះឆ្នោត ។ នេះខ្ញុំដឹង ។

នៅពេលក្រោយ១៧មេសា បន្តិចខ្ញុំទៅរើសៀវភៅបាន នេះសៀវភៅអំពីអាណានិគមនិយមទៅកុម្មុយនិស្តនិយមនេះ នៅក្នុងទីស្នាក់ការគណៈបក្សសាធារណរដ្ឋខ្មែររបស់ លន់ នល់ នេះអ្នកនិពន្ធបារាំងម្នាក់សរសេរ ខ្ញុំមើលទៅឃើញហេតុផលគួរឱ្យជឿ ថាបក្សកុម្មុយនិស្តកម្ពុជាមិនយល់ស្របនឹងផែនការសហព័ន្ធឥណ្ឌូចិនរបស់ ហូ ជីមិញ ទេ? ជឿ ។ ជឿទាំងស្រុង ហើយមកដល់ពេលដែលខ្ញុំស្នាក់នៅផ្លូវរទេះភ្លើង ខ្ញុំឃើញ ឡេ យន់ មក ។ ប៉ុល ពត គាត់ថា ទៅទទួលអីស្រួលបួលទៅ ។

[១៥:៤០:00]

ហ្នឹងឃើញ ដឹង ក៏ប៉ុន្តែគ្មានអ្នកណានិយាយថា ចូលមកពិភាក្សាគ្នារឿងអី ខ្ញុំអត់ដឹងទេ ដឹងថាគេមក នេះខ្ញុំដឹង ។ ហើយទំនាស់ប្រដាប់អាវុធ មិនដឹងទេ នេះសូមជម្រាបដោយត្រង់ ខ្ញុំគិតគួរដឹងច្បាស់រឿងនយោបាយ គេបង្ហាញនយោបាយ ដែលត្រូវតែប្រុងប្រយ័ត្ន គឺសហព័ន្ធឥណ្ឌូចិននេះឯង ។ នេះជារឿងនយោបាយ ។ ក៏ប៉ុន្តែ រឿងពិតមួយដែលខ្ញុំចង់ចាំជានិច្ច គឺថ្ងៃ១៥ សីហា ១៩៧៧ មេខ្ញុំលោកគ្រូសុន សេន ទៅចោលខ្ញុំ មិនចុះមកជួបខ្ញុំទេ មានតែពូនួន គាត់ចុះមកជួបខ្ញុំ គឺ នួន ជា ហ្នឹង ហ្នឹងគឺខ្ញុំចាំ ។ ប៉ុន្តែ មេខ្ញុំអត់នេះទេ គាត់ទៅនៅនឹងអ្នកលឿង មិនដឹងជារៀបចំស្អីខ្លះទេ នៅនឹងអ្នកលឿង ។ យូរៗឃើញតែអូមកខ្ញុំម្តង ។ នេះមែន ខ្ញុំនៅចាំ ។ ឯចំណែក ទំនាស់ប្រដាប់អាវុធវាផ្ទុះយ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំសូមពឹងផ្អែកលើបញ្ជីនៅ ស-២១ ហើយ ខែណាដែលមានយុទ្ធជនវៀតណាមមកប៉ុន្មាននាក់ ស្អីប៉ុន្មាននាក់ គឺសូមពឹងផ្អែកនៅលើបញ្ជីហ្នឹងតែម្តង គ្មានចាំទេ ។ នេះគឺខ្ញុំសូមសរុបខ្លីប៉ុណ្ណេះ ។ ដោយឡែកដែលចាំច្បាស់មែនទែន ហើយដែលយកចិត្តទុកដាក់ដឹកនាំការងារនេះ ជាប្រយោលបន្តិចដែរ ។ គឺនៅពេលដែលចាប់ផ្តើមមានការយកសំឡេងវៀតណាមតាមខ្សែអាត់ ចាក់ផ្សាយវិទ្យុនេះគឺចាំ គឺដឹង គឺគិតគូរដើម្បីដឹកនាំការងារនេះឲ្យបានល្អ នេះមែន ។ នេះគឺខ្ញុំសូមរំឭកឡើងវិញរឿងត្រួសៗប៉ុណ្ណេះ ហើយឃើញនូវចំណុចខ្វះខាតត្រង់ណាទៀត សូមលោកជំទាវ លោកមានប្រសាសន៍សួរខ្ញុំមកទៀតចោះ ខ្ញុំរង់ចាំឆ្លើយជម្រាបជូនដោយស្មោះ ។ សូមអរគុណ ។

[១៥:៤២:២០]

**ស៖** អរគុណ នៅក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០០៨ លោកបាននិយាយថា នៅក្នុងអង់គ្លេសលេខ ERN 00177587 ចាប់ផ្តើមពីសង្គ្រាមមករហូតដល់ឆ្នាំ១៩៧៩ ខ្ញុំបានឃើញឈ្លើយសឹកវៀតណាមបានចូលមកដល់ ។ ដោយលោកប្រើឃ្លាថា ចាប់តាំងពីមានសង្គ្រាមមក តើលោកមានន័យថា ចាប់តាំងពីថ្ងៃ១៧ ខែមេសា ៧៥មក? ឬក៏ចាប់ពីពេលណា?

**ឆ៖** សូមជម្រាបប្រសាសន៍លោកជំទាវ! ថ្ងៃដែលខ្ញុំចាំបំផុត ហើយដែលកំណត់ថាមានសង្គ្រាមជាមួយគ្នានេះ គឺក្រោយថ្ងៃ០៦ មករា ហ្នឹង ។ សូមបញ្ជាក់ថាមុន ០៦ មករា ហ្នឹង ឮៗល្បីថាកងទ័ពវៀតណាមគេចូលមកជ្រៅក្នុងទឹកដីខ្មែរ ប៉ុន្តែមិនដឹងដល់ត្រង់ណាខ្លះទេ ខ្ញុំមិនដឹងទេ ។ ដល់ថ្ងៃ០៦ មករាហ្នឹង ប៉ុល ពត គាត់ហៅពួកយើងខ្ញុំទៅបង្រៀន ។ ពេលហ្នឹងបានថា អូ! គេឈ្នះ ហើយពេលហ្នឹងដែលគេប្រកាសសង្គ្រាមអី ឃើញវៀតណាមមក គេឲ្យ ស-២១ យកខ្សែអាត់ថតសំឡេង ។

ដូច្នេះ ពាក្យដែលខ្ញុំបាទប្រើថា ចាប់ផ្តើមពីមានសង្គ្រាមហ្នឹង គឺសំដៅថ្ងៃ០៦ មករា អាហ្នឹងថ្ងៃហ្នឹងខ្ញុំចាំជាងគេហើយ សូមជម្រាបដោយត្រង់ អាថ្ងៃគេប្រកាសវិទ្យុ ។ ខ្ញុំឥឡូវនេះនៅជឿ ជឿថាគេប្រកាសអ៊ីចឹងមែន ប៉ុន្តែ វានឹកភ្លាមមិនឃើញដល់ហ្នឹងភ្លាមទេ នេះសូមជម្រាបដោយត្រង់ ។

**ស៖** នៅក្នុងបទសម្ភាសន៍ដដែលនោះដែរ លោកបាននិយាយបន្ថែមទៀតថា ហើយក៏មានជនស៊ីវិលវៀតណាមផងដែរ ប៉ុន្តែ គេត្រូវបានចាប់ខ្លួននៅសមរភូមិមុខកន្លែងដែលយោធាវាយប្រយុទ្ធគ្នា ។ ហើយតាមពិត ហើយមិនដែល កម្រនឹងមានអន្តោប្រវេសន៍វៀតណាមនៅក្នុងកម្ពុជាទេ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ លោកក៏បានបញ្ជាក់ទៀតថា បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វៀតណាមភាគច្រើនដែលរស់នៅក្នុងកម្ពុជាត្រូវបានកម្ទេចអស់ហើយ មានចំនួនតិចតួចណាស់ដែលនៅសេសសល់ ។ ប៉ុន្តែ ខ្ញុំនៅចាំថាខ្ញុំបានឃើញបញ្ជីឈ្មោះអ្នកទោសដែលមានឈ្មោះវៀតណាម ដែលនៅរស់នៅកម្ពុជានៅឡើយ ។ សំណួររបស់ខ្ញុំហ្នឹងគឺចំពោះលោក គឺថាចាប់តាំងពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ ពេលដែលលោកនិយាយថា លោកបានដឹងថាវាមានសង្គ្រាមនោះ តើលោកបានដឹងថា មានគោលនយោបាយដើម្បីលុបបំបាត់ជនជាតិវៀតណាមចេញពីទឹកដីកម្ពុជាដែរឬទេ?

**ឆ៖** ខ្ញុំអត់មានបានទទួលដំណឹងនេះទេ ក៏ប៉ុន្តែ វាមានព្រឹត្តការណ៍នៅឆ្នាំ១៩៧៣ ។ ព្រឹត្តការណ៍ឆ្នាំ១៩៧៣ហ្នឹងគេរៀនវគ្គ ប្រាប់បក្ខជនទាំងអស់ឲ្យជ្រាបថា នៅឆ្នាំ-- ឡុ យន់ គាត់ត្រូវការអាណិកជនវៀតណាមយកទៅភាគខាងត្បូងវៀតណាម ត្រៀមចាំបោះឆ្នោត អាហ្នឹងខ្ញុំដឹង ។

ដូច្នេះ នយោបាយជាជម្រៅថាឲ្យគេតាំងចិត្តថា ឲ្យតែវៀតណាមគេកម្ទេចនយោបាយបំបាត់ពូជសាសន៍វៀតណាមនៅស្រុកខ្មែរ អត់ឮអ្នកណាផ្សាយទេ ។ ប៉ុន្តែ អាណិកជនវៀតណាមដែលនៅសល់បន្តិចបន្តួចនៅស្រុកនោះ គេចាប់បញ្ជូនមកសុទ្ធតែមានសកម្មភាពដែលគេទាស់ចិត្តដែលប្រឆាំងនឹងគេ ។

ដូច្នេះ គេកំណត់ទុកថាជាខ្មាំង ដូចខ្មែរ ដូចអាណិកជនចិនអ៊ីចឹងដែរ ។ អាហ្នឹងខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** លោកបានស្តាប់លោក ណាយ៉ាន់ ចាន់ដា ដែលគាត់ឆ្លើយពីការបោះពុម្ពផ្សាយនូវមន្ទីរព័ត៌-មាន ហើយនិងក្រសួងការបរទេសនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ ហើយដែលគេហៅថា “សៀវភៅខ្មៅ” ។ តើលោកចាំពីការបោះពុម្ពផ្សាយនោះទេ?

[១៥:៤៨:២១]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំមិនដែលឃើញសៀវភៅនេះទេ រហូតដល់ទៅឆ្នាំ៨៣ ទើបខ្ញុំឃើញសៀវភៅហ្នឹងគេចម្លងតមួយសាពីររួចទៅហើយ ។ ដូច្នេះ សៀវភៅដែលក្រសួងការបរទេសខ្មែរកម្ពុជាប្រជាធិបតេយ្យបោះពុម្ព ខ្ញុំអត់បានឃើញជាសៀវភៅច្បាប់ដើម ច្បាប់បោះពុម្ពទេ ។ ឃើញ ៨៣ អីហ្នឹងនៅសំឡូត គេចម្លងមួយតពីរតរួចទៅហើយ ។ សូមជម្រាបបញ្ជាក់អីចឹង ។

**ស៖** អរគុណ ។ នៅក្នុងសៀវភៅនោះ គឺមានការចោទប្រកាន់ថា ការវាយប្រហាររបស់វៀត-ណាមមកលើកម្ពុជាប្រជាធិបតេយ្យភ្លាមៗ បន្ទាប់ពីខ្មែរក្រហមបានរំដោះភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ តើលោកបានដឹងទេនៅពេលនោះថា រដ្ឋាភិបាល គឺរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជឿជាក់ថា វៀតណាមបានវាយប្រហារមកលើកម្ពុជាភ្លាមៗ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬក៏ទ័ពរបស់ខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញនោះភ្លាម?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ១៧ មេសា កម្ពុជារំដោះភ្នំពេញ ឯចំណែកភាគខាងត្បូងវៀតណាមរំដោះនៅថ្ងៃ៣០ មេសា ក្រោយកម្ពុជាដប់បីថ្ងៃ ។ ដូច្នេះ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំមិនជឿទេថា វៀត-ណាមឯណាបំបែកទ័ពយកមកវាយស្រុកខ្មែរភ្លាមនោះ ខ្ញុំមិនជឿ នេះជម្រាបដោយត្រង់ ។

**ស៖** អរគុណ ហើយក៏នៅក្នុងសៀវភៅនោះដែរ ក៏មានការចោទប្រកាន់ថា វៀតណាមបញ្ជូនចារកម្ម ឬក៏គិញមកកម្ពុជានៅឆ្នាំ១៩៧៦ ។ តើលោកបានដឹងដែរឬទេថាមានគិញ មកក្នុងកម្ពុជានៅក្នុងឆ្នាំនោះ?

**ឆ៖** រឿងនេះវាអាចមាន ហើយអាចមកដល់ស-២១ ផងក៏មិនដឹង ព្រោះខ្មែរមានចាប់ជនស៊ីវិលហើយអាចបញ្ជូនមកដល់ស-២១ ។ ដូច្នេះ តែចាប់ហើយធម្មតាទេ គេតែងចោទថា គិញហើយប្រគល់មកឲ្យស-២១ វៃសួរចម្លើយហើយ ។ នេះជារឿងដែលខ្ញុំអាចសន្និដ្ឋានបាន នេះសូមជម្រាបបញ្ជាក់ជូនលោកជំទាវប៉ុណ្ណេះ ។

**ស៖** ហើយបន្ថែមលើហ្នឹងទៀត នៅក្នុងសៀវភៅខ្មៅនោះ គឺមានការចោទប្រកាន់ថា មានការប៉ុនប៉ងធ្វើការឃាត និងការសម្លាប់ នូវមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៥ និងក្នុងឆ្នាំ ១៩៧៦ ។ តើលោកបានដឹងអំពីការប៉ុនប៉ងដើម្បីធ្វើឃាតក្នុងពេលនោះដែរឬទេ?

[១៥:៥២:២៦]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំមិនដឹងទេ ។ ក៏ប៉ុន្តែ ឯកសារស-២១ ដែលចាប់ផ្ដើមនិយាយប្រាថ្នាចង់ធ្វើឃាតនោះ គឺកងពល៣១០ របស់ភូមិភាគឧត្តរចាស់របស់មិត្ត អឿន ។ ហ្នឹងបើ

តាមខ្ញុំចាំ ជាឯកសារដំបូងគេបង្អស់ដែលនិយាយប្រាថ្នាធ្វើឃាតលេខាបក្ស ។ ហើយឯកសារដែលនៅសល់ដែរគឺឯកសារថ្ងៃ៣០ មីនា ១៩៧៦ នេះនិយាយអំពី ប៉ុល ពត ប្រុងប្រយ័ត្នបដិវត្តន៍ ។ ប្រសិនបើវៀតណាមអញ្ជើញគឺមិនទៅខ្លួនឯងទៅទៀត សុខចិត្តឲ្យពូ នួន ឬសុខចិត្តឲ្យ ខៀវ សំផន ទៅ ។

ដូច្នេះ សុទ្ធតែត្រៀមជើងព្រួលបែបនេះ អាហ្នឹងវាមានឯកសារពីរសម្រាប់បញ្ជាក់ ។ ទីមួយគឺសេចក្ដីសារភាពរបស់ មិត្តអឿន លេខាកងពល៣១០ ទីពីរគឺនៅខាងចុងនោះវាមានសេចក្ដីណែនាំសេចក្ដីសម្រេចចិត្តរបស់ ប៉ុល ពត ថាគាត់មិនទៅទេទុកឲ្យ នួន ជា ឬក៏ ខៀវ សំផន ទៅជួបគេ ខាងវៀតណាម ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង គឺឃើញតែឯកសារប៉ុណ្ណឹង ។

**ស៖** ហើយលោកបានដឹងថា មានឯកសារនោះនៅពេលនោះ ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ឯកសារដែលខ្ញុំដឹងនៅពេលនោះ គឺសេចក្ដីសារភាពរបស់ មិត្តអឿន កងពល៣១០ ។

ឯចំណែកឯកសារថ្ងៃ៣០ ខែមីនា ១៩៧៦ ខ្ញុំទើបនឹងទទួលបានពីដៃលោកចៅក្រមស៊ើបអង្កេតថ្មីៗនេះឯង ថ្ងៃខែខ្ញុំភ្លេចទៅហើយ វាមាននៅក្នុងកំណត់ហេតុសួរចម្លើយ ។

[១៥:៥៤:៣០]

**ស៖** សូមអរគុណ ។ នៅក្នុងការផ្ដល់សក្ខីកម្មគឺលោក ណាយ៉ាន់ ចាន់ដា គាត់បាននិយាយពីការតស៊ូដណ្ដើមអំណាចផ្ទៃក្នុងក្នុងឆ្នាំ១៩៧៦ ដោយ ប៉ុល ពត បន្ទាប់ពីមានការសម្រិតសម្រាំងក្នុងខែកញ្ញា ហើយដែលមានសេចក្ដីសម្រេចនោះ គឺបានធ្វើនោះដើម្បីស្វែងរកដំណោះស្រាយអចិន្ត្រៃយ៍មួយ ដើម្បីដោះស្រាយបញ្ហាវិវាទជាមួយវៀតណាម ហើយដើម្បីបំបាត់ពូជ ឬក៏លប់បំបាត់វៀតណាមពីកម្ពុជា ERN ក្នុងភាសាអង់គ្លេសនោះ គឺលេខ00192271 នៅក្នុងសៀវភៅមួយដែលមានឈ្មោះថា "សត្រូវបងប្អូនឯង" ។ ថាតើមានគោលនយោបាយបែបហ្នឹងទេទាក់ទងទៅរកដំណោះស្រាយអចិន្ត្រៃយ៍ដោះស្រាយវិវាទជាមួយវៀតណាម ហើយការសម្លាប់បំផុតពូជវៀតណាមនៅកម្ពុជាដែលបានបញ្ជូនមកលោកនៅក្នុងពេលដែលលោកធ្វើការក្នុងរបបនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ឯកសារដែលខ្ញុំបានទទួលពីខាងលើមក សៀវភៅខ្មៅក៏អត់ ឯកសារបែបនេះក៏អត់ ។ មានតែឯកសារដែលខ្ញុំផ្ដល់ឲ្យខាងលើវិញ គឺចម្លើយសារភាពរបស់មន្ទីរស-២១ ។ ឯចំណែកឯកសារដែលខ្ញុំទទួលពីខាងលើមានទង់បក្សដិវត្តន៍ យុវជនបដិវត្តន៍ លក្ខន្តិកៈបក្សរបៀបហ្នឹងទេ ឯចំណែកឯកសារជាក់ស្ដែងចូលទៅក្នុងទំនាស់រវាងខ្មែរនិងវៀតណាម បក្សទាំងពីរនេះខ្ញុំអត់ដែលបានទទួលពីខាងលើមកទេ ។ នេះជម្រាបដោយស្មោះត្រង់ ។

**ស៖** ខ្ញុំយល់ហើយថា លោកមិនមានលទ្ធភាពនិងទទួលបាននូវសៀវភៅខ្មៅ និងសៀវភៅរបស់ ណាយ៉ាន់ ចាន់ដា ទេ។ ប៉ុន្តែ ខ្ញុំសួរថាតើលោកមានអ្នកណាបានប្រាប់លោកទេ ឬក៏លោកបានអានពីរឿងហ្នឹង អំពីសេចក្តីសម្រេចដើម្បីរកដំណោះស្រាយអចិន្ត្រៃយ៍ចំពោះជម្លោះរវាងវៀតណាម ហើយនិងលុបបំបាត់ជនជាតិវៀតណាមចេញពីកម្ពុជានៅក្នុងរវាងឆ្នាំ១៩៧៦ នោះ?

**ឆ៖** និក្ខេបបទនេះ គោលគំនិតនេះ របស់អ្នកជំនាញ ណាយ៉ាន់ ចាន់ដា ខ្ញុំឮនៅទីនេះឯងជាលើកដំបូង ។ ហើយសុំជម្រាបលោកជំទាវថា សៀវភៅរបស់លោក ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯងនេះ ក៏ខ្ញុំទើបតែឃើញនៅពេលដែលលោក ណាយ៉ាន់ ចាន់ដា មកឧទ្ទេសនាមនិក្ខេបបទរបស់គាត់នៅទីនេះ ។

**ស៖** តើលោកបានដឹងអំពីនយោបាយនោះទេ នៅក្នុងឆ្នាំ១៩៧៦?

**ឆ៖** ខ្ញុំសូមអភ័យទោស ខ្ញុំសុំបញ្ជាក់លោកជំទាវនយោបាយអី សូមលោកជំទាវមានប្រសាសន៍ឲ្យចំ ។

[១៥:៥៨:១៤]

**ស៖** គឺជាគោលនយោបាយដើម្បីស្វែងរកដំណោះស្រាយអចិន្ត្រៃយ៍ ដើម្បីដោះស្រាយវិវាទជាមួយវៀតណាម ហើយនិងលុបបំបាត់វៀតណាម ជនជាតិវៀតណាមនៅក្នុងកម្ពុជា ។

**ឆ៖** ខ្ញុំអត់ដឹងទេ អត់ដឹងគោលនយោបាយនេះទេ ហើយអត់មានឮអ្នកណានិយាយផង ។ នេះជម្រាបដោយត្រង់ អត់មានឮអ្នកណានិយាយទេ ។

**ស៖** អរគុណ។កាលណាមានការសម្រិតសម្រាំងនៅក្នុងជួរកងទ័ពនៅកម្ពុជា ហើយលោកបានយោងទៅរកចំណុចមួយដែលថា នៅក្នុងការសម្លាសមួយចំនួន ហើយខ្ញុំយោងទៅរកឯកសារមួយដែលមានលេខយោងជាភាសាអង់គ្លេស ERN00218977 រហូតទៅដល់ 00218978 ។ នៅក្នុងអត្ថបទខ្មែរលេខ ERN00218975 រហូតដល់ 00218976 ។ ហើយអត្ថបទជាភាសាបារាំងលេខERN 00239998 រហូតដល់ 00239999 ។ នោះគឺជាបញ្ជារាយនាមឈ្មោះមនុស្សចំនួន៦៦នាក់ដែលនៅក្នុងកងទ័ពដែលត្រូវបានសម្លាប់ក្នុងរយៈពេលបីថ្ងៃ២២, ២៦, ២៩ ខែមីនា ឆ្នាំ១៩៧៦ ។

តើមានការសួរចម្លើយអ្នកទាំងអស់ហ្នឹងនៅស-២១ ដែរឬទេ?

**ឆ៖** ខ្ញុំ បញ្ជីនេះធ្វើឲ្យខ្ញុំឆ្ងើលម្តងដែរ ភ្ញាក់។ កាលដែលខ្ញុំធ្វើប្រធានស-២១ អត់ឃើញជនជាតិវៀតណាមណាមកជាធំទំហំទេ ។ ក៏ប៉ុន្តែ មានបញ្ជីមួយដែលប្រគល់មកឲ្យខ្ញុំធ្វើសេចក្តីអត្ថាធិប្បាយ

មនុស្សហុបសិបប្រាំមួយនាក់នេះ ជាអ្នកនេសាទត្រីវៀតណាម ។ ខ្ញុំថា អ៊ើ! បញ្ជីនេះសង្ស័យបញ្ជីរបស់ ១៦៤ ។

**សៈ** ខ្ញុំសូមកាត់បន្តិច ពីព្រោះនេះជាការយល់ខុសគ្នា ។ ខ្ញុំនិយាយអំពីបញ្ជីឈ្មោះទាហានខ្មែរ ទាហានកម្ពុជាដែលបានមកដល់ស-២១ ហើយនេះ គឺនិយាយអំពីបញ្ជីឈ្មោះរបស់ទាហានទាំងនោះ ដែលត្រូវបានសម្លាប់នៅថ្ងៃទី២២, ២៦ និងថ្ងៃទី២៩ នៅក្នុងឆ្នាំ៧៦ ។ ហើយខ្ញុំសួរទៅលោកថា តើទាហានខ្មែរទាំងអស់នុំងត្រូវបានគេសួរចម្លើយនៅស-២១ ដែរឬទេ?

**ឆៈ** បើនិយាយពីទាហានលន់នល់ចាស់ អាចនៅសល់ឯគុកពេទ្យឆ្កួតតាខ្មៅឯណោះ ហើយពេលដែល ណាត គេចេញទៅនេះ គេឲ្យមិត្តហ៊ី កម្ទេច បង្ហើយការងារនេះ ។ អត់មានសួរចម្លើយទេ ។ ភាគច្រើនទាហានគឺមិនដែលបានឃើញសួរចម្លើយទេ ។

**សៈ** តើលោកមានបានដឹងទេថា បញ្ជីឈ្មោះទាហានរបស់កម្ពុជាប្រជាធិបតេយ្យទាំង៦៦នាក់ហ្នឹងមានបានទៅធ្វើការប្រយុទ្ធតតាំងជាមួយវៀតណាមដែរឬទេ?

**ឆៈ** សូមទោសលោកជំទាវ! ខ្ញុំហើយនិងលោកជំទាវ ខ្ញុំអត់ទាន់ច្បាស់ទេ ។ អ៊ីចឹងសូមមេត្តាបញ្ជាក់លោកជំទាវម្តងទៀត ។ ៦៦នាក់នេះ ជាទាហាន ប៉ុល ពត ឬក៏ទាហាន លន់ នល់? ដំបូងខ្ញុំរាយ-ការណ៍ជូនលោកជំទាវមិញគឺសំដៅទាហាន លន់ នល់ ។ ប៉ុនដល់៦៦នាក់នេះ ទាហាន ប៉ុល ពត ខ្ញុំមិនទាន់ប៉ានឆ្លើយថាម៉េចទេ ។ សូមបញ្ជាក់ ។

**សៈ** នេះមិនមែនសម្រាប់ខ្ញុំឆ្លើយនឹងសំណួរទេ ក៏ប៉ុន្តែ គឺមានបញ្ជីឈ្មោះដែលថា អ្នកទោសត្រូវបានកម្ទេចនៅស-២១ នៅទួលស្លែង ហើយពួកគេត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ៧៦ ។ តើខ្ញុំអាចសន្និដ្ឋានថា ពួកគេហ្នឹងអាចជាកងទ័ពរបស់យោធាបក្សកម្ពុជាប្រជាធិបតេយ្យ ហើយមិនមែនជាទាហានរបស់ លន់ នល់ ទេនៅដំណាក់កាលនោះ?

[១៦:០៣:៥៨]

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវដោយត្រង់ ខ្ញុំពន្យល់មិនទាន់កើតទេ ដរាបណាមិនទាន់បានឃើញបញ្ជីនេះឲ្យច្បាស់លាស់ ។

**សៈ** លោកបាននិយាយនៅក្នុងបទសម្ភាសន៍របស់លោកជាមួយនឹងតុលាការយោធា ដែលមានលេខ D42/1.13 ដែលមានលេខ ERN00197753 ហើយនិងមានលេខ 00197759 ទាក់ទងទៅនឹងបញ្ជីនោះ ។ ពួកគេហ្នឹងគឺជាកងទ័ពដែលត្រូវបានចាប់ខ្លួននៅភ្នំពេញ នៅតំបន់២៥ ។ លោកបានឃើញ

មុខតែមួយទេ គឺ បានអ៊ូច និលពេជ ដែលមានលេខ៥៥ នៅក្នុងបញ្ជីនោះ ហើយបានរៀបរាប់ថា គាត់ហ្នឹងមានឋានៈសក្តិ៤ ហើយលោកក៏បានរៀបរាប់ទៀតថា “ខ្ញុំបានមិនបានឃើញ គឺមិនបានឃើញមុខរបស់ទាហានអស់ទាំងហ្នឹងផ្ទាល់ទេ” ប៉ុន្តែ ខ្ញុំព្រមទទួលថា ពួកគេគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ មក ។ តើអ្វីដែលខ្ញុំលើកឡើងនេះ បណ្តាលឲ្យលោកនឹងឃើញដែរឬទេ?

**ឆ៖** ជម្រាបលោកប្រសាសន៍លោកជំទាវ! បើនិយាយអំពីសក្តិបួនកន្លះម្នាក់ បើគាត់នោះពិតជាឈ្មោះ បានអ៊ូច និលពេជៗ។ នេះខ្ញុំសូមប្រើពាក្យនេះឲ្យចំតាមឈ្មោះគាត់ បានអ៊ូច និលពេជ។ បានអ៊ូច និលពេជ នេះគឺជាឪពុកមា ណាត ប៉ុន្តែមិនដឹងជាថ្ងៃណាទេ ។ មកជាប់នៅនឹង *ប៉េអេស (PS) ប៉េហ្ស៊ី (PJ)* នេះ ។ ណាត នាំខ្ញុំទៅអង្គុយលេងនៅបន្ទប់នុំងម្តង ។ ហ្នឹងមែន ខ្ញុំឃើញតែមួយហ្នឹងមែន ។ ដូច្នេះ ទាហាននេះមិនសំដៅថា ជាទាហានរបស់បក្សកុម្មុយនិស្តកម្ពុជាទេ គឺដើរប្រមូលពី២៥ ពីអី១ ណាត មិនសមប្រមូលគេយកមកវៃចោលអ៊ីចឹង ។ ដូច្នេះ អត់បានសួរចម្លើយទេ ។ បានអ៊ូច និលពេជ ក៏ខ្ញុំមិនដឹងជាគេសួរឬក៏មិនសួរទេ ។ នេះរឿងពិត ។ ខ្ញុំរំឭកឃើញហើយ សូមជម្រាបដោយស្មោះត្រង់អ៊ីចឹង ។

**ស៖** សូមអរគុណ ។ ឥឡូវនេះ យើងនិយាយអំពីអ្នកទោសជាជនជាតិវៀតណាមម្តង ។ នៅក្នុងអង្គហេតុដែលបានព្រមព្រៀងគ្នា នៅលេខ១០៨ លោកមិនជំទាស់ថា ចំនួនបរទេសដ៏ច្រើនជាងគេដែលត្រូវបានជាប់ឃុំឃាំងនោះគឺជាជនជាតិវៀតណាម ។ ហើយបញ្ជីដែលមានកត់ត្រា គឺមានបង្ហាញអំពីចំនួនជនជាតិវៀតណាមយ៉ាងហោចណាស់ចំនួនបួនរយនាក់ ដែលក្នុងនោះ ប្រហែលជាមួយរយហាសិបនាក់ ត្រូវបានចុះឈ្មោះថាជាឈ្លើយសឹកវៀតណាម ។ ហើយយ៉ាងហោចណាស់មានចំនួនមួយរយនាក់ គឺជាជនជាតិស៊ីវិល គឺជាជនស៊ីវិលវៀតណាម ។ តើមានអ្វីលោកចង់បន្ថែមទៅលើសេចក្តីថ្លែងការណ៍របស់លោក ដែលលោកបានព្រមព្រៀងទៅលើអង្គហេតុនេះដែរឬទេ?

[១៦:០៨:២២]

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកជំទាវ! អត់មានអីជំទាស់ទេ ។ យល់ស្របដដែល រក្សាការយល់ស្របនេះដដែល ។

**ស៖** ដូច្នេះ តើលោកអាចប្រាប់បានទេ នៅពេលដំបូងដែលលោកបានទទួលឈ្លើយសឹកវៀត-ណាម នៅពេលដែលគេបញ្ជូនមកនៅស-២១ នោះ តើនៅពេលណា?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំមិនចាំទេ ។ ប៉ុន្តែ មានតិចតួចណាស់ មុនថ្ងៃ៦ មករា ១៩៧៨ ក្រោយមកបានមានច្រើន ។

**ស៖** សូមអរគុណ ។ ហើយបន្ទាប់មកទៀត លោកក៏មិនជំទាស់នៅកថាខណ្ឌ១០៨(ខ) ដែរ ដែលថា "ការកត់ត្រាលើកដំបូងនៅក្នុងបញ្ជីថា ជាជនជាតិវៀតណាម គឺនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ៧៦" ។ តើលោកពុំមានអ្វីត្រូវនិយាយបន្ថែមទៅលើអង្គហេតុដែលបានព្រមព្រៀងគ្នានេះទេឬ?

[១៦:០៩:៥២]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ឲ្យតែមាននៅក្នុងបញ្ជី ហើយឲ្យតែខ្ញុំយល់ថា បញ្ជីនោះពិតប្រាកដ ខ្ញុំមិនដែលហ៊ានជំទាស់ទេ ។ ដូច្នេះ អាបញ្ជីអំមិញហ្នឹង ខ្ញុំជឿថា អាចគឺជាបញ្ជីរបស់ស-២១ពិតហើយ ។ ក៏ប៉ុន្តែ ឲ្យខ្ញុំពន្យល់ថា យ៉ាងម៉េចអីយ៉ាងម៉េច ខ្ញុំមិនចាំទេ សូមជម្រាបដោយត្រង់ ។

**ស៖** សូមអរគុណ ។ មានពេលខ្លះដែលជនជាតិវៀតណាមត្រូវបានដឹកពីសមរភូមិដោយបុគ្គលិករបស់ស-២១ តើការដឹកជញ្ជូនហ្នឹងកើតមានឡើងមុនថ្ងៃទី០៦ ខែ០១ ឆ្នាំ៧៨ ឬ? តើមុនហ្នឹងមានធ្លាប់មាន ការដឹកជនជាតិវៀតណាមហ្នឹងដែរឬទេ?

**ឆ៖** រឿងនេះក៏ចាំមិនច្បាស់ដែរ នេះសូមជម្រាបដោយត្រង់ ខ្ញុំចាំអត់ច្បាស់ទេ ។ ប៉ុន្តែ មានៗទៅដឹក មិនដឹងជាក្រោយ ឬមុន ។

**ស៖** នៅពេលដែលមានការដឹកជញ្ជូនបែបហ្នឹង គឺការដឹកជញ្ជូនឈ្លើយសឹកវៀតណាមពីសមរ-ភូមិមុខមកៗស-២១ នោះ ។ តើលោកមានបានចេញបញ្ជាបុគ្គលិកស-២១ ឲ្យបំពេញភារកិច្ចនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បុគ្គលិកស-២១ ដែលចេញទៅអ៊ីចឹងបាន ទាល់តែមានបញ្ជាពីខ្ញុំ នេះទីមួយ ។ ទីពីរទៀត បើសិនជាចេញទៅជនបទអ៊ីចឹង ទាល់តែមានលិខិតដើរផ្លូវពិសេសមួយ ។

**ស៖** សូមអរគុណ ។ ដូច្នេះ គឺថាលោកនឹងដឹងពីតំបន់ដែលពួកឈ្លើយសឹកអស់ទាំងហ្នឹងត្រូវបានចាប់ខ្លួន ដើម្បីចេញបញ្ជាឲ្យពួកគេហ្នឹង ត្រូវបានដឹកជញ្ជូនមកស-២១ ។ តើនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍ ត្រឹមត្រូវ ។

**ស៖** តើលោកអាចរំឭកឡើងវិញទេថា តើនៅតំបន់ណាខ្លះដែលលោកបានបញ្ជូនបុគ្គលិកស-២១ ឲ្យទៅដឹកជញ្ជូនឈ្លើយសឹកជនជាតិវៀតណាមមកនោះ?

**ឆ៖** ខ្ញុំនឹកមិនឃើញទេ ។ ផ្លូវមានពីរ ។ ទីមួយ តាមផ្លូវលេខ១ ភ្នំពេញ អ្នកលឿង ហើយទៅព្រៃវែង ស្វាយរៀង ។ ផ្លូវមួយទៀត គឺផ្លូវលេខ៧ ពីភ្នំពេញ ទៅស្គន់ ទៅកំពង់ចាម ហើយឆ្លងកាត់ទៅពញាក្រែក ទៅអ៊ីៗនុំង ។ ដូច្នេះ មិនដឹងទៅតាមផ្លូវណាយ៉ាងម៉េចទេ ។ ហើយខ្ញុំចាំតែប៉ុណ្ណេះទេ លិខិតដើរផ្លូវពិសេសហ្នឹងមិនដឹងជាប្រើសម្រាប់ទៅវៀតណាមហ្នឹងប៉ុន្មាន ហើយប្រើសម្រាប់ទៅបាត់ដំបងហ្នឹងប៉ុន្មានទេ ប៉ុន្តែខ្ញុំចាំបានថា លិខិតដើរផ្លូវពិសេសហ្នឹងប្រើបានតែពីរដងគត់ ។ ក្រោយមកមេឈប់ឲ្យប្រើ ។

**ស៖** សូមអរគុណ ។ នៅក្នុងសេចក្តីថ្លែងការណ៍ដែលលោកបានធ្វើនៅក្នុងអំឡុងពេល ស៊ើបអង្កេតរបស់យោធា តុលាការយោធានៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ(១៩)៩៩ ដែលមានលេខ ERN ជាភាសាអង់គ្លេស 00184829 រហូតដល់លេខ 00184832 និងភាសាខ្មែរមានលេខ 0089673 រហូតដល់លេខ 0089678 ហើយមិនមានការបកប្រែជាភាសាបារាំងទេ ។ លោកបាននិយាយថា ជនទាហានវៀតណាម ដែលចម្លើយរបស់ពួកគេហ្នឹងត្រូវបានកត់ត្រានៅលើខ្សែអាត់ ហើយត្រូវបានចាក់ផ្សាយ ហើយរូបថត ក៏ត្រូវបានថត ដើម្បីបង្ហាញទៅពិភពលោកថា ពួកគេហ្នឹង នឹងត្រូវបានកម្ទេច ។ ហើយលោកក៏បានបន្តទៀតថា គឺមានជនជាតិវៀតណាមច្រើន ហើយខ្ញុំមិនចាំពួកគេអស់ទេ ហើយក៏មានការពន្យល់បន្ថែមទៀត ទៅលើទាហានវៀតណាម ដែលត្រូវបានជាប់ឃុំឃាំងនៅស-២១ ។ ពួកគេគឺជាយុទ្ធជនដែលត្រូវបានចាប់ខ្លួន នៅលើសមរភូមិ នៅលើទឹកដីកម្ពុជានៅខាងត្បូង ក្នុងអំឡុងឆ្នាំ៧៨ ។ ដូច្នេះ ពីសេចក្តីថ្លែងការណ៍របស់លោកនេះ ហាក់បីដូចជាមានការបង្ហាញថា មានទាហានវៀតណាមដែលត្រូវបាននាំខ្លួនមកស-២១ នៅក្នុងអំឡុងឆ្នាំ៧៧ ហើយនិងពេលក្រោយទៀតគឺនៅក្នុងអំឡុងឆ្នាំ៧៨ ។ តើនេះជាការត្រឹមដែរឬទេ?

[១៦:១៥:៤៥]

**ឆ៖** ខ្លឹមសារដែលជំទាវអានអម្បាញ់មិញនេះ ខ្ញុំនៅតែគិតថាវាបង្ហាញពី៧៨ ទេ ឬយ៉ាងម៉េចខ្ញុំមិនច្បាស់ទេ ប៉ុន្តែ បញ្ជីនៅស-២១ វាបំភ្លឺ យើងច្បាស់ជាងអាចម្លើយរបស់ខ្ញុំនៅតុលាយោធាទៅទៀត ។ ៧៧ មកដល់ប៉ុន្មាន? កងទ័ពវៀតណាម ។ ៧៨ មកដល់ប៉ុន្មាន? បញ្ជីស-២១ វាពិតជាបំភ្លឺយើងច្បាស់ជាង ។ ចម្លើយរបស់ខ្ញុំដែលស្រពេចស្រពិល នេះខ្ញុំសូមជម្រាបបញ្ជាក់អ៊ីចឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ លោកប្រធាន ខ្ញុំគិតថាប្រហែលជាដល់ពេល ដែលយើងត្រូវសម្រាកហើយ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម ។ ឥឡូវនេះ អង្គជំនុំជម្រះប្រកាសរៀបចាដំណើរការសវនាការថ្ងៃនេះ គឺត្រូវផ្អាកត្រឹមនេះ ហើយសវនាការដែលត្រូវលើកបន្តទៅនឹងព្រឹកថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។

អនុរក្សមន្ទីរឃុំឃៅនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការវិញ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់ ។

ហើយក៏ជម្រាបជូនដំណឹងដល់ភាគីដែលចូលរួមក្នុងនីតិវិធីសវនាការដូចគ្នា ។ សូមអញ្ជើញមកចូលរួមក្នុងដំណើរការសវនាការនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនជាកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង១៦:១៧:២៩នាទី]*